ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ [illegible]

◆ [illegible]

[illegible]

លេខ ៦៨ ខែសីហា ឆ្នាំ២០០៥

លេខ៦៤ ខែមេសា ឆ្នាំ២០០៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
## មាតិកា


◆ សំបុត្រៈ តើខ្ញុំឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ.....................១

**ផ្នែកឯកសារ**

◆ សេចក្ដីអំពាវនាវឲ្យមានការផ្ដល់ឯកសារដល់អង្គជំនុំជម្រះ........៤

◆ អតីតលេខាទូតកម្ពុជាប្រចាំទីក្រុងបែលក្រាដ............................៥

◆ សារាចរណែនាំស្ដីអំពីការថែរក្សារៀបចំទុកដាក់អដ្ឋិធាតុ............ ៨

◆ បញ្ជីឈ្មោះជនរងគ្រោះមន្ទីរស-២១..................................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ថ្ងៃឈឺចាប់.........................................................១៤

◆ ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ? ......................១៦

◆ មិននិយាយមិនមែនមានន័យថាភ្លេចទេ..............................២៧

◆ វាលពិឃាតបឹងជើងឯក.............................................. ២៩

**ផ្នែកច្បាប់**

◆ ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម..........៣៤

**វេទិកាពិភាក្សាសាធារណៈ**

◆ សេចក្ដីថ្លែងការណ៍របស់លេខាធិការដ្ឋានក្រុមការងារ.............. ៤៤

◆ សេចក្ដីថ្លែងការណ៍របស់សហព័ន្ធអន្តរជាតិស្ដីអំពីសិទ្ធិមនុស្ស...៤៦

◆ ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា..............................៤៨

◆ យុត្តិធម៌សម្រាប់ជនរងគ្រោះ.........................................៥៥

◆ ចងចាំការដួលរលំទីក្រុងភ្នំពេញទៅក្នុងរបបខ្មែរក្រហម............៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងភាពនឹងថ្កល់................................................ ៥៧

◆ ត្រូវតែកាត់ទោសដើម្បីទុកជាមេរៀន......................... ៦០






កងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះៈ** យិន នាន, ញាណ សុជាតិ, ម៉ូង សាន់ឃុីស, ដាវីដ ប៊ីយ, គីម កែវកន្និដ្ឋា, ម៉េង រស្មី, ហេង ថាល់សាវុធ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **អ្នកបកប្រែៈ** ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន


Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# តើខ្ញុំឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យដោយរបៀបណា?

នៅក្នុងរយៈពេលដប់ឆ្នាំដែលខ្ញុំបានធ្វើការឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកសារព័ត៌មានបានលើកសំណួរខាងលើនេះញឹកញាប់ជាងសំណួរផ្សេងៗដទៃទៀត ។ ខ្ញុំបានគិតគូរយ៉ាងច្រើនចំពោះសំណួរនេះទន្ទឹមនឹងពេលមកដល់នៃខួបគម្រប់លើកទី៣០ នៃការឡើងកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំគឺជាក្មេងម្នាក់អាយុ ១៤ឆ្នាំ ។ ឪពុករបស់ខ្ញុំគឺជាជីផែនទី ហើយក្រោយមកជាប់កំណែនយោធាលន់ណុល ។ បើទោះបីជាគ្រួសារខ្ញុំមានជីវភាពប្រសើរជាងប្រជាជនភាគច្រើននៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ក៏ដោយ តម្លៃទំនិញដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃបានធ្វើឲ្យម្តាយខ្ញុំត្រូវចំណាយយ៉ាងប្រុងប្រយ័ត្នបំផុតដោយសារតែប្រាក់បៀវត្សរ៍តិចតួចរបស់ឪពុកខ្ញុំ ។ ជាងនេះទៅទៀត ភាគច្រើននៃសាច់ញាតិក្រុមគ្រួសាររបស់ខ្ញុំបានផ្លាស់ទីលំនៅទៅទីក្រុងភ្នំពេញដើម្បីគេចពីការវាយប្រហារនៅតាមទីជនបទ ។ ម្តាយរបស់ខ្ញុំសន្សំសំចៃខ្លាំងណាស់ សូម្បីតែផ្លែចេកមួយផ្លែឬអង្ករមួយគ្រាប់គឺជាម្ហូបអាហារនៅក្នុងផ្ទះរបស់ខ្ញុំ ។ ឪពុកម្តាយរបស់ខ្ញុំមានការព្រួយបារម្ភជាប្រចាំក្រែងហេតុការណ៍មិនល្អនឹងកើតឡើងចំពោះបងៗស្រីរបស់ខ្ញុំ ហេតុដូច្នេះហើយគាត់យកចិត្តទុកដាក់ការពារសុវត្ថិភាពបងៗស្រីរបស់ខ្ញុំជាពិសេស ។ សាលារៀនរបស់ខ្ញុំបិទទ្វារស្ទើរតែរៀងរាល់សប្តាហ៍ ហើយដោយសារតែមូលហេតុទាំងអស់នេះ ខ្ញុំបានរៀនធ្វើអ្វីៗដោយខ្លួនឯង (ដូចជារៀនធ្វើខ្លែងពីក្រដាសកាសែត) និងរៀនគ្រប់គ្រងលើខ្លួនឯង ។

ការគ្រប់គ្រងលើខ្លួនឯងនេះបានជួយសម្រួលដល់ការរស់នៅរបស់ខ្ញុំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្ញុំនៅផ្ទះតែម្នាក់ឯងគត់ ។ ម្តាយខ្ញុំនិងសមាជិកដទៃទៀតនៃគ្រួសារខ្ញុំបានចាកចេញទៅរកកន្លែងមានសុវត្ថិភាពមុនមួយថ្ងៃរួចទៅហើយ ។ ម្តាយនិងសមាជិកគ្រួសាររបស់ខ្ញុំបានប្រាប់ខ្ញុំថាគាត់នឹងត្រឡប់មកយកខ្ញុំវិញ ។ ប៉ុន្តែជាអកុសល ផ្លូវត្រូវបានកាត់ផ្តាច់ ហើយកងទ័ពខ្មែរក្រហមបានប្រាប់ខ្ញុំថាត្រូវតែចាកចេញពីផ្ទះ ។ ខ្ញុំបានចាកចេញពីផ្ទះដោយគ្មានទិសដៅពិតប្រាកដទេ ។ អ្នករស់នៅក្បែរៗផ្ទះរបស់ខ្ញុំបានចាកចេញពីផ្ទះអស់ទៅហើយ ។ ខ្ញុំចាប់ផ្តើមធ្វើដំណើរ ។ នៅតាមផ្លូវ ខ្ញុំបានឮប្រជាជននិយាយថា គាត់កំពុងតែត្រឡប់ទៅភូមិកំណើតរបស់គាត់វិញ ។ ខ្ញុំក៏សម្រេចចិត្តត្រឡប់ទៅផ្ទះកំណើតម្តាយរបស់ខ្ញុំនៅខេត្តតាកែវ ។ ដោយសារតែខ្ញុំមិនបានយកអាហារតាមខ្លួន ខ្ញុំបានសុំអាហារខ្លះពីកងទ័ពខ្មែរក្រហម ហើយកងទ័ពទាំងនោះបានឲ្យនំគ្រាប់ខ្លះមកខ្ញុំ ។ បន្ទាប់ពីដើរអស់រយៈពេលជាច្រើនសប្តាហ៍ ខ្ញុំបានទៅដល់ភូមិរបស់ម្តាយខ្ញុំ ។ ទន្ទឹមគ្នានោះដែរ ខ្ញុំបានឮដំណឹងថា ម្តាយរបស់ខ្ញុំបានព្យាយាមឆ្លងព្រំដែនទៅប្រទេសវៀតណាម ប៉ុន្តែត្រូវបានហាមឃាត់ ។ ប្រមាណបួនខែក្រោយមក ម្តាយរបស់ខ្ញុំបានត្រឡប់មកភូមិកំណើតរបស់គាត់ ។ ក្រុមគ្រួសាររបស់ខ្ញុំក៏បានជួបជុំគ្នាឡើងវិញ ។ បន្ទាប់មកក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅកាន់ខេត្តបាត់ដំបង ។ រយៈពេលប៉ុន្មានខែក្រោយមក ខ្ញុំបែកចេញពីក្រុមគ្រួសារដោយសារត្រូវទៅជីកប្រឡាយនៅក្នុងកងចល័តវ័យជំទង់ ។ ក្នុងអំឡុងពេលប្រហែលមួយឆ្នាំតាំងពីខ្ញុំចេញទៅកងចល័ត ខ្ញុំបានលួចរត់ទៅផ្ទះនៅពេលយប់ខ្លះដែរ ប៉ុន្តែក្រោយមកទៀត កងចល័តរបស់ខ្ញុំបានចេញទៅធ្វើការកាន់តែឆ្ងាយពីផ្ទះធ្វើឲ្យខ្ញុំមិនអាចលួចទៅលេងផ្ទះបានទៀតទេ ហើយខ្ញុំកាន់តែមានអារម្មណ៍កណ្តោចកណ្តែងជាងពេលណាៗទាំងអស់ ។

ក្នុងនាមជាក្មេងទីក្រុងម្នាក់ ខ្ញុំមិនមានជំនាញអ្វីដើម្បីរស់នៅក្នុងស្ថានភាពនាពេលនោះទេ ប៉ុន្តែការស្រេកឃ្លានអាហារបានបង្រៀនឲ្យខ្ញុំចេះជំនាញជាច្រើន ។ ខ្ញុំបង្រៀនខ្លួនឯងឲ្យចេះអុំទូកចេះហែលទឹកដើម្បីអាចមុជទៅកាច់ដើមអំពៅដែលដុះនៅក្នុងវាលស្រែដែលលិចទឹក ។ ខ្ញុំចេះលួចអាហារ ខ្ញុំចេះសម្លាប់សត្វពស់និងកណ្តុរដើម្បីបរិភោគ ព្រមទាំងចេះស្វែងរកស្លឹកឈើដែល

អាចបរិភោគបាននៅក្នុងព្រៃ ។

អាហារគឺជាព្រះនិងគឺជារបស់តែម្យ៉ាងគត់ដែលខ្ញុំចង់បានបំផុតនៅពេលនោះ ។ ខ្ញុំស្រមៃឃើញម្ហូបអាហារគ្រប់មុខ ហើយការស្រមៃនេះបានជួយឲ្យខ្ញុំដេកលក់និងផ្តល់ជាកម្លាំងចិត្តសម្រាប់ធ្វើការងារបន្តទៀតនៅថ្ងៃស្អែកនៅតាមវាលស្រែចម្ការ ។ សូម្បីតែសព្វថ្ងៃនេះក៏ដោយ ខ្ញុំមិនសប្បាយចិត្តទាល់តែសោះនៅពេលដែលខ្ញុំឃើញកុមារដែលមិនមានអាហារបរិភោគនៅតាមដងវិថី ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានកុមារទាំងនោះមិនមានអាហារបរិភោគគ្រប់គ្រាន់នៅពេលដែលយើងលែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យទៀតហើយនោះ ។

ដោយសារតែបញ្ហាអាហារនេះ ខ្ញុំមានការខឹងសម្បារយ៉ាងខ្លាំង ព្រមទាំងមានជម្លោះជាមួយប្រធានភូមិនិងប្រធានកង ។ ខ្ញុំត្រូវបានជួយស្រោចស្រង់ជីវិតដោយសារសន្តានចិត្តល្អរបស់មនុស្សជាច្រើន ។ នៅពេលដែលខ្ញុំត្រូវកងឈ្លបវាយធ្វើបាបនិងធ្វើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខឃុំ បុរសម្នាក់ដែលរស់នៅក្នុងភូមិជាមួយម្តាយរបស់ខ្ញុំបានទៅអង្វរប្រធានសន្តិសុខឲ្យដោះលែងខ្ញុំ ដោយនិយាយថា ខ្ញុំនៅក្មេងណាស់ ។ ប្រហែលពីរសប្តាហ៍ក្រោយមក ខ្ញុំត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ។ ក្រោយមកបុរសដែលជួយអង្វរឲ្យខ្ញុំបានរួចខ្លួនត្រូវខ្មែរក្រហមចោទថាមានសាច់ញាតិរស់នៅក្នុងតំបន់ខ្មាំង ។ តាំងពីពេលនោះមកគាត់បាត់ខ្លួនជារៀងរហូត ។ ប្រជាជនមូលដ្ឋានម្នាក់ទៀតឈ្មោះ ទូក បានផ្តល់អាហារដល់ក្រុមគ្រួសាររបស់ខ្ញុំនៅពេលដែលយើងកំពុងត្រូវការជាទីបំផុត ។

ភូមិដែលខ្ញុំរស់នៅក្នុងខេត្តបាត់ដំបងមានឈ្មោះថា ភូមិត្រពាំងវែង ។ ប្រធានភូមិចុងក្រោយមកពីភូមិភាគបស្ចិម ។ ប្រធានភូមិនេះមានឈ្មោះ មិត្តនារីអួន ដែលទើបតែមានអាយុប្រមាណ១២ឆ្នាំប៉ុណ្ណោះ ។ ម្តាយរបស់ខ្ញុំបានយកកន្ត្រៃស្អាតមួយមកពីប្រទេសចិនទៅឲ្យប្រធានភូមិ ហើយអង្វរកុំឲ្យបញ្ជូនខ្ញុំទៅធ្វើការនៅក្នុងកងចល័ត ។ ម្តាយរបស់ខ្ញុំស្រលាញ់កន្ត្រៃនេះណាស់ ដោយសារថាវាជាអំណោយរបស់ប្អូនប្រុសពៅគាត់ ប៉ុន្តែគាត់បានលះបង់កន្ត្រៃនោះដើម្បីខ្ញុំ ។ កន្ត្រៃនោះសង្គ្រោះខ្ញុំមិនបានប៉ុន្មានថ្ងៃផង អង្គការបានបញ្ជាឲ្យមិត្តនារី អួន បញ្ជូនខ្ញុំទៅធ្វើការក្នុងកងចល័តឆ្ងាយពីផ្ទះដដែល ។

នៅចុងឆ្នាំ១៩៧៨ ពាក្យចចាមអារ៉ាមបានចាប់ផ្តើមលេចឮសាយភាយពាសពេញភូមិអំពីចំនួនមនុស្សដែលបាត់បង់ជីវិតអស់ជាច្រើននាក់ (ភូមិត្រពាំងវែងពីមុនមាន១២០០គ្រួសារ ក្រោយមកនៅសល់ប្រហែលតែ១២គ្រួសារប៉ុណ្ណោះដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ) ។ ប្រជាជនចាប់ផ្តើមឆក់យកឱកាសដើម្បីរករស់តែរៀងៗខ្លួន ។ អ្នកមូលដ្ឋានម្នាក់បានប្រាប់ឪពុកមារបស់ខ្ញុំឲ្យរត់ទៅប្រទេសថៃ ព្រោះបើគាត់នៅតែ



បន្តរស់នៅក្នុងភូមិនោះ គាត់ប្រាកដជាស្លាប់មិនខាន ដោយសារថាគាត់ធ្លាប់ធ្វើការនៅធនាគារជាតិកម្ពុជា ។ បន្តិចក្រោយមកបងថ្លៃប្រុសរបស់ខ្ញុំបានចាកចេញពីភូមិដែរ ។ បន្ទាប់ពីធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលប៉ុន្មានថ្ងៃ គាត់បានត្រឡប់មកផ្ទះវិញដោយសារនឹករឭកប្រពន្ធរបស់គាត់ ។ ខ្ញុំត្រូវបានប្រាប់កុំឲ្យរត់គេចខ្លួន ។ ខ្ញុំបានយល់ស្រប ហើយការណ៍នេះប្រហែលជាបានជួយសង្គ្រោះជីវិតខ្ញុំមិនឲ្យជួបវាសនាដូចឪពុកមារបស់ខ្ញុំ ។ ឪពុកមារបស់ខ្ញុំបានធ្វើដំណើរទៅប្រទេសថៃ ហើយយើងមិន

ឃើញគាត់ត្រឡប់មកផ្ទះវិញរហូត ។ ខ្ញុំសង្ស័យថាគាត់មានគ្រោះថ្នាក់ដោយសារជាន់គ្រាប់មីនក៏មិនដឹង ។

សមាជិកគ្រួសាររបស់ខ្ញុំនិងអ្នកដទៃទៀតប្រហែលជាបានជួយសង្គ្រោះជីវិតរបស់ខ្ញុំច្រើនដង ។ អ្នកទាំងនេះជាអ្នកដែលមើលឃើញពីតម្លៃនៃជីវិត ហើយបានប្រឹងប្រែងអស់សមត្ថភាពរបស់ខ្លួនដើម្បីការពារភាពជាមនុស្សនៅក្នុងស្ថានភាពដែលពិបាកបែបនោះ ។ អ្នកទាំងនេះបានផ្តល់ឲ្យខ្ញុំនូវក្តីសង្ឃឹម ។

អ្នកសារពត៌មាននិងអ្នកដទៃទៀតក៏បានសាកសួរខ្ញុំថា



តើខ្ញុំនៅតែយល់សប្តិអាក្រក់អំពីព្រឹត្តិការណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ជីវិតរបស់ខ្ញុំនៅពេលនោះគឺជាសុបិនអាក្រក់មិនចេះចប់មិនចេះហើយ ប៉ុន្តែខ្ញុំមិនដែលយល់សប្តិអំពីរបបនោះទៀតទេ ។ ទោះជាយ៉ាងណាក៏ដោយ ម្តាយរបស់ខ្ញុំបានយល់សប្តិឃើញខ្ញុំ ។ គាត់យល់សប្តិឃើញថា ខ្ញុំកំពុងតែអង្គុយលើភ្នំព្រះនេត្រព្រះហើយសម្លឹងមើលទៅឆ្ងាយ ។ ម្តាយរបស់ខ្ញុំនិយាយថា នេះជាសញ្ញាបង្ហាញថាខ្ញុំនឹងរស់រានមានជីវិតនិងមានអនាគតខ្ពង់ខ្ពស់ ហើយការណ៍នេះបានធ្វើឲ្យខ្ញុំមានក្តីសង្ឃឹមក្នុងជីវិត ។

ដូច្នេះហើយ ខ្ញុំមិនដែលនឹកដល់សេចក្តីស្លាប់ទាល់តែសោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ផ្ទុយទៅវិញ ខ្ញុំតែងមានសង្ឃឹមថា ខ្ញុំប្រាកដជានឹងបានដេកលក់ស្កប់ស្កល់ហើយមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគនៅថ្ងៃណាមួយ ។ ក្តីសង្ឃឹមនេះស្ថិតនៅជាប់ជាមួយខ្ញុំជានិច្ច ហើយវាបានលើកទឹកចិត្តខ្ញុំឲ្យតស៊ូដើម្បីរស់ ។

កម្ពុជាប្រជាធិបតេយ្យបានកែប្រែជីវិតរបស់ខ្ញុំជារៀងរហូត ។ ភាពចាំបាច់ក្នុងការស្វែងរកចម្លើយទៅនឹងមូលហេតុដែលខ្ញុំត្រូវទទួលរងនូវក្តីឈឺចាប់ជាខ្លាំងនិងការបាត់បង់សមាជិកគ្រួសារអស់ជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានជំរុញឲ្យខ្ញុំសិក្សាស្រាវជ្រាវអំពីរបបនេះ ។ ខ្ញុំចង់ដឹងអំពីមូលហេតុនៃការស្លាប់របស់បងស្រីខ្ញុំ មូលហេតុដែលខ្ញុំត្រូវអង្គការឃុំឃាំង មូលហេតុដែលអង្គការធ្វើទារុណកម្មមកលើរូបខ្ញុំដោយគ្រាន់តែខ្ញុំបេះបន្លែយកទៅឲ្យបងស្រីដែលកំពុងតែមានផ្ទៃពោះនិងស្រេកឃ្លានអាហារ និងមូលហេតុដែលម្តាយរបស់ខ្ញុំមិនអាចជួយអ្វីខ្ញុំបាននៅពេលដែលខ្ញុំត្រូវឈ្លបធ្វើទារុណកម្ម ។ ខ្ញុំចង់ឲ្យមានការឆ្លើយតបសមរម្យមួយចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំធ្លាប់មានគំនិតចង់សងសឹកយ៉ាងខ្លាំង ។

ទោះបីជាខ្ញុំកំពុងតែស្វែងរកចម្លើយទៅនឹងមូលហេតុខាងលើក៏ដោយ ក៏អារម្មណ៍ចង់សងសឹករបស់ខ្ញុំចំពោះរបបកម្ពុជាប្រជាធិបតេយ្យនាពេលនោះបានរសាយអស់ទៅហើយ ។ ការត្រឡប់ទៅលេងផ្ទះចាស់របស់ខ្ញុំនៅទួលគោកបានជួយលួងលោមចិត្តរបស់ខ្ញុំ ដោយបានជួយឲ្យខ្ញុំនឹកឃើញឡើងវិញដល់ក្តីសង្ឃឹមចង់បានការអប់រំខ្ពស់កាលពីវ័យកុមារភាព ហើយវាក៏បានជួយធ្វើឲ្យការចងចាំអំពីមិត្តភក្តិនិងមនុស្សជាទីស្រលាញ់ដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅរស់រវើក ។ កាលពីក្មេង ខ្ញុំធ្លាប់ដាំដើមផ្កានៅផ្ទះរបស់ខ្ញុំដូចជា ផ្កាអ័រគីដេ ផ្កាផ្គរលាន់ ផ្កាក្រចកដៃ និងផ្កាអង្គារបុស្ស ។ ឥឡូវនេះ ខ្ញុំដាំដើមផ្កាដដែលនេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដើមផ្កាទាំងនេះបានរំឭកខ្ញុំអំពីកន្លែងដែលខ្ញុំធ្លាប់រស់នៅនិងអ្វីដែលខ្ញុំកំពុងតែបោះជំហានទៅមុខ ។ **ឆាំង យុ**

# សេចក្តីអំពាវនាវឱ្យមានការផ្តល់ឯកសារដល់អង្គជំនុំជម្រះវិសាមញ្ញ

រហូតមកដល់ថ្ងៃ១៧មេសា២០០៥នេះដែលជាថ្ងៃគម្រប់ខួបទី៣០នៃការឡើងកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជានៅតែមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមធ្វើការអំពាវនាវដល់ប្រទេសនានា អង្គការ និងបុគ្គលទាំងអស់ ឲ្យជួយដល់ប្រទេសកម្ពុជាក្នុងការស្វែងរកយុត្តិធម៌តាមរយៈការផ្តល់ជាឯកសារនិងសម្ភារដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យជូនអង្គជំនុំជម្រះវិសាមញ្ញ ដែលនឹងត្រូវបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សម្ភារទាំងនេះអាចជាឯកសារសក្ខីភាព និងសម្ភារដទៃទៀតដូចជា រូបថត (កាសែ្សតថតសំឡេង ឬឧបករណ៍សំឡេងផ្សេងៗ) ក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ជាងនេះទៅទៀត យើងកំពុងតែស្វែងរកការប្រគល់មកវិញនូវខ្សែភាពយន្តដែលត្រូវបានថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពត៌មានទាំងនេះជាការរួមចំណែកដល់ការស្វែងរកយុត្តិធម៌និងការពិតសម្រាប់ប្រជាជនកម្ពុជាតាមរយៈការពង្រីកនិងបង្កើនឯកសារដែលនឹងត្រូវប្រើប្រាស់ជាភស្តុតាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

ប្រទេសមួយចំនួនមានស្ថានទូតនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចំណែកឯប្រទេសខ្លះទៀតបានតាមដានព្រឹត្តិការណ៍នៅក្នុងប្រទេសកម្ពុជាពីស្ថានទូតរបស់ខ្លួននៅប្រទេសថៃ ចិន វៀតណាម ឬប្រទេសឡាវ ។ យើងសង្ឃឹមយ៉ាងមុតមាំថា ប្រទេសទាំងនោះនឹងចាប់ផ្តើមស្រាវជ្រាវនៅក្នុងបណ្ណសារដ្ឋានការទូត យោធា និងភ្នាក់ងារសម្ងាត់ (រួមទាំងទូរលេខ) របស់ខ្លួន ដើម្បីស្វែងរកឯកសារនិងសម្ភារដែលមានប្រយោជន៍សម្រាប់បង្កើតឲ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ជាប្រវត្តិសាស្រ្តយ៉ាងពេញលេញមួយចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ។ យើងសង្ឃឹមថា ប្រទេសទាំងនេះនឹងបញ្ជូនឯកសារនិងសម្ភារដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ ទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងអនុញ្ញាតឲ្យសាធារណជនប្រើប្រាស់ឯកសារទាំងនេះ ។

យើងក៏សង្ឃឹមដែរថា អ្នកសារពត៌មាន អ្នកស្រាវជ្រាវ និងបុគ្គលដទៃទៀត ដែលមានឯកសារនិងសម្ភារដែលពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ នឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញនិងសាធារណជនបានប្រើប្រាស់ឯកសារទាំងនោះដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមថ្លែងអំណរគុណចំពោះបណ្ឌិតស៊ីវ ហេដ័រ នៃសាកលវិទ្យាល័យក្រុងឡុងដ៍ និងលោក ដេវីដ ហកអតីតមន្រ្តីទទួលបន្ទុកកិច្ចការកម្ពុជានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលបានផ្តល់ឲ្យយើងនូវឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានសារប្រយោជន៍សម្រាប់ប្រើប្រាស់នៅក្នុងសាលាជំនុំជម្រះក្តីមួយដែលយើងរំពឹងថាប្រាកដជានឹងត្រូវបានបង្កើតឡើងសម្រាប់កាត់សេចក្តីមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងមានសុទិដ្ឋិនិយមថាអ្នកដទៃទៀតនឹងដើរតាមគំរូរបស់អ្នកទាំងពីរនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលស្គាល់ថាមនុស្សទាំងឡាយមានការព្រួយបារម្ភអំពីសិទ្ធិក្នុងការថែរក្សាភាពជាអាថ៌កំបាំងរបស់ឯកសារខ្លះ ប៉ុន្តែយើងជឿជាក់ថា ប្រាកដជារកឃើញដំណោះស្រាយសម្រាប់បញ្ហានេះជាមិនខាន ។

ពេលវេលាមានសារសំខាន់ខ្លាំងណាស់ ។ ប្រទេសទាំងឡាយគួរតែចាប់ផ្តើមប្រមូលនិងបញ្ចេញឯកសារដែលពាក់ព័ន្ធដើម្បីផ្តល់ភាពងាយស្រួលដល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ តាមរយៈការធ្វើដូច្នេះ អ្នកទាំងឡាយដែលកាន់កាប់ឯកសារដ៏មានតម្លៃទាំងនេះអាចរួមចំណែកក្នុងការធានាថាអង្គជំនុំជម្រះវិសាមញ្ញជាដំណើរការតាមផ្លូវច្បាប់មួយដែលល្អិតល្អន់និងមានយុត្តិធម៌ ។ **ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# អតីតលេខាទូតកម្ពុជាប្រចាំទីក្រុងបែលក្រាដ

គាន់ ឆៃហេង ជាអតីតលេខាទូតកម្ពុជាប្រចាំទីក្រុងបែលក្រាដប្រទេសយូហ្គោស្លាវី ។ ឆៃហេង រៀនចប់ផ្នែកបច្ចេកទេសអគ្គីសនីនៅសហភាពសូវៀត និងធ្វើជាលេខាស្ថានទូតរបស់រណសិរ្សរួបរួមជាតិកម្ពុជាប្រចាំទីក្រុងបែលក្រាដពីខែ៨ ឆ្នាំ១៩៧០ ដល់ខែ៥ ឆ្នាំ១៩៧៧ ។ ឆៃហេង បានត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៤ ខែ៥ ឆ្នាំ១៩៧៧ តាមការហៅរបស់អង្គការ ហើយនៅថ្ងៃទី១៦ ខែ៥ ឆ្នាំ១៩៧៧ គាត់ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ សួរចម្លើយ និងសម្លាប់ចោល ។

គាន់ ឆៃហេង កើតនៅភូមិបល្ល័ង្ក ឃុំស្រយូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ឆ្នាំ១៩៦០ ឆៃហេង រៀនដល់ថ្នាក់ទី៣ (ថ្នាក់ទី១០បច្ចុប្បន្ន) នៅអនុវិទ្យាល័យកំពង់ធំ ហើយក៏ផ្លាស់មករៀននៅខេត្តកំពង់ចាមនិងបញ្ចប់ការសិក្សាត្រឹមថ្នាក់ឧត្តមនៅវិទ្យាល័យកំពង់ចាម ។

នៅឆ្នាំ១៩៦៣ ឆៃហេង និងនិស្សិត៥នាក់មានឈ្មោះ គឹកឆាយអៀមជួ, ទីយ៉ាវ, ច័ន្ទមីន, គ្រិនលាន និង ហាយ គឹមស៊ាន បានទទួលអាហារូបករណ៍របស់ក្រសួងសិក្សាធិការជាតិទៅសិក្សាផ្នែកបច្ចេកទេសនៅសហភាពសូវៀត ។ ឆៃហេង ធ្វើដំណើរទៅដល់ទីក្រុងមូស្គូនៅខែ៩ ។ និស្សិតទាំង៦នាក់ត្រូវរៀនភាសារុស្ស៊ីនៅសាលាសែមហ្គូរយៈពេលមួយឆ្នាំ ។ គ្រូបង្រៀនឈ្មោះ វ៉ាស៊ីលាវណា ។ ក្រៅពីបង្រៀនភាសារុស្ស៊ី វ៉ាស៊ីលាវណា បានអូសទាញ ឆៃហេង ឲ្យចូលចិត្តសង្គមនិយមសូវៀត ។ នៅខែ១០ ឆ្នាំ១៩៦៤ ឆៃហេង ចូលរៀននៅសាលាបច្ចេកទេសអគ្គីសនី ។ នៅក្នុងសាលាបច្ចេកទេសអគ្គិសនីមាននិស្សិតខ្មែរពីរនាក់ទៀតឈ្មោះ ហាក់ សៀងឡាយនី និង ជ័យ រ៉េត ដែលតែងតែណែនាំ ឆៃហេង ឲ្យចូលចិត្តសង្គមនិយមសូវៀត ។ ជ័យ រ៉េត ណែនាំ ឆៃហេង, គ្រិន លាន និង ហាយ គឹមស៊ាន ឲ្យស្គាល់ វ៉ាស៊ីលាវិច ណាឌាសឌីន ចាងហ្វាងការិយាល័យទំនាក់ទំនងនិស្សិតបរទេស ។

វ៉ាស៊ីលាវិច អប់រំ ឆៃហេង អំពីកា.ហ្សេ.បេ និងប្រាប់ឲ្យ ឆៃហេង ទាក់ទាញនិស្សិតខ្មែរឲ្យចូលកា.ហ្សេ.បេ ។ នៅខែ៥ ឆ្នាំ១៩៦៥ ឆៃហេង បានចូលជាសមាជិកកា.ហ្សេ.បេដោយមានការទទួលស្គាល់ពីឈ្មោះ ញ៉ៀវ ជាចាងហ្វាងការិយាល័យទំនាក់ទំនងនិស្សិតនៃក្រសួងសិក្សាធិការសូវៀត ។

ពីឆ្នាំ១៩៦៥ដល់១៩៦៧ ឆៃហេង បកប្រែអត្ថបទស្តីពីសង្គមនិយមសូវៀតពីភាសារុស្ស៊ីមកជាភាសាខ្មែរ ហើយអានថតដាក់កាសែ្សតចាក់ផ្សាយតាមវិទ្យុម៉ូស្គូ២ដងក្នុងមួយសប្តាហ៍ ។ នៅខែ៦ ហាក់ សៀងឡាយនី និង ជ័យ រ៉េត បញ្ចុះបញ្ចូល ឆៃហេង, គ្រិន លាន និង ហាយ គឹមស៊ាន តាមរយៈសៀវភៅ «គោលការណ៍ម៉ាក្ស-លេនីន» និងណែនាំឲ្យស្គាល់និស្សិតខ្មែរប្រហែល១០នាក់ទៀតដើម្បីបង្កើតក្រុម«ខ្មែរម៉ាក្ស-លេនីន» ឬក្រុមខ្មែរកុម្មុយនិស្តនៅសហភាពសូវៀត និងឈានទៅបង្កើតបក្សកុម្មុយនិស្តខ្មែរទៅថ្ងៃមុខ ។

នៅឆ្នាំ១៩៦៦ ក្រុមនិស្សិតនៅសហភាពសូវៀតបានបង្កើតសមាគមនិស្សិតមួយហើយដាក់ឈ្មោះថា សហភាពខេមរនិស្សិត និងបានជ្រើសរើស ឆៃហេង ឲ្យធ្វើជាអនុប្រធានសមាគមនេះ ។ នៅឆ្នាំ១៩៦៧ ឆៃហេង ជាប់ឆ្នោតជាប្រធានសមាគម ។ នៅឆ្នាំ១៩៦៨ ឆៃហេង ញុះញង់និស្សិតខ្មែរឲ្យប្រឆាំងនឹងប្រទេសចិន ។ ស្របពេលដែលប្រទេសចិនកំពុងតែធ្វើបដិវត្តន៍វប្បធម៌ ឆៃហេង ឃោសនាថា ប្រទេសចិនចង់ត្រួតត្រាប្រទេសតូចដូចជាកម្ពុជា ចំណែកសូវៀតតែងតែជួយជ្រោមជ្រែងកម្ពុជា ។

នៅចុងឆ្នាំ១៩៦៨ គាន់ ឆៃហេង រួមជាមួយ ហាក់ សៀងឡាយនី និង គ្រិន លាន បានចូលរួមពិធីមហាប្រជុំយុវជននិស្សិតសកលលោកនៅទីក្រុងសូហ្វីយ៉ា ប្រទេសបុលហ្គារី ក្នុងគោលបំណងពង្រីកមិត្តភាពរវាងយុវជនសកលលោក និងបំផុសសាមគ្គីភាពជាមួយយុវជនវៀតណាមដើម្បីប្រឆាំងនឹង

ចក្រពត្តិអាមេរិក ។

ដើមឆ្នាំ១៩៦៩ ឆែ ហេង សរសេរសំបុត្រទាក់ទងជាមួយនិស្សិតខ្មែរបីនាក់ គឺ សៀង ហ្វឡុង និង សិត ប៉េងហួរ នៅប្រទេសអាល្លឺម៉ង់ និងឈ្មោះ ប៊ូ ឃិន នៅប្រទេសឆេកូស្លូវ៉ាគី ដើម្បីសុំគម្រោងការបង្កើតសហព័ន្ធសមាគមនិស្សិតខ្មែរនៅបរទេស ។

ហាក់ សៀងឡាយនី បានហៅនិស្សិតខ្មែរទៅជួបប្រជុំនៅបន្ទប់របស់ គ្រិន លាន (នៅសាលាបច្ចេកទេសអគ្គិសនី) នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧០ ដើម្បីបញ្ជូនកម្លាំងចូលធ្វើការនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ។ នៅល្ងាចថ្ងៃដដែល ឆែ ហេង ផ្ញើទូរលេខមួយថ្វាយសម្តេច សីហនុ នៅទីក្រុងប៉េកាំងដើម្បីសុំចូលជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា ។

នៅខែ៤ ឆ្នាំ១៩៧០ ជា សាន ដែលជាឯកអគ្គរាជទូតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំទីក្រុងមូស្គូ បានប្រកាសបង្កើតអង្គការយុវជនរណសិរ្សរួបរួមជាតិកម្ពុជាដោយជ្រើសរើស ឆែ ហេង ធ្វើជាប្រធានអង្គការនេះ ។

នៅដើមខែ៦ ឆ្នាំដដែល នៅពេលដែលរណសិរ្សរួបជាតិកម្ពុជាអំពាវនាវឲ្យនិស្សិតខ្មែរនៅបរទេសទៅធ្វើការនៅទីក្រុងប៉េកាំង និងស្នើឲ្យគ្រប់ស្ថានទូតកម្ពុជានៅបរទេសផ្តាច់ចំណងទាក់ទងជាមួយរដ្ឋាភិបាលលន់ណុល ឆែ ហេង ក៏ស្ម័គ្រចិត្តទៅធ្វើការនៅទីក្រុងប៉េកាំង ។ មុនពេលចេញដំណើរ វ៉ាស៊ីលាវិច ផ្តាំផ្ញើឲ្យ ឆែ ហេង ផ្តល់ព័ត៌មានឲ្យគាត់អំពីស្ថានការណ៍ទាំងអស់នៅទីក្រុងប៉េកាំង ។

ខែ៨ ឆែ ហេង និង ថាច់ សួង ត្រូវបានរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាតែងតាំងជាលេខាស្ថានទូតកម្ពុជាប្រចាំទីក្រុងបែលក្រាដ ប្រទេសយូហ្គោស្លាវី ដែលមាន ហួត សម្បត្តិ ជាឯកអគ្គរាជទូត ។ ខែ៩ ឆែ ហេង បានធ្វើដំណើរទៅដល់ទីក្រុងបែលក្រាដ ។ ចុងខែ១២ ឆែ ហេង រួមដំណើរទស្សនកិច្ចជាមួយ ហួត សម្បត្តិ ទៅទីក្រុងទីរ៉ាណា ប្រទេសអាល់បានី ។

ចុងឆ្នាំ១៩៧១ ឆែ ហេង ណែនាំនិស្សិតខ្មែរប្រហែល៣០នាក់ឲ្យចូលធ្វើការនៅរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង ។ ពាក់កណ្តាលឆ្នាំ១៩៧២ ឆែ ហេង បានទទួលគណៈប្រតិភូមួយដែលដឹកនាំដោយសម្តេច សីហនុ អមដំណើរដោយ អៀង សារី មកធ្វើទស្សនកិច្ចនៅប្រទេសយូហ្គោស្លាវី ។ ក្នុងឱកាសនោះ ឆែ ហេង បានជួបនិងស្គាល់ អូឌិនសូវ លេខាស្ថានទូតសូវៀតប្រចាំទីក្រុងបែលក្រាដ ។

ចុងឆ្នាំ១៩៧២ ដោយអស់អាណត្តិធ្វើជាឯកអគ្គរដ្ឋទូតសូវៀតនៅប្រទេសយូហ្គោស្លាវី អូឌិនសូវ បានណែនាំឲ្យ ឆែ ហេង ស្គាល់លេខាថ្មីគឺ បុនដាឈុក ។

នៅដើមឆ្នាំ១៩៧៣ អ្នកដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជាអនុញ្ញាតឲ្យសមាជិកនៅក្រៅប្រទេសចូលទៅតំបន់រំដោះនៃប្រទេសកម្ពុជា ។ ឆែ ហេង បានដាក់សំណើសុំចូលមកក្នុងប្រទេសកម្ពុជាដែរ ប៉ុន្តែត្រូវបានបដិសេធដោយសារគាត់មានប្រពន្ធជាជនជាតិសូវៀត ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ គណៈប្រតិភូដែលដឹកនាំដោយ ខៀវ សំផន និង អៀង សារី បានទៅធ្វើទស្សនកិច្ចនៅប្រទេសយូហ្គោស្លាវី ហើយបានឆៀងទៅទស្សនារោងចក្រផលិតអាវុធរបស់ប្រទេសនេះ ។

នៅខែ៦ ឆ្នាំ១៩៧៥ ឆែ ហេង ដាក់សំណើសុំចូលប្រទេសកម្ពុជាជាលើកទីពីរ ប៉ុន្តែនៅតែមិនបានសម្រេច ។ នៅខែ៨ ឆែ ហេង និង អ៊ិក អ៊ាមហេង ចូលរួមបោះជំរំសម្រាកដែលរៀបចំដោយគណៈកម្មាធិការរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំង ។ គាត់បានជួបជាមួយ មុនី និង ឈឺវ អតីតវេជ្ជបណ្ឌិតនៅទីក្រុងភ្នំពេញ ហើយណែនាំឲ្យអ្នកទាំងពីរចូលតំបន់រំដោះ ។ នៅពេលត្រឡប់មកពីបោះជំរំវិញ ឆែ ហេង រាយការណ៍ប្រាប់ បុកដាឈុន និង កាសាកូវ កុងស៊ុលសូវៀតប្រចាំប្រទេសយូហ្គោស្លាវី អំពីសេចក្តីថ្លែងការណ៍របស់ អៀង សារី ថាប្រទេសកម្ពុជាមានអង្គការបដិវត្តន៍ជាអ្នកដឹកនាំ ហើយគ្មានកម្មសិទ្ធិឯកជនឡើយ ។ កាសាកូវ ណែនាំឲ្យ ឆែ ហេង ប្រមូលព័ត៌មានអំពីកម្ពុជាឲ្យបានច្រើន ។

ខែ២ ឆ្នាំ១៩៧៦ ឆែ ហេង បានបកប្រែរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យពីភាសាខ្មែរទៅជាភាសារុស្ស៊ីឲ្យ កាសាកូវ ។ នៅខែ៤ឆ្នាំដដែល ថាច់ សួង បានទទួលការអនុញ្ញាតឲ្យចូលប្រទេសកម្ពុជា ។ នៅពាក់កណ្តាលខែ៦ យុគ ចន្ទា លេខាស្ថានទូតកម្ពុជាប្រចាំប្រទេសតង់សានី និង កុក ហួរ លេខាស្ថានទូតកម្ពុជា

ប្រចាំប្រទេសម៉ូរីតានី ក៏បានទទួលការអនុញ្ញាតចូលប្រទេសកម្ពុជាដែរ ។ ខែ៤ ឆ្នាំ១៩៧៧ ឆៃ ហេង បានទទួលលិខិតមួយច្បាប់ពី ពេជ ជាង អគ្គរដ្ឋទូតរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំទីក្រុងប៉េកាំង អនុញ្ញាតឲ្យគាត់វិលត្រឡប់ចូលប្រទេសកម្ពុជាវិញ ។ មុនពេលចេញដំណើរមកប្រទេសកម្ពុជា កាសាកូវ បានប្រគល់ភារកិច្ចមួយចំនួនដល់ ឆៃ ហេង និងណែនាំអំពីរបៀបឃោសនាកសាងកម្លាំងតស៊ូនៅប្រទេសកម្ពុជា ជាពិសេសគឺការបើកស្ថានទូតរុស្ស៊ីនៅទីក្រុងភ្នំពេញឡើងវិញ ។ ឆៃ ហេង សំណូមពរឲ្យ កាសាកូវ ផ្តល់ការងារនិងផ្ទះសម្បែងដល់ប្រពន្ធនិងកូនរបស់គាត់នៅទីក្រុងមូស្គូផង ។

ឆៃ ហេង ចាកចេញពីទីក្រុងបែលក្រាដនៅថ្ងៃទី៧ ខែ៥ ឆ្នាំ១៩៧៧ ហើយមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៤ ខែ៥ ឆ្នាំ១៩៧៧ ។ អង្គការបញ្ជូនគាត់ទៅស្នាក់នៅមន្ទីរមួយដែលគាត់មិនស្គាល់ឈ្មោះនិងទីកន្លែងអស់រយៈពេល២ថ្ងៃ ។ ថ្ងៃទី១៦ ខែ៥ ឆ្នាំ១៩៧៧ អង្គការបញ្ជូន ឆៃ ហេង ទៅដាក់នៅមន្ទីរឃុំឃាំង ស-២១ ។

នៅមន្ទីរ ស-២១ ឆៃ ហេង បានឆ្លើយសារភាពអំពីសកម្មភាពរបស់គាត់នៅទីក្រុងភ្នំពេញនិងនៅបរទេស ។ អត្ថបទចម្លើយសារភាពរបស់គាត់មានចំនួន៥៩ទំព័រ ។ អ្នកសួរចម្លើយ ឆៃ ហេង ឈ្មោះ មាក ។ យោងតាមបញ្ជីឈ្មោះអ្នកទោសដែលកម្ទេចនៅមន្ទីរស-២១ គាន់ ឆៃ ហេង ត្រូវអង្គការកម្ទេចនៅថ្ងៃទី២០ ខែ៧ ឆ្នាំ១៩៧៧ ។ **សូ ហ្វារីណា**

## សេចក្តីប្រកាសរកបងប្រុសពីរនាក់


ថោង សុវណ្ណផល្លា

នាងខ្ញុំឈ្មោះ ថោង សុវណ្ណ ផល្លា ឪពុកឈ្មោះ ថោង ប៉ូ ម្តាយ ឈ្មោះ សំ សារិន ។ នាងខ្ញុំមានបងប្អូន៤នាក់ៈ ទី១) បងប្រុស (មិនចាំឈ្មោះ), ទី២ ពៅ (ប្រុស ទី៣) រូបខ្ញុំ និង ទី៤) ថោង សុវណ្ណផល្លី (ស្លាប់) ។ នាងខ្ញុំសូមសួររកបងប្រុសទី១ និងទី២ ដែលបានបែកគ្នាកាលពីជំនាន់ប៉ុលពត ។ មុនឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំមានទីលំនៅក្នុងទីក្រុងភ្នំពេញមុំទួលគោក ។ ឆ្នាំ១៩៧០ ក្រុមគ្រួសាររបស់នាងខ្ញុំផ្លាស់ទីលំនៅមកខេត្តកំពង់ចាម ស្នាក់នៅភូមិមេម៉ាយ ។ ចំណែកបងប្រុសទីមួយធ្វើការនៅភ្នំពេញ ។

ឆ្នាំ១៩៧៥ ប៉ុលពត បានជម្លៀសក្រុមគ្រួសារនាងខ្ញុំទៅនៅស្រុកចំការលើនៅភូមិខ្វាកោណ ជាប់ព្រំប្រទល់ភូមិស្ពោ ។ រស់នៅទីនោះបានរយៈពេលបីខែ ឪពុកម្តាយនិងប្អូនស្រីបានស្លាប់ដោយសារជំងឺគ្រុនចាញ់ ។ ក្រោយមកនាងខ្ញុំបានបែកពីបងប្រុសទីពីរក្នុងពេលជម្លៀសទៅភូមិបន្តទៀត ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋាននៅភូមិត្នោតជុំ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ឬតាមទូរស័ព្ទលេខ ០១២ ៥២៧ ២៣៩ ដោយអនុគ្រោះ ។ សូមអរគុណ ។

## ដំណឹងសួររកប្អូនប្រុស

នាងខ្ញុំឈ្មោះ ដាន់ ដុន អាយុ៦៥ឆ្នាំ និង ប្តីឈ្មោះ ដៀវ ទិត អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិចុងកោះថ្មី ឃុំកោះធំ(ក) ស្រុកកោះធំ ខេត្តកណ្តាល ។ សូមសួរប្អូនប្រុសឈ្មោះ ដាន់ ញ៉ាញ់ ដែលត្រូវប្រធានភូមិចុងកោះថ្មីឈ្មោះ ទិត ចុចឈ្មោះឲ្យធ្វើជាកងទ័ពខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៦ ។ ចាប់តាំងពី ញ៉ាញ់ ចេញពីផ្ទះទៅធ្វើកងទ័ពខ្មែរក្រហម ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។ នៅអំឡុង១៩៩០ កងទ័ពម្នាក់រស់នៅភូមិចុងកោះថ្មីបាននិយាយប្រាប់នាងខ្ញុំថា គាត់ធ្លាប់ធ្វើការជាមួយ ញ៉ាញ់ នៅអំឡុងឆ្នាំ១៩៧៦ដល់១៩៧៩ ហើយក្រោយឆ្នាំ១៩៧៩ គាត់ធ្លាប់ជួប ញ៉ាញ់ ម្តងនៅលើភ្នំអន្លង់វែង ។

ប្រសិនបើប្អូនប្រុសបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានទទួលដំណឹងអំពីឈ្មោះ ដាន់ ញ៉ាញ់ សូមទាក់ទងមកនាងខ្ញុំតាមអាសយដ្ឋានដូចបានជម្រាបខាងលើ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

## សារាចរណែនាំស្តីពីការថែរក្សារៀបចំទុកដាក់អដ្ឋិធាតុប្រជាជនរងគ្រោះ ដោយអំពើប្រល័យពូជសាសន៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការរៀបចំតំបន់អន្លង់វែងឱ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ

ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ភ្លាម ទឹកដីកម្ពុជាទាំងមូលមានរណ្តៅសាកសពរួមជាច្រើនកន្លែងដែលរបបប្រល័យពូជសាសន៍ប៉ុលពតបានបន្សល់ទុកជាវត្ថុតាងនៃឧក្រិដ្ឋកម្មមកលើប្រជាជនស្លូតត្រង់ ។ ភ្លាមនោះ អាជ្ញាធរនិងប្រជាពលរដ្ឋបានខិតខំយកអដ្ឋិធាតុរបស់ជនរងគ្រោះមកថែរក្សាតម្កល់ទុកបានគត់មត់ល្អ កន្លែងខ្លះបានធ្វើស្តូបនិងបានធ្វើកន្លែងតម្កល់ទុកដាក់ជាបូជនីយដ្ឋានបានសមរម្យ ។ ប៉ុន្តែរហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅកន្លែងដែលបានតម្កល់ទុកអដ្ឋិធាតុពីមុនពុំទាន់បានយកចិត្តទុកដាក់ថែរក្សាឲ្យបានល្អជាប្រចាំនៅឡើយ ។

ដើម្បីថែរក្សាទុកអដ្ឋិធាតុជាភ័ស្តុតាងនៃឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រសម្រាប់ជាមូលដ្ឋានរំឭកដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ពិសេសដល់វ័យជំនាន់ក្រោយឲ្យចងចាំជានិច្ចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់ខ្លោចផ្សានិងជូរចត់បំផុតដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តមកលើប្រជាជននិងទឹកដីមាតុភូមិកម្ពុជាកាលពីឆ្នាំ១៩៧៥-១៩៧៨អស់រយៈកាល៣ឆ្នាំ ៨ខែ និង២០ថ្ងៃនេះ ជាពិសេសការរៀបចំរក្សាតំបន់អន្លង់វែងសម្រាប់ធ្វើជាសារមន្ទីរប្រវត្តិសាស្ត្រជូនដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិនាពេលអនាគតរាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ៖

១) អាជ្ញាធរដែនដីខេត្តក្រុងទាំងអស់សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធនៅជុំវិញខេត្តក្រុង ត្រូវត្រួតពិនិត្យជួសជុលនិងថែរក្សាឡើងវិញឲ្យបានល្អនូវកន្លែងតម្កល់អដ្ឋិធាតុទាំងឡាយដែលបានធ្វើកន្លងមកហើយ ត្រួតពិនិត្យស្រាវជ្រាវនូវរណ្តៅដែលនៅសេសសល់ដើម្បីរៀបចំកន្លែងទាំងអស់នេះឲ្យទៅជាបូជនីយដ្ឋានដែលមានរបងហ៊ុមព័ទ្ធ មានដាំដើមឈើនិងដាក់ផ្លាកសញ្ញាពត៌មានប្រវត្តិសាស្ត្រឲ្យបានល្អដើម្បីបង្ហាញជូនដល់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរ ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងទេសចរណ៍ត្រូវធ្វើការណែនាំបន្ថែមអំពីផ្នែកបច្ចេកទេសហើយត្រូវចាត់តាំងមន្ត្រីជំនាញក្រោមឱវាទឲ្យចុះសហការជាមួយអាជ្ញាធរដែនដីក្នុងកិច្ចការនេះ ។

២) ដោយឡែកនៅតំបន់អន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាតំបន់ប្រវត្តិសាស្ត្រនៃជីវិតនយោបាយចុងក្រោយរបស់មេដឹកនាំនិងអគ្គការចាត់តាំងខាងយោធារបស់ខ្មែរក្រហមប៉ុលពត ក្រសួងទេសចរណ៍ត្រូវខិតខំអនុវត្តដូចដែលរាជរដ្ឋាភិបាលបានណែនាំកន្លងមក ដោយត្រូវសហការណ៍ជាមួយអាជ្ញាធរដែនដី ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់យោធភូមិភាគទី៤ មជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា (CMAC) និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការបោសសម្អាតមីនរៀបចំប្លង់មេឲ្យបានត្រឹមត្រូវ ស្រាវជ្រាវឯកសាររៀបចំជាសារមន្ទីរប្រវត្តិសាស្ត្រ ដោយខិតខំស្វែងរកគ្រប់ប្រភពថវិកាជំនួយដើម្បីធ្វើការរៀបចំនូវភ័ស្តុតាងប្រវត្តិសាស្ត្រទាំងអស់ និងសម្រាប់កសាងរៀបចំតំបន់នោះឲ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយរបស់ប្រទេសជាតិ ។

ហាមឃាត់ដាច់ខាតនូវការរំលោភយកដីធ្លីនិងការបែងចែកដីធ្លីបែបអនាធិបតេយ្យឬការសាងសង់សំណង់ណាមួយនៅតំបន់អន្លង់វែងដែលធ្វើឲ្យមានការប៉ះពាល់ដល់តំបន់ប្រវត្តិសាស្ត្រនេះដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល លើកលែងតែការសាងសង់លំនៅឋានរបស់ប្រជាពលរដ្ឋនៅក្នុងភូមិឃុំនោះដែលត្រូវបានអនុញ្ញាតស្របតាមការកំណត់របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ។

៣) ត្រូវយកចិត្តទុកដាក់ខិតខំអនុវត្តកិច្ចការទាំងអស់ខាងលើឲ្យបានមុនថ្ងៃ៧មករា ឆ្នាំ២០០២នេះ ដែលជាខួបលើកទី២៣នៃថ្ងៃផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន:** ◆ ក្រសួងព្រះបរមរាជវាំង ◆ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ◆ អគ្គលេខាធិការដ្ឋានរដ្ឋសភា ◆ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ◆ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ◆ ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ◆ សាលាខេត្ត-ក្រុង ◆ កាលប្បវត្តិ-ឯកសារ ។

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ




យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជា-ធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញ ឬទាក់ទងតាមអ៊ីមែល *truthwynne@dccam.org* ឬ *truthpivoine@dccam.org* ។

សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៩៥៦ | ពុត លីង ហៅ មឿន | យុទ្ធជន | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥៧ | ហ៊ុន ហ៊ាង | យុទ្ធជនពេទ្យ | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥៨ | សុក នីម ហៅ នី (ស្រី) | ប្រពន្ធ សុវណ្ណ | មន្ទីរការពារ | ១៣-៣-៧៧ | ២៣-៣-៧៧ |
| ១៩៥៩ | ហាក់ ចាំ | សមាជិកកងហ | ស-២១យ | ៣-៣-៧៧ | ២៣-៣-៧៧ |
| ១៩៦០ | អ៊ឹម រុន | ប្រធានកងហ | ស-២១យ | ៣-៣-៧៧ | ២៣-៣-៧៧ |
| ១៩៦១ | អ៊ុយ សឿង | សេដ្ឋកិច្ច | ស-២១យ | ២-៣-៧៧ | ២៣-៣-៧៧ |
| ១៩៦២ | ប៉ាត សន ហៅ រិន | យុទ្ធជន | ស-២១យ | ៤-៣-៧៧ | ២៣-៣-៧៧ |
| ១៩៦៣ | យិន ង៉ែត | យុទ្ធជន | ស-២១យ | ៥-២-៧៧ | ២៣-៣-៧៧ |
| ១៩៦៤ | ឌី វ៉ែន | កងហ១២ | ស-២១យ | ១២-២-៧៧ | ២៣-៣-៧៧ |
| ១៩៦៥ | ដៃ ធី ហៅ ឆាំ | យុទ្ធជន១៣ | ស-២១យ | ៩-៣-៧៧ | ២៣-៣-៧៧ |
| ១៩៦៦ | យុត រុន | យុទ្ធជន | កងពល៧០៣ | ១៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៦៧ | ង៉ូវ ទ្រី | កម្មករចាស់ | មន្ទីរ ស-៨ | ១៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៦៨ | ខៀវ ឯម | កម្មករ | មន្ទីរ ក-២៧ | ? | ២៣-៣-៧៧ |
| ១៩៦៩ | ស្រី ជីម ហៅ ឃ្លាំង | សមាជិកមន្ទីរ | ដឹកដើងគោក | ? | ២៣-៣-៧៧ |
| ១៩៧០ | ទន់ ប៊ុនហុង | កម្មករ | អគ្គិសនីទី១ | ? | ២៣-៣-៧៧ |
| ១៩៧១ | អេត ហុង | កម្មករ | រោងចក្រ ដ-១ | ? | ២៣-៣-៧៧ |
| ១៩៧២ | ហុក ស៊ុយ ហៅ រី | អនុក្រុម | ថាមពល | ? | ២៣-៣-៧៧ |
| ១៩៧៣ | អ៊ុំ សារិន ហៅ ប៊ិល | យុទ្ធជន | ពាណិជ្ជកម្ម | ? | ២៣-៣-៧៧ |
| ១៩៧៤ | ម៉ែន ទិដ្ឋភាព ហៅ ចាន់ណា | យុទ្ធជន | កងចល័តស្រុក | ? | ២៣-៣-៧៧ |
| ១៩៧៥ | ប៊ុត ហឿន ហៅ យីវ គឹមយ៉ុង | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៧៦ | ហម កាំង | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៧៧ | ដាប់ ឡាយ | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៧៨ | នាត នី ហៅ វ៉ែន | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៧៩ | យស់ វីកា ហៅ វី | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨០ | អោ អេង ហៅ ភក្តិ | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨១ | សេក ម៉ៅ | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨២ | ហោ ទ្រី | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៩៨៣ | មុី ចយ | យុទ្ធជន | ស-២១យ | ២៤-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៤ | ញ៉ឹក យ៉េង ហៅ វ៉ុន (ស្រី) | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៥ | ស៊ិន ភាន់ (ស្រី) | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៦ | ម៉ក ង៉ែត ហៅ សារឿន (ស្រី) | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៧ | ទេព អឿន | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៨ | លី ឈន ហៅ ធឿន | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៨៩ | កាំង វុន | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩០ | ពិន អ៊ីន | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩១ | ហេង លាង | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩២ | ដួង ហុល | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៣ | ណូ ង៉ឿន ហៅ ចិត្ត | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៤ | យុត ខន | យុទ្ធនារី | ស-២១យ | ២២-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៥ | ឡាយ ប៊ុនឡេង ហៅ សំ | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៦ | ប៉ុល សុង ហៅ ក្រុង | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៧ | ហុង ឈាង ហៅ ធា | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៨ | សូ ដាន | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ១៩៩៩ | ហម រឿន | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០០ | ស៊ឹម សុអេង ហៅ ណេត | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០១ | លឹម ទ្រី ហៅ ឆន | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០២ | លី អាន ហៅ សុត | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៣ | យឿន នី ហៅ ដាត | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៤ | ស៊ុន ស៊ឹម ហៅ សុង | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៥ | ព្រុំ អឿន ហៅ គិត | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៦ | លុន គៀ ហៅ ឆន | យុទ្ធនារី | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៧ | អៀ ដាំ (ស្រី) | ម្តាយមីង រស់ ពត | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៨ | អៀ ទូច (ស្រី) | ម្តាយ រស់ពត | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០០៩ | សុក ណៃ (ស្រី) | ម្តាយ រ៉ិត រឿន | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១០ | នាង អ៊ុម (ស្រី) | ម្តាយ មុំ ទឹម | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១១ | អ៊ី ស៊ឹម (ស្រី) | ចិន | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១២ | ឡេ ឆិញ (ស្រី) | ម្តាយ សួស ណារិន | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១៣ | ចាន់ អឹម (ស្រី) | ម្តាយ សុក | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |

**(នៅមានត)**

# យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥























# ថ្ងៃឈឺចាប់


ធាន ម៉ារ៉ាឌី

ចូលឆ្នាំថ្មីនេះ ធាន ម៉ារ៉ាឌី មានអាយុ៤៨ឆ្នាំហើយ ។ ទោះបីពេលចូលឆ្នាំខ្មែរនេះជាពេលមួយដែលគាត់សប្បាយរីករាយ និងបានជួបជុំគ្រួសារក៏ដោយ ក៏ ម៉ារ៉ាឌី មិនអាចបំភ្លេចព្រឹត្តិការណ៍កាលពី៣០ឆ្នាំមុនគឺពេលដែលកងទ័ពខ្មែរក្រហមក្មេងៗជម្លៀសក្រុមគ្រួសាររបស់គាត់ចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅក្នុងឆ្នាំ១៩៧៥ ម៉ារ៉ាឌី មានអាយុ១៨ឆ្នាំ ហើយកំពុងរៀនថ្នាក់ទី៧ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនិងបណ្តេញប្រជាជនចេញពីទីក្រុង ម្តាយរបស់ ម៉ារ៉ាឌី ដែលមានផ្ទៃពោះគ្រប់ខែ បានឈឺពោះសម្រាលកូននៅម៉ោង១០ព្រឹក ។ ឪពុករបស់គាត់បានសុំអនុញ្ញាតកងទ័ពខ្មែរក្រហមដើម្បីពន្យារពេលចាកចេញចំនួនពីរថ្ងៃ ដោយសារតែប្រពន្ធនៅសរសៃខ្ចី ។ ក្រោយពីការអង្វរករដ៏យូរ កងទ័ពខ្មែរក្រហមបានយល់ព្រម ប៉ុន្តែបានដាក់លក្ខខណ្ឌថា "ចង់នៅក៏នៅចុះ ប៉ុន្តែបើមានរឿងអ្វីកើតឡើង ទទួលខុសត្រូវដោយខ្លួនឯង" ។ ពីរថ្ងៃក្រោយ ឪពុករបស់ ម៉ារ៉ាឌី រៀបចំឥវ៉ាន់ដើម្បីនាំក្រុមគ្រួសារដែលមានសមាជិក៦នាក់ចាកចេញពីទីក្រុងភ្នំពេញ ។ គាត់ច្នៃប្រឌិតផលិតបានរទេះរុញមួយ ហើយដាក់ប្រពន្ធនិងទារកដែលទើបនឹងកើតលើរទេះរុញនោះរួចហើយនាំក្រុមគ្រួសារធ្វើដំណើរទៅ ។ ម៉ារ៉ាឌី បញ្ជាក់ថា ពេលនោះប្រជាជនបានចាកចេញពីទីក្រុងភ្នំពេញអស់ទៅហើយ ទីក្រុងទាំងមូលស្ងាត់ជ្រងំ ។ ក្រុមគ្រួសាររបស់ ម៉ារ៉ាឌី សម្រាកពេលយប់នៅចាក់អង្រែ ហើយគិតថាព្រឹកឡើងនឹងធ្វើដំណើរតាមផ្លូវជាតិលេខ២ឆ្ពោះទៅស្រុកកំណើតនៅឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ក៏ប៉ុន្តែព្រឹកឡើង ក្រុមគ្រួសាររបស់ ម៉ារ៉ាឌី មិនអាចធ្វើដំណើរតាមផ្លូវជាតិលេខ២បានទេ ព្រោះកងទ័ពខ្មែរក្រហមបានបិទផ្លូវនេះ ហើយបញ្ជាប្រជាជនឲ្យធ្វើដំណើរទៅតាមផ្លូវជាតិលេខ១ ។ ដូច្នេះគ្រួសាររបស់ ម៉ារ៉ាឌី ក៏បកមកឆ្លងស្ពានច្បារអំពៅហើយធ្វើដំណើរតាមផ្លូវជាតិលេខ១ ហើយទម្រាំមកដល់ស្រុកកំណើតគឺត្រូវដើរអស់រយៈពេលជាច្រើនថ្ងៃ ។

ក្រុមគ្រួសាររបស់ ម៉ារ៉ាឌី មកដល់ស្រុកកំណើតបានមួយអាទិត្យ មេភូមិឈ្មោះ ថន បានមកប្រាប់ឪពុករបស់ ម៉ារ៉ាឌី ថាគណៈឃុំឲ្យអញ្ជើញគាត់ទៅពិភាក្សាអំពីការងារ ព្រោះអង្គការត្រូវការអ្នកបច្ចេកទេសដើម្បីយកទៅធ្វើការកន្លែងដើមវិញ ។ (ឪពុករបស់ ម៉ារ៉ាឌី គឺជាអតីតអ្នកបច្ចេកទេសនៅរោងចក្រស៊ីម៉ង់ត៍ខេត្តកំពត) ។ ម៉ារ៉ាឌី រៀបរាប់ថា "ប្រធានភូមិប្រាប់ថាប្រធានឃុំឲ្យអញ្ជើញគាត់ទៅពិភាក្សាការងារ ព្រោះឥឡូវអង្គការត្រូវការអ្នកបច្ចេកទេសទៅធ្វើការកន្លែងដើមវិញ ។ គាត់អត់ដឹងថាខ្លួនទៅស្លាប់ទេ ។ ខ្ញុំនៅចាំបានថាគាត់ស្លៀកតែខោខ្លីមួយ ពាក់អាវពណ៌ខៀវ ដើរចេញពីផ្ទះទៅទិសខាងជើងសំដៅទៅសាលាឃុំញ៉ែងញ៉ង ។ ខ្ញុំខ្វោចចិត្តត្រង់ថាគាត់ដើរទៅស្លាប់ណា៎ ។ ខ្ញុំបានដឹងតែប៉ុណ្ណឹង បាត់ដំណឹងគាត់សូន្យឈឹងតែម្តង ។ ញាតិមិត្តជិតខាងបងប្អូនបានខ្សឹបប្រាប់ម៉ែខ្ញុំថាពុកខ្ញុំស្លាប់ហើយ គេសម្លាប់ហើយ គេមិនឲ្យមកវិញទេ យើងមិនបាច់សង្ឃឹមទេ ។ ពេលហ្នឹងហើយដែលខ្ញុំចេះតែមានកំហឹង ។ វាអយុត្តិធម៌សម្រាប់គាត់ណាស់ បើថាគាត់ជាអ្នកមាននិន្នាការនយោបាយអីអត់ទេ គាត់ជាអ្នកបច្ចេកទេសសោះក៏ត្រូវប៉ុលពតសម្លាប់ដែរ" ។

ក្រោយពេលដែលឪពុករបស់ ម៉ារ៉ាឌី ស្លាប់ទៅ ម្តាយរបស់ ម៉ារ៉ាឌី កើតទុក្ខជាខ្លាំង ។ ប្អូនស្រីពីរនាក់របស់ ម៉ារ៉ាឌី ក៏មានជំងឺជាទម្ងន់ទៀត ហើយបន្ទុកនេះធ្លាក់លើម្តាយរបស់គាត់ទាំងអស់ ។ មួយខែក្រោយពីឪពុករបស់ ម៉ារ៉ាឌី ស្លាប់ទៅ ប្អូនពៅរបស់គាត់ដែលទើបតែមានអាយុជាង១ខែក៏បានស្លាប់ ហើយមួយឆ្នាំកន្លះក្រោយមកទៀត ប្អូនស្រីបន្ទាប់ ម៉ារ៉ាឌី ម្នាក់ទៀតក៏

ស្លាប់ដោយជំងឺគ្មានថ្នាំព្យាបាល ។ ម៉ារ៉ាឌី និយាយថា “ម្តាយខ្ញុំសោកសៅណាស់ ក្រោយពេលដែលបាត់ប្តី ហើយស្លាប់កូនពីរនាក់ទៀត គាត់ចង់ទៅជាវិកលចរិតណាស់ ប៉ុន្តែបានបងប្អូនរបស់ខ្ញុំជួយជ្រោមជ្រែងលើកទឹកចិត្តខ្លះទៅ ប៉ុន្តែកាលណោះលើកទឹកចិត្តហ្នឹងធ្វើដោយលាក់លៀមទៀតណាស់ ។ យប់ឡើងមានឈ្លបសម្ងាត់របស់អង្គការមកលបស្តាប់នៅក្រោមផ្ទះរាល់យប់ក្រែងលោយើងមានសកម្មភាពអ្វី យើងនិយាយអីពីគេ ។ ម្ល៉ោះហើយយប់ឡើងយើងត្រូវនៅស្ងៀម ទោះជាយំក៏អត់ហ៊ានឲ្យឮដែរ ។ ព្រលឹមឡើងចេញទៅធ្វើការនឹងគេទៅ គាត់ធ្វើការតាមកងរបស់គាត់ ខ្ញុំធ្វើតាមកងរបស់ខ្ញុំ យប់ឡើងមកដល់ផ្ទះគាត់សោកសង្រេង តែមិនដឹងធ្វើម៉េច ។ បើដូចឥឡូវនេះយើងចេះតែឲ្យអ្នកដទៃជួយបាន កាលជំនាន់នោះវាលំបាកណាស់ គេគាបសង្កត់សតិអារម្មណ៍ផងផ្លូវចិត្តផង ធ្វើបាបយើងណាស់” ។

ក្រោយឆ្នាំ១៩៧៩ ម្តាយរបស់ ម៉ារ៉ាឌី នៅតែញាំញីដោយការឈឺចាប់ផ្លូវចិត្ត ដែលបន្សល់ពីរបបខ្មែរក្រហមរហូតដល់ពេលដែលគាត់បាត់បង់ជីវិតនៅឆ្នាំ២០០៤ ។ ម៉ារ៉ាឌី និយាយថា តាំងពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ រហូតដល់ពេលដែលម្តាយគាត់ស្លាប់ គាត់មិនដែលឃើញម្តាយរបស់គាត់សប្បាយចិត្តម្តងណាឡើយ ។ ម៉ារ៉ាឌី សោកស្តាយដែលម្តាយរបស់គាត់ស្លាប់ទៅទាំងមិនទាន់បានទទួលយុត្តិធម៌ ។ ម្តាយរបស់ ម៉ារ៉ាឌី ក៏មិនខុសពីប្រជាជនកម្ពុជាទូទៅដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម ប៉ុន្តែមិនបានទទួលយុត្តិធម៌ចំពោះអ្វីដែលគាត់បានទទួលរងនិងបាត់បង់ ។ ម៉ារ៉ាឌី ពិតជាចង់បានតុលាការមួយដែលអាចផ្តល់យុត្តិធម៌ចំពោះការស្លាប់របស់ឪពុកនិងប្អូនៗរបស់គាត់និងចំពោះការឈឺចាប់របស់ម្តាយគាត់ ។ **ញាណ សុជាតិ**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី “វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រ ចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៤៣ ០៧២ ។ សូមអរគុណ ។

# ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ?

**(តចប់)**

### ឃ) ឧស្សាហូបនីយកម្មដែលពឹងពាក់ខ្លួនឯង

ឧស្សាហកម្មនៅទីក្រុងភ្នំពេញមិនបានខូចខាតដោយសារសង្គ្រាមទេ ហើយស្ទើរតែទាំងអស់នៅតែមានដំណើរការនៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ ឧស្សាហកម្មជាច្រើនទៀតត្រូវបានបន្ថែមព្រមទាំងមានរោងសិប្បកម្មតូចៗជាច្រើនទៀតផង ។

នៅអំឡុងពេលជម្លៀសប្រជាជន កម្មាភិបាលភូមិភាគបូព៌ាបានហៅអ្នកបច្ចេកទេសឲ្យមករៀបចំគ្រឿងម៉ាស៊ីនឲ្យមានដំណើរការឡើងវិញ ។ ក៏ប៉ុន្តែ អ្នកបច្ចេកទេសទាំងអស់ត្រូវបានបញ្ជូនឲ្យត្រឡប់ទៅវិញដោយសារតែអ្នកបូព៌ាក៏ត្រូវដេញចេញជាបណ្តើរៗ ហើយអ្នកនិរតីបានចូលមកកាន់កាប់ទាំងស្រុង ។ ឥឡូវនេះកូនប្រុសនិងកូនស្រីរបស់កសិករក្រីក្រជាអ្នករៀបចំដំណើរការរបស់រោងចក្រ ។ មិនមាននរណាម្នាក់ខ្វល់អំពីដំណើរការមិនប្រក្រតីរបស់ម៉ាស៊ីនទេ អ្វីដែលមានសារសំខាន់នោះគឺគោរពតាមការណែនាំរបស់អង្គការ ។ ទិសដៅត្រូវបានកំណត់រួចជាស្រេច គឺបំពេញតាមតម្រូវការរបស់អង្គការ មិនមែនកំណត់តាមលទ្ធភាពដែលរោងចក្រអាចផលិតបាននោះទេ ។ លទ្ធផលគឺថាផលិតកម្មបានកើនឡើងមែន ប៉ុន្តែមិនមានគុណភាព ។ ចបកាប់និងប៉ែលមិនសូវមាំ ហើយម៉ាស៊ីនកសិកម្មក៏ឆាប់ខូចដោយសារតែលំបាកក្នុងការធ្វើឲ្យសីតុណ្ហភាពខ្ពស់ដល់កម្រិតដើម្បីផលិតដែក ។

ការសាងសង់អគារឧស្សាហកម្មបានអនុវត្តដោយមានជំនួយពីអ្នកបច្ចេកទេសនិងទីប្រឹក្សាចិន ។ អ្នកបច្ចេកទេសនិងទីប្រឹក្សាទាំងនេះបានជួសជុលព្រលានយន្តហោះនៅភ្នំពេញ ប្រព័ន្ធដឹកជញ្ជូនផ្លូវដែកនិងផ្លូវថ្នល់ រោងចក្រមួយចំនួន ប្រព័ន្ធទូរស័ព្ទ រោងចក្រចម្រាញ់ប្រេងកាត ។ល ។ ហើយថែមទាំងបានពង្រីកព្រលានយន្តហោះតូចមួយនៅខេត្តសៀមរាបទៀតផង ។ ជាងផ្សារដែក ជាងម៉ាស៊ីន និងជាងអគ្គិសនី ត្រូវបានបញ្ជូនមកពីប្រទេសចិន ។ មានអ្នកបច្ចេកទេសចិនជាង៧រយនាក់នៅឯកំពង់ផែកំពង់សោម ។ ប្រទេសកូរ៉េខាងជើងបានជួយបំពាក់រោងចក្រតម្លើងត្រាក់ទ័រមួយ កសាងវារីអគ្គិសនីមួយ រោងចក្រកែច្នៃកូនត្រីមួយ និងការងារផ្សេងៗទៀតទាក់ទងនឹងប្រព័ន្ធធារាសាស្ត្រ ។ ប្រទេសរ៉ូម៉ានីបានអភិវឌ្ឍរោងចក្រត្រីសមុទ្រនិងរោងចក្រត្រីខកំប៉ុង ។ នៅខែមករាឆ្នាំ១៩៧៩ អ្នកបច្ចេកទេសចិននិងកម្មករកម្ពុជាបានកសាងផ្លូវរថភ្លើងមួយខ្សែពីក្រុងភ្នំពេញទៅកំពង់សោម ។

អ្នកបច្ចេកទេសជនជាតិចិនមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងដំណើរការរោងចក្រទេ ។ នៅពេលដែលអ្នកបច្ចេកទេសចិនបង្រៀនអំពីរបៀបប្រើប្រាស់គ្រឿងម៉ាស៊ីន កម្មករត្រូវកត់ត្រាអំពីរបៀបបញ្ជាម៉ាស៊ីន ប៉ុន្តែកម្មករទាំងនោះមិនចេះអក្សរទាល់តែសោះ ។ ដំណោះស្រាយពីរត្រូវបានរកឃើញនៅឆ្នាំ១៩៧៨ ។ កម្មករទាំងអស់ត្រូវតែរៀនឲ្យចេះអាននិងចេះសរសេរ ហើយសាលាបច្ចេកទេសមួយត្រូវបានបង្កើតឡើងដែល ប៉ែកឃ័រ បានពណ៌នាថាល្អជាងសាលាពាណិជ្ជកម្មមូលដ្ឋានបន្តិចបន្តួចប៉ុណ្ណោះ ។ នាយកសាលានេះបានអះអាងយ៉ាងមានមោទកភាពថា យុវជនទាំងអស់នេះមានសមត្ថភាពខ្ពស់ជាងវិស្វករអឺរ៉ុបរួចទៅហើយ ។

អ្វីដែលនៅតែមិនទាន់ច្បាស់លាស់នោះគឺកម្លាំងដ៏ខ្លាំងក្លារបស់កម្មករចំពោះការងារ ។ សូម្បីតែមនុស្សក្មេងបំផុតក៏អាចធ្វើការងារដែលគួរឲ្យកោតសរសើរដែរ ។ កម្មករទាំងនោះអាចធ្វើទូកឈើធំៗដែលអាចប្រើប្រាស់នៅក្នុងសមុទ្របានដោយប្រើប្រាស់សម្ភារដ៏សាមញ្ញ ដែលធ្វើឲ្យទីប្រឹក្សាចិនស្ងើចសរសើរជាខ្លាំង ។

### ង) យុទ្ធសាស្ត្រដែលមានមូលដ្ឋានលើការនាំចេញ

ក្រដាសប្រាក់ត្រូវបានលុបបំបាត់ ប៉ុន្តែប្រាក់រៀលចាស់នៅតែប្រើប្រាស់ដដែល ហើយតម្លៃត្រូវបានកំណត់៤រៀលក្នុង១ដុល្លារ ។ ទំនិញដែលត្រូវប្តូររវាងសហករណ៍និងរដ្ឋត្រូវបានកំណត់តាមតម្លៃទីផ្សារពិភពលោក ប៉ុន្តែគិតជាលុយរៀល ។ នៅពេលដែលសហករណ៍ណាមួយបញ្ជាទិញថ្នាំពេទ្យឬសម្លៀក

បំពាក់ គ្រាក់ទ័រយូហ្គោស្លាវី ឬរថយន្តរបស់ចិន តម្លៃរបស់ទំនិញទាំងនេះត្រូវបានគិតតាមចំនួនឥណទានដែលសហករណ៍នោះមាន ។ ឯកសារជំនួញត្រូវបានថែរក្សាដោយភ្នាក់ងារមជ្ឈិមដែលជាអ្នកកំណត់តម្លៃទំនិញនាំចូលទៅតាមតម្លៃប្រែប្រួលរបស់អង្ករនៅលើទីផ្សារពិភពលោក ។

បក្សកុម្មុយនិស្តកម្ពុជាបានបដិសេធមិនទទួលជំនួយបរទេសទេ ។ បក្សបានបដិសេធមិនទទួលយកជំនួយពីអង្គការយូនីសេហ្វ (UNICEF) អង្គការជួយសង្គ្រោះកុមារ (Save the Children) គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (International Committee of the Red Cross) អង្គការកាកបាទក្រហមពីប្រទេសមិនចូលបក្សសម្ព័ន្ធចំនួនបីនិងពីប្រទេសកាណាដា ។ នៅឆ្នាំ១៩៧៥ ប្រទេសចិនបានផ្តល់ជំនួយយោធានិងសេដ្ឋកិច្ចមិនយកការប្រាក់ចំនួន១ពាន់លានដុល្លារអាមេរិក ។ ក្រៅពីនេះចិនក៏បានផ្តល់អំណោយចំនួន២០លានដុល្លារអាមេរិកថែមទៀត ប៉ុន្តែកម្ពុជាមិនបានប្រើប្រាស់ជំនួយនេះទេ ។ កូរ៉េខាងជើងបានផ្តល់ជាត្រាក់ទ័រនិងសម្ភារផ្សេងទៀត ប៉ុន្តែ ខៀវ សំផន បានបដិសេធជំនួយនេះដោយនិយាយថា "កម្ពុជាជាម្ចាស់លើខ្លួនឯង" ។ ក្រោយមកទៀត កម្ពុជាប្រជាធិបតេយ្យបានទទួលយកជំនួយខ្លះៗដូចជាថ្នាំគ្រុនចាញ់មួយចំនួនតូចពីអង្គការមនុស្សធម៌មួយរបស់អាមេរិក និងជំនួយជាម៉ាស៊ីនកសិកម្ម ថ្នាំពេទ្យ គ្រឿងបរិក្ខារពេទ្យ និងសម្ភារផ្សេងៗទៀត ពីប្រទេសយូហ្គោស្លាវី ។

យុទ្ធសាស្ត្រនាំចេញនៅក្នុងផែនការ៤ឆ្នាំរបស់ ប៉ុល ពត បានផ្តោតជាសំខាន់ទៅលើការនាំស្រូវចេញ ។ ការនាំចេញទៅប្រទេសចិនបានចាប់ផ្តើមនៅឆ្នាំ១៩៧៦ ហើយស្ទើរតែរៀងរាល់ថ្ងៃមានកប៉ាល់ដឹកស្រូវចេញពីកំពង់សោម ។ នៅឆ្នាំ១៩៧៦ កម្ពុជាបាននាំទំនិញចេញទៅដល់ពិភពមូលធននិយម ពោលគឺកោះហុងកុង ប៉ុន្តែស្រូវនិងកៅស៊ូរបស់កម្ពុជាមានគុណភាពទាបណាស់ ។ បក្សកុម្មុយនិស្តកម្ពុជាចង់បញ្ចេញកៅស៊ូរបស់ខ្លួនទៅទ្វីបអឺរ៉ុបតាមប្រទេសម៉ាឡេស៊ី និងបានបង្កើតក្រុមហ៊ុនមួយនៅក្នុងប្រទេសសិង្ហបុរីសម្រាប់ការធ្វើពាណិជ្ជកម្មជាមួយប្រទេសនៅអាស៊ី-អាគ្នេយ៍និងអឺរ៉ុប ។ កម្ពុជាប្រជាធិបតេយ្យមានគម្រោងនាំចេញស្រូវ កប្បាស និងប្រភេទគ្រាប់ពូជផ្សេងៗទៅប្រទេសថៃ ។ អ្នកនេសាទជនជាតិថៃបានមកនេសាទលើផ្ទៃទឹកកម្ពុជាដោយលួចលាក់ ឬមានការព្រមព្រៀងជាមួយនឹងអាជ្ញាធរមូលដ្ឋានដោយប្រគល់ជាថ្នូរនូវសាំងឬទំនិញផ្សេងៗ ។ កម្ពុជាបាននាំចេញឈើ ត្បូង និងផលិតផលបន្លែមួយចំនួនតូចទៅប្រទេសជប៉ុន ហើយមានបំណងលក់ត្រី ក្តាមបន្ទះ សត្វអាហារ ម្រេច និងផលិតផលកសិកម្ម ទៅប្រទេសសិង្ហបុរី ។

ការនាំចេញរបស់កម្ពុជាទៅប្រទេសចិនរួមមាន ឈើហ៊ុបម្រេចខ្មៅ ដូង និងទំនិញដែលកម្រនិងមានតម្លៃខ្ពស់ដូចជាគ្រាប់ឈូក កាហ្វេ ផ្កាចំប៉ី ក្រវាញ និងសរីរាង្គផ្សេងៗរបស់សត្វដែលមានតម្លៃសម្រាប់ធ្វើជាថ្នាំពេទ្យនិងថ្នាំសម្រើបដូចជា ស្បែកពស់ ស្បែកខ្លាឃ្មុំ ស្នែងរមាំង ស្នូកអណ្តើក ស្នែងក្របី ឆ្អឹងស្វា និងសម្ភារកម្រៗផ្សេងទៀតដែលស្តេចត្រាញ់របស់ប្រទេសកម្ពុជាតែងតែថ្វាយព្រះមហាក្សត្រជាសួយសារអាករអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ។

កម្ពុជាប្រជាធិបតេយ្យចាំបាច់ត្រូវតែនាំចូលផលិតផលសម្រេចពីប្រទេសមូលធន ដោយសារតែរោងចក្ររបស់កម្ពុជាផលិតបានផលិតផលដែលមានគុណភាពទាប ។ មានរបាយការណ៍អំពីការនាំចូលសម្លៀកបំពាក់ពីប្រទេសថៃ ចិន កូរ៉េខាងជើង និងយូហ្គោស្លាវី ចំណែកឯខ្សែនីឡុង ក្រមា សម្លៀកបំពាក់ពណ៌ខ្មៅ កាបូបក្រចៅ អាវភ្លៀង ថ្នាំពេទ្យ អំបិល ស្ករស កាំបិត ពូថៅ កណ្តៀវ នង្គ័ល គ្រឿងបន្លាស់ម៉ាស៊ីន ស្បែកជើងកៅស៊ូ ស្តែក្តោប និងគ្រាប់សាឡាត់នាំមកពីប្រទេសថៃ ។ ថ្នាំប៉េនីស៊ីលីនត្រូវបាននាំចូលពីប្រទេសថៃនិងតាមរយៈហុងកុង ថ្មដែកកេះពីប្រទេសចិន ហ្វីល និងសម្ភារសម្រាប់ថតរូបពីហុងកុង សាំងនិងប្រេងពីប្រទេសចិន ថៃ និងតាមរយៈហុងកុង ផលិតផលប្រេងឥន្ធនៈពីប្រទេសសិង្ហបុរី ដែកពីប្រទេសចិននិងជប៉ុន រំសេវពីប្រទេសចិននិងសាជីវកម្មវត្ថុគីមីនៃរដ្ឋកាលីហ្វ័រញ៉ា ។ កម្ពុជាទិញទំនិញពីកោះហុងកុង និងអាចធ្វើពាណិជ្ជកម្មជាមួយប្រទេសសិង្ហបុរីនិងជប៉ុនបានដោយសារតែប្រទេសចិនបានផ្តល់នូវឥណទានសម្រាប់ប្តូរប្រាក់បរទេស ។ ការនាំទំនិញចូលបានកើនឡើងឆាប់រហ័សជាងការនាំទំនិញទៅលក់នៅក្រៅប្រទេស ។ អតុល្យភាពពាណិជ្ជកម្មដ៏ធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យបក្សកុម្មុយនិស្តកម្ពុជាមិនអាចសម្រេច

ទៅតាមគោលការណ៍ពឹងពាក់លើខ្លួនឯងបានឡើយ ។

### ៧) ជីវភាព

ផែនការ៤ឆ្នាំរបស់ ប៉ុល ពត បានសរសេរថា ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនគឺជាការសំខាន់ ហើយបានសរសេរទៀតថា ការបរិភោគបាយជាមធ្យមប្រចាំថ្ងៃគឺកន្ទះគីឡូក្រាម ។ ប៉ុន្តែអ្នកដែលនៅរស់ជីវិតពីរបបនោះបាននិយាយថា ខ្លួនស្ទើរតែមិនដែលបានបរិភោគបាយទាល់តែសោះ គឺបានបរិភោគតែបបររាវៗប៉ុណ្ណោះ ។ នៅតាមសហករណ៍ទាំងឡាយ ប្រជាជនឃើញមានអាហារ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យបរិភោគអាហារទាំងនោះទេ ។ ប្រជាជនម្នាក់បាននិយាយថា “មានជង្រុកស្រូវជាច្រើនដែលមានទំហំប៉ុនៗផ្ទះ ប៉ុន្តែស្រូវទាំងនេះត្រូវបានដឹកតាមឡានយកចេញទៅអស់” ។

តើស្រូវទាំងអស់នោះទៅណា? បរិមាណស្រូវដែលបាននាំចេញទៅក្រៅប្រទេសមិនអាចកំណត់បានទេ ដោយសារតែពុំមានទិន្នន័យនៃចំនួនស្រូវដែលបាននាំចេញទៅប្រទេសចិននិងកូរ៉េខាងជើង ។ ប្រហែលជាស្រូវទាំងអស់ដែលប្រមូលពីសហករណ៍មិនបានលក់ទេ ហើយនៅក្នុងករណីខ្លះស្រូវទាំងនោះមិនបានចេញទៅទីផ្សារពិភពលោកទៀតផង ។ អ្នកកាសែតយូហ្គោស្លាវីម្នាក់ដែលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ បានរាយការណ៍ថានៅក្នុងសហករណ៍ខ្លះ ជង្រុកស្រូវមិនអាចផ្ទុកផលស្រូវដែលប្រមូលបានទាំងអស់ទេ ហេតុនេះហើយ ស្រូវដែលនៅសល់ត្រូវទុកចោលនៅឯវាលស្រែ ។

ម្ហូបអាហារមិនត្រូវបានបែងចែកដោយស្មើភាពឡើយ ។ នៅក្នុងចំណោមកម្មាភិបាលរបស់បក្ស ចំនួនម្ហូបអាហារដែលបែងចែកគឺខុសៗគ្នាទៅតាមមុខតំណែង ហើយមេដឹកនាំទទួលបានម្ហូបអាហារច្រើនយ៉ាងពិសេស ។ ប្រជាជនថ្មីទទួលបានរបបអាហារច្រើនបំផុតគឺ១កំប៉ុងក្នុងមួយថ្ងៃនៅអំឡុងពីរខែបន្ទាប់ពីប្រមូលផល និងទាបបំផុតគឺកន្ទះកំប៉ុងក្នុងមួយថ្ងៃ ។ ប្រជាជនហូបមិនគ្រប់គ្រាន់ ហើយគ្មានការផ្តល់អាហារបន្ថែមទេ ។ អ្នកដែលត្រូវអង្គការចាប់បានជាមួយនឹងត្រី ក្តាម ខ្យង ឬក៏ជីងចក់ជួនកាលត្រូវបានប្រហារជីវិតដោយសារតែយកធនធានរបស់ប្រជាជនមកធ្វើជារបស់ផ្ទាល់ខ្លួន ។ ដោយសារតែធ្វើការងារអស់កម្លាំងពេក របបអាហារដែលទទួលបានមិនបំពេញតាមតម្រូវការរបស់ប្រជាជនឡើយ ។ ប្រជាជនភាគច្រើនបរិភោគអាហារដែលមិនមានជាតិខ្លាញ់និងមានជាតិប្រូតេអ៊ីនតិចតួច ។ ប្រជាជនបរិភោគអាហារមិនសូវមានវីតាមីន ដោយសារតែប្រជាជនកម្របានបរិភោគផ្លែឈើនិងបន្លែឆៅ ដូច្នេះហើយការបំលែងជាតិស្ករនៅក្នុងខ្លួនក៏កម្រដែរ ។ ការរំលាយអាហារមិនគ្រប់គ្រាន់បានបង្កទៅជាជំងឺហើមពោះ ជំងឺរាកមួល និងធ្វើឲ្យរាងកាយចុះខ្សោយ ។ នៅក្នុងស្ថានភាពដែលខ្វះអាហារូបត្ថម្ភនិងមានជំងឺដូច្នេះ ប្រជាជនត្រូវធ្វើការងារដែលធ្ងន់ធ្ងរហួសកម្លាំងនិងរំខានដោយកង្វះខាតបាយ ។ ចំនួនមនុស្សស្លាប់ដែលចេះតែកើនឡើងបានធ្វើឲ្យកម្លាំងពលកម្មចុះខ្សោយ ។ ការណ៍នេះបាននាំឲ្យមានការប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេស ។

ជីវភាពរស់នៅរបស់“ប្រជាជនចាស់” មានការវាយតម្លៃខុសៗគ្នា ។ យោងតាម ម៉ាទីន អង្គការមិនបានជម្លៀសប្រជាជនចាស់ចេញពីភូមិទេ ។ ប្រជាជនចាស់មានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ អាចបន្តដាំបន្លែនិងដើមឈើហូបផ្លែ ហើយថែមទាំងអាចបរិភោគផ្លែឈើនិងបន្លែដែលខ្លួនបានដាំទៀតផង ។ ទ្វីននីងយល់ថា បែបបទនៃការបំពេញការងារគឺផ្ទុយគ្នាទៅនឹងបទដ្ឋានការងារតាមទំនៀមទម្លាប់របស់កសិករ ។ នៅសម័យមុនៗប្រជាជនមានពេលសម្រាកបន្ទាប់ពីបំពេញការងារ ប៉ុន្តែឥឡូវនេះប្រជាជនត្រូវធ្វើការជារៀងរាល់ថ្ងៃ ។ តាមការវាយតម្លៃរបស់ អេប៊ីហារ៉ា សូម្បីតែកសិករដែលទម្លាប់ទៅនឹងការធ្វើពលកម្មជារៀងរាល់ថ្ងៃក៏មានអារម្មណ៍ថាការងារដែលតម្រូវឲ្យបំពេញគឺច្រើនលើសលប់ ។

តាមសេចក្តីរាយការណ៍របស់វិទ្យុ នៅខែមិថុនាឆ្នាំ១៩៧៦ អង្គការសុខភាពមួយត្រូវបានបង្កើតឡើង ដែលក្នុងនោះមានមន្ទីរពេទ្យនិងបន្ទប់សម្រាប់សម្រាលកូន ។ នៅមន្ទីរពេទ្យទាំងនេះយុទ្ធជនយុទ្ធនារីជាអ្នកបម្រើសេចក្តីត្រូវការរបស់កសិករ ហើយការធ្វើដូច្នេះគឺដើម្បីប្រមូលកម្លាំងឲ្យបានច្រើនថែមទៀតក្នុងការកសាងភ្លឺស្រែ ។ ប៉ុន្តែនារីកសិករក្មេងៗដែលជាគិលានុបដ្ឋាយិកា មិនមានចំណេះដឹងផ្នែកពេទ្យទាល់តែសោះ ហើយក៏មិនយល់អំពីរូបមន្តគីមីដែលអ្នកជំនាញការចិនបានបង្រៀនដែរ ។

ឡូវ៉ង់ ពិច បានសង្កេតមើលពេទ្យក្មេងៗដែលមានអាយុពី៩ឆ្នាំ ទៅដល់១៣ឆ្នាំ ហើយបានរកឃើញថាពេទ្យក្មេងៗទាំងនេះមាន ឫកពារក្រអឺតក្រទមណាស់ ។

អង្គការថែរក្សាកុមារដោយប្រុងប្រយ័ត្នខ្លាំងណាស់ ព្រោះខួរក្បាលរបស់កុមារទាំងនេះដិតដាមទៅដោយចិត្តគំនិត របស់ឪពុកម្តាយ ។ ឪពុកម្តាយមិនមានសិទ្ធិក្នុងការអប់រំកូនចៅ របស់ខ្លួនទេ ។ នៅក្នុងរោងបាយដែលគ្មានសណ្តាប់ធ្នាប់សម្រាប់ ទទួលទានអាហាររួមគ្នា កុមារត្រូវបានឲ្យបរិភោគមុនមនុស្ស ចាស់ ។ អង្គការតម្រូវឲ្យកុមារបំពេញការងារខាងផ្នែកសន្តិសុខ ដូចជាឈ្លបនៅក្នុងសហករណ៍និងនៅក្នុងពន្ធនាគារ ។ យុវជន យុវតីដែលបានចូលបម្រើការងារបដិវត្តន៍តាំងពីអំឡុងពេល សង្គ្រាមត្រូវបានចាត់តាំងឲ្យបំពេញការងារជាទាហាននិងជាអ្នក ធ្វើទារុណកម្មអ្នកទោសនៅក្នុងគុកទួលស្លែង ។ នៅក្នុងចំណោម មនុស្ស១៦៦នាក់ដែលបម្រើការងារនៅក្នុងគុកទួលស្លែងនៅឆ្នាំ ១៩៧៦ មាន១០៨នាក់ជាយុវជនអាយុពី១៨ទៅ២១ឆ្នាំ ហើយ ២០នាក់ជាកុមារដែលមានអាយុក្រោម១៨ឆ្នាំ ។

កុមារទាំងនោះបានដឹងអំពីតួនាទីរបស់ខ្លួននៅពេលអនាគត ហើយមិនអត់ឱនឲ្យអ្វីៗដែលតំណាងឲ្យភាពទន់ខ្សោយ ពុតត្បុត និងស្រេកឃ្លានអំណាចទេ ។ កុមារទាំងនោះគោរពបញ្ជារបស់ អង្គការយ៉ាងម៉ឺងម៉ាត់ រហូតដល់ចាត់ទុកឪពុកម្តាយរបស់ខ្លួនជា អ្នកដទៃ ។ ឧទាហរណ៍ កុមារត្រូវបានបង្រៀនឲ្យសូត្រពាក្យ ស្លោកថា «ខ្ញុំមិនមែនសម្លាប់ម្តាយរបស់ខ្ញុំទេ គឺខ្ញុំសម្លាប់ខ្មាំង» ។ នេះជាចុងបញ្ចប់នៃភាពជាក្រុមគ្រួសារនិងតម្លៃរបស់គ្រួសារ ។

### ៧) មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាប្រឈមមុខនឹងបញ្ហា

បន្ទាប់ពីបានដាក់ផែនការឲ្យអនុវត្ត ជោគជ័យដ៏ធំធេងត្រូវ បានរាយការណ៍ ។ នៅខែធ្នូ ឆ្នាំ១៩៧៦ មជ្ឈិមបក្សបានថ្លែងថា បដិវត្តន៍សង្គមនិយមទទួលបានជ័យជម្នះយ៉ាងពេញចិត្តរហូតដល់ ហួសពីការរំពឹងទុកទៀតផង ។ ប្រជាជនក្រីក្រមានអាហារ បរិភោគគ្រប់គ្រាន់ មានសម្លៀកបំពាក់គ្រប់គ្រាន់ ហើយមាន ផ្ទះសម្បែងត្រឹមត្រូវ ។ ប្រជាជន៩០ភាគរយមានជីវភាពខ្ពស់ ជាងពេលណាៗទាំងអស់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ វិទ្យុបាន រាយការណ៍ថា កម្ពុជាប្រជាធិបតេយ្យសព្វថ្ងៃនេះមានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដ៏ខ្ពស់ ហើយពិភពលោកកំពុងតែកោតសរសើរ យើង ។ ថ្នាំពេទ្យមានការរីកចម្រើនជាងមុនច្រើន ។ នៅក្នុង សហករណ៍ទាំងអស់ ប្រជាជនរៀនអានអក្សរនិងគិតលេខ ។ ចំណែកឯអ្នកចម្បាំងវិញបើករថយន្តដែលបំពាក់ដោយអាវុធ យន្តហោះ និងបញ្ជានាវាចម្បាំង ។ នេះជារូបភាពផ្លូវការ ចំណែក ឯកសារផ្ទៃក្នុងវិញបានបង្ហាញពីការពិតដែលផ្ទុយគ្នាស្រឡះ ។ នៅពេលដែលមជ្ឈិមបក្សកំពុងតែពិនិត្យផែនការនេះ មានសេចក្តី រាយការណ៍អំពីបញ្ហារួចទៅហើយ ។

#### ក) របាយការណ៍ដែលគួរឲ្យព្រួយបារម្ភ

នៅពាក់កណ្តាលឆ្នាំ១៩៧៦ អៀង ធីរិទ្ធ ត្រូវបានបញ្ជូន ទៅភូមិភាគពាយ័ព្យដើម្បីត្រួតពិនិត្យសភាពការណ៍ ។ អៀង ធីរិទ្ធ បានមើលឃើញបញ្ហា ហើយក្រោយមកគាត់បានប្រាប់ ប៉ែកយ័រ ថា «នៅខេត្តបាត់ដំបង ខ្ញុំបានឃើញកម្មាភិបាលខ្មែរក្រហម ចាត់តាំងប្រជាជនទាំងអស់ឲ្យទៅធ្វើការនៅវាលស្រែ ហើយ វាលស្រែនៅឆ្ងាយពីភូមិខ្លាំងណាស់ ។ ខ្ញុំឃើញប្រជាជនទាំង អស់នៅកណ្តាលវាលស្រែ ហាលខ្យល់នៅក្រោមកម្តៅថ្ងៃដ៏សែន ក្តៅ ហើយប្រជាជនភាគច្រើនមានជំងឺរាកមួលនិងគ្រុនចាញ់» ។

នៅខែកញ្ញា មជ្ឈិមបក្សបានដោះស្រាយបញ្ហាដែលកើត មាននៅមុនពេលប្រមូលផលនិងបញ្ហាទឹក ព្រមទាំងបញ្ហាកង្វះខាត ដទៃៗទៀតទាក់ទងនឹងអាហារ ជម្រក និងទឹកផឹក ក្រោលគោ-ក្របីនិងចំណីអាហារ ការរៀបចំកសិកម្មស្រូវ និងកម្លាំង ។

នៅក្នុងកិច្ចប្រជុំរបស់កងពលមួយនៅខែតុលា មានសេចក្តី រាយការណ៍អំពីការមិនសប្បាយចិត្តនៅក្នុងជួរកងទ័ព ។ កម្មាភិបាល ម្នាក់បានត្អូញត្អែរថា «កាលពីពេលយើងធ្វើស្រែនៅក្នុងអំឡុង ពេលបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិ កិច្ចការស្រែចម្ការមាន ការរីកចម្រើន ។ ប៉ុន្តែនៅពេលយើងធ្វើស្រែចម្ការនៅក្នុង បដិវត្តន៍សង្គមនិយម យើងបែរជាដើរថយក្រោយទៅវិញ ។ កាលពីមុន យើងហូបអង្ករវាល់តៅ ឥឡូវហូបអង្ករវាល់កំប៉ុង» ។

នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំមួយនៅខែធ្នូ ប៉ុល ពត បាន និយាយម្តងទៀតអំពីគុណវិបត្តិក្នុងការផ្គត់ផ្គង់អាហារ ។ ៣ភាគ៤ នៃប្រទេសខកខានមិនបានដោះស្រាយបញ្ហានេះ ។ ការណ៍នេះ បានធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាជន ។ ប៉ុល ពត បាន

និយាយថា "នៅភូមិភាគបស្ចិមដែលជាកន្លែងផលិតស្រូវបានទិន្នផលខ្ពស់បំផុតនោះ បែរជាមានបញ្ហាខ្វះខាតអាហារធ្ងន់ធ្ងរជាងកន្លែងផ្សេងៗទៅវិញ" ។

នៅក្នុងកិច្ចប្រជុំមួយនៅដើមឆ្នាំ១៩៧៧ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាបានពិភាក្សាអំពីបញ្ហាដែលប្រមូលផលបានតិច ។ ហ៊ូ នឹម បានស្នើសុំឲ្យមានការលើកទឹកចិត្តជាសម្ភារខ្លះៗដើម្បីផលិតឲ្យបានច្រើនជាងមុន ហើយថា គួរតែចាប់ផ្តើមចាយលុយឡើងវិញ ។ មេបញ្ជាការកងវរសេនាធំម្នាក់ដែលក្រោយមកបានចុះចូលជាមួយប្រទេសថៃ បានអះអាងថា មេដឹកនាំមួយចំនួននៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដូចជា ហ៊ូ នឹម និង រស់ ញឹម បានស្នើសុំឲ្យបក្សមានក្តីមេត្តាចំពោះប្រជាជន ។ នៅក្នុងទស្សនៈរបស់មេដឹកនាំប៉ុន្មាននាក់នេះ ប្រទេសកម្ពុជាគួរតែទទួលយកជំនួយរបស់បរទេសដើម្បីកុំឲ្យប្រជាជនជួបប្រទះការលំបាកវេទនាខ្លាំងពេក ។

## ១) របៀបពន្យល់អំពីបរាជ័យ

ភ្លាមៗនោះ អៀង ធីរិទ្ធ បានសង្ស័យថាភ្នាក់ងារខ្មាំងកំពុងតែប្រតិបត្តិការនៅភូមិភាគពាយ័ព្យ ហើយកម្មាភិបាលនៅភូមិភាគនេះមានចេតនាមិនគោរពបញ្ជារបស់បក្ស ។ ការពន្យល់មួយនោះគឺថា កម្មាភិបាលខ្លះនៅតែគាំទ្រកម្មសិទ្ធិឯកជន សម្ភារនិយម អំណាច ភាពល្បីឈ្មោះ គ្រួសានិយម ការប្រណែននិន្ទានិងការធ្វើទុក្ខបុកម្នេញ ។ ថ្នាក់ដឹកនាំបានសន្និដ្ឋានថា ខ្មាំងនៅក្នុងបក្សមានបំណងបំផ្លាញបដិវត្តន៍ ហើយធ្វើឲ្យកម្ពុជាពឹងផ្អែកលើបរទេស ។

"ការបំផ្លាញផែនការ" បានពន្យល់អំពីមូលហេតុដែលនាំឲ្យផលិតកម្មចុះអន់ថយ ។ នៅពេលដែលភូមិភាគពាយ័ព្យមិនបានបញ្ជូនស្រូវមកភ្នំពេញនៅឆ្នាំ១៩៧៧ដោយសារតែប្រមូលផលបានតិចនិងកម្លាំងពលកម្មដែលទន់ខ្សោយដោយសារការបរិភោគមិនឆ្អែត បក្សបានចោទកម្មាភិបាលភូមិភាគនេះពីបទលាក់ឬបំផ្លាញទិន្នផលស្រូវ និងពីបទមានចេតនាបង្អត់អាហារប្រជាជន និងលក់ស្រូវឲ្យប្រទេសថៃ ។ នៅក្នុងគុកទួលស្លែង "អ្នកទោសបានសារភាព" ថាបានលែងគោឲ្យស៊ីស្រូវ ជុតភ្លឺស្រែ ធ្វើឲ្យទឹកលិចវាលស្រែ សម្លាប់សត្វគោ និងមិនអនុញ្ញាតឲ្យប្រជាជនធ្វើស្រែ ។ ដើម្បីបំផ្លាញផែនការ ស្រូវត្រូវបានច្រូតទាំងមិនទាន់ទុំ ។ ប៉ុល ពត បានត្អូញត្អែរថា ខ្មាំងបានបំផ្លាញប្រេងម៉ាស៊ីន ស្រូវ សម្លៀកបំពាក់ ដើមដូង និងដើមឪឡឹក ។ ប៉ុល ពត បាននិយាយទៀតថា "ខ្មាំងបានស្ទូងស្រូវបត់គល់" ។ នៅខែកក្កដាឆ្នាំ១៩៧៨ ទស្សនាវដ្តី "ទង់បដិវត្ត" បានសរសេរថា ខ្មាំងបាន "បង្អត់អាហារប្រជាជន ធ្វើឲ្យស្រេកឃ្លាន ធ្វើឲ្យប្រជាជនគ្មានអ្វីស្លៀកពាក់ និងគ្មានកន្លែងស្នាក់នៅ ។ ខ្មាំងបានបំផ្លាញទឹក គ្រាប់ពូជ ស្រូវ ជី សត្វ នង្គ័ល រនាស់...បំផ្លាញអ្វីៗទាំងអស់ ។

អ្នកទោសជាច្រើននៅទួលស្លែងត្រូវបានបង្ខំឲ្យសារភាពថា បានបំផ្លាញបដិវត្តដោយចេតនាដោយការធ្វើបាបប្រជាជន ។ មន្ត្រីម្នាក់បានសារភាពថាបានណែនាំអ្នកនៅក្រោមបង្គាប់ឲ្យបង្អត់អាហារប្រជាជន ដើម្បីឲ្យប្រជាជនទាមទារអាហារពីអង្គការ ។ អតីតលេខាស្រុកម្នាក់នៅភូមិភាគនិរតីបានសារភាពថាគាត់បានបង្កចលាចលដោយបង្ខំឲ្យប្រជាជននៅតាមសហករណ៍ធ្វើការជាទម្ងន់ដែលបណ្តាលឲ្យមានជំងឺនិងបាត់បង់ជីវិត ។ គាត់សារភាពទៀតថាបានចូលរួមនៅក្នុង "បក្សពលករវៀតណាម" ។ កម្មាភិបាលម្នាក់ទៀតដែលធ្វើការនៅផ្នែកទីផ្សាររបស់រដ្ឋបានសារភាពថា គាត់ទទួលបញ្ជាឲ្យលាក់សម្លៀកបំពាក់ ស្រូវ និងគ្រឿងបរិក្ខារផ្សេងទៀត ។

អ្នកទោសម្នាក់បាននិយាយថា គាត់ត្រូវបានកម្មាភិបាលជាច្រើនណែនាំឲ្យបំផ្លាញផែនការរបស់បក្សក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ ។ កម្មាភិបាលម្នាក់នៅភូមិភាគពាយ័ព្យបានសារភាពថា គាត់បានចូលរួមនៅក្នុងគម្រោងការ "បំផ្លាញផែនការបក្ស" ដោយបំផ្លាញសម្ភារដូចជាកញ្ជើនិងកាំបិត នៅពេលសាងសង់ទំនប់ឬប្រឡាយទឹក ។

កម្មកររោងចក្រត្រូវបានបង្ខំឲ្យសារភាពថាបានបំផ្លាញម៉ាស៊ីន លួចសម្ភារផ្សេងៗ ធ្វើរបស់ក្លែងក្លាយ និងបានចូលរួមផែនការក្បត់ជាមួយសហការី ។ កម្មករអគ្គិសនីបានសារភាពថាបានធ្វើឲ្យប្រព័ន្ធម៉ាស៊ីនមិនដំណើរការ ។ អ្នកបើកបរសារភាពថាបានធ្វើឲ្យមានគ្រោះថ្នាក់ដោយចេតនា ។ កម្មករនៅកំពង់ផែបានសារភាពថាលួចរបស់របរនិងធ្វើឲ្យខូចសម្ភារ ។ ចំណែកឯកម្មកររថភ្លើងសារភាពថាបានធ្វើឲ្យខូចម៉ាស៊ីន ។ បុគ្គលិកផ្នែកពេទ្យសារភាពថាបានចាក់ថ្នាំបំពុលឲ្យអ្នកជំងឺ លួចថ្នាំ និងប្រើប្រាស់

ថ្នាំមិនត្រឹមត្រូវ ។

"ការបំផ្លាញផែនការរបស់បក្ស"រួមមានទាំងអ្នកនៅក្នុងជួរកងទ័ពដែរ ។ ប្រធានផ្នែកភ័ស្តុភារនៃកងពលធំលេខ១៧៤នៅភូមិភាគកណ្តាលសារភាពថា គាត់និងសហការីរបស់គាត់បានពិភាក្សាគ្នារកមធ្យោបាយធ្វើឲ្យប្រជាជននិងកងទ័ពបន្ថយការសាងសង់ទំនប់ទឹក ។ ក្រុមរបស់គាត់បានរុះរើផ្ទះថ្មីដើម្បីយកឈើធ្វើជាអុសដុត ដោយទុកផ្ទះចាស់ៗឲ្យអង្គការ ហើយបានបំផ្លាញដំណាំអស់មួយហិកតា ។ អនុប្រធានអគ្គសេនាធិការម្នាក់បានសារភាពថា ហេតុការណ៍ភ្លើងឆេះទូកដឹកប្រេងគឺបណ្តាលមកពីការផ្ទុះអាគុយជាជាងដោយសារសកម្មភាពក្បត់ ។ អំពើចោរកម្ម ការធ្វើឲ្យខូចផ្លូវថ្នល់ និងការគោះទ្វារផ្ទះប្រជាជននៅពេលយប់ គឺជាផ្នែកមួយនៃផែនការប្រឆាំងនឹងបដិវត្តន៍ ។

ភាគច្រើននៃអ្វីដែលថ្នាក់ដឹកនាំមើលឃើញថាជាសកម្មភាពក្បត់បានឆ្លុះបញ្ចាំងអំពីការមិនសប្បាយចិត្តជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ សមាជិកបក្សបាននិយាយថាក្បត់នឹងបក្សដោយសារតែមិនសប្បាយចិត្តចំពោះផែនការរបស់បក្ស ។ កងទ័ពម្នាក់បាននិយាយថា "ប្រសិនបើអ្នកធ្វើបដិវត្តន៍សង្គមនិយម ម្ហូបអាហារមិនមានរសជាតិទេ ហើយអ្នកត្រូវធ្វើការឥតឈប់ឈររហូតទាល់តែមនុស្សក្មេងៗដួលសន្លប់នៅនឹងកន្លែងធ្វើការ ។ អ្នកត្រូវធ្វើការទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាក ហើយគ្មានសេរីភាពទាល់តែសោះ... ។ នៅពេលអ្នកធ្វើបដិវត្តសង្គមនិយម គ្មានប្រាក់បៀវត្ស គ្មានឋានៈបុណ្យសក្តិ គ្មានស្រី គ្មានស្រា គ្មានល្បែង គ្មានឡាន" ។ នៅក្នុងកងពលធំលេខ៨០១ ខ្មាំងនិយាយថាបានលើកទឹកចិត្តប្រជាជននៅការដ្ឋានឲ្យខ្ជិលច្រអូសនិងលួចសម្ភារ ដោយនិយាយថា "ប្រសិនបើអ្នកហូបមិនឆ្អែត អ្នកនឹងគ្មានកម្លាំងធ្វើការទេ" ។ ខ្មាំងបានបន្តឲ្យប្រជាជនមានពេលឈប់សម្រាក ដើរលេងជិតៗ និយាយអ្វីដែលចង់និយាយ និងរត់ចោលជួរកងទ័ពនិងសហករណ៍ ។ នៅក្នុងកងពលធំលេខ៣១០មានការរំដើបរំជួលដោយសារកងទ័ពគិតថាការធ្វើបដិវត្តន៍សង្គមនិយមមានន័យថាហូបបបរជាមួយត្រកួន ហើយនៅពេលដែលយើងឈានទៅដល់កុម្មុយនិស្តយើងនឹងហូបត្រកួនសុទ្ធតែម្តង ។ អ្នកនេសាទម្នាក់បាននិយាយថា "បដិវត្តន៍សង្គមនិយមអ៊ីអ៊ីចឹង ស៊ីបបរាវកក្ដួកហ្នឹង!" ។ យុទ្ធជនម្នាក់បាននិយាយដោយត្រង់ៗថា "អង្គការឆ្កួត" ។

យុទ្ធជនទាំងឡាយបានប្រៀបធៀបជោគវាសនារបស់ខ្លួនទៅនឹងជោគវាសនារបស់យុទ្ធជនវៀតណាមបន្ទាប់ពីទទួលជោគជ័យលើសង្គ្រាម ។ នៅប្រទេសវៀតណាម អតីតយុទ្ធជនត្រូវបានអនុញ្ញាតឲ្យសម្រាកនិងទៅសួរសុខទុក្ខក្រុមគ្រួសារ ។ ប៉ុន្តែនៅកម្ពុជា ភ្លាមៗបន្ទាប់ពីសង្គ្រាម យុទ្ធជនទាំងអស់ត្រូវបានបង្ខំឲ្យទៅធ្វើស្រែចម្ការ ។ ខ្មាំងចោទប្រកាន់ថាបានធ្វើឲ្យប្រជាជនរំដើបរំជួលតាមរយៈការឃោសនាអំពី "ឋានៈ បុព្វសិទ្ធិ និងប្រាក់បៀវត្ស ដែលប្រជាជនវៀតណាមនិងឡាវទទួលបាន ចំណែកឯបដិវត្តន៍កម្ពុជាមិនទទួលបានរបស់ទាំងអស់នោះទេ" ។ កងពលធំលេខ៨០១បានរាយការណ៍ថា យុទ្ធជនម្នាក់បាននិយាយថា "បដិវត្តន៍របស់យើងតឹងរ៉ឹងនិងលំបាកខុសពីបដិវត្តន៍នៅប្រទេសវៀតណាមនិងឡាវ" ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច វ៉ន វ៉េត បានសារភាពថា ទស្សនៈយកគំរូតាមសង្គមនិយមចិនត្រូវបានផ្សព្វផ្សាយទៅក្នុងចំណោមប្រជាជន ជាពិសេសនៅភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ និងភូមិភាគឦសាន ។

## គ) សេចក្តីសម្រេចចិត្តក្នុងការដោះស្រាយបញ្ហា

មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបាននិយាយថា បញ្ហាប្រជាជនត្រូវតែដោះស្រាយ ប្រសិនបើមិនដូច្នោះទេប្រជាជនប្រាកដជាខ្វះខាតអាហារមិនខាន បើទោះបីជាមានស្រូវគ្រប់គ្រាន់ក៏ដោយ ។ នេះនឹងបង្ហាញថានរណាជាមនុស្សល្អ ហើយនរណាជាមនុស្សអាក្រក់ ។

ការងារសន្តិសុខនៅតាមមូលដ្ឋាននឹងត្រូវពឹងផ្អែកលើប្រជាជននៅក្នុងសហករណ៍ ដែលនៅទីនោះអាជ្ញាធរបានពឹងផ្អែកជាសំខាន់ទៅលើឈ្លបនិងអ្នកភូមិដើម្បីរាយការណ៍អំពីអ្នកនៅភូមិជាមួយគ្នា ។

បក្សត្រូវតែមានវត្តមាននៅក្នុងសហករណ៍ដើម្បីផ្តល់ការដឹកនាំដែលដាច់ខាតនិងមានល្បឿនលឿន ។ មនុស្សជាច្រើនទៀតនឹងត្រូវទទួលឲ្យចូលជាសមាជិកបក្ស ហើយកម្មាភិបាលនឹងទទួលបានការអប់រំបន្ថែមដើម្បីទទួលជ័យជម្នះលើ"គ្រួសារ

និយម បងប្អូននិយម និងញាតិសន្តាននិយម» ។ ក្នុងឆ្នាំ១៩៧៧ សមាជិកភាពរបស់បក្សបានកើនឡើងទ្វេដង សូម្បីតែប្រជាជនថ្មីក៏ក្លាយសមាជិកបក្សដែរ ។ បន្ទាប់ពីត្រួតពិនិត្យប្រវត្តិរូបរបស់ប្រជាជនថ្មីទាំងនេះតាំងពីកំណើតមក អត្រាការបញ្ជូនអ្នកទាំងនោះទៅអប់រំថែមទៀត ។

សេវាសន្តិសុខត្រូវបានលើកទឹកចិត្តឲ្យចេញជាបញ្ជាថា នៅទីណាដែលមានរឿងអាក្រក់កើតឡើងឬសម្រេចមិនបានតាមផែនការ ទីនោះមានខ្មាំង ។ ការបោសសម្អាតខ្មាំងទាំងនេះនឹងធ្វើឲ្យមានការបោះជំហានទៅមុខយ៉ាងលឿន ។ មេដឹកនាំបក្សបានដាក់ចេញនូវទស្សនៈមួយថាមានការរួមគំនិតក្បត់យ៉ាងរីករាលដាលនៅក្នុងជួរបក្ស ។ ប៉ុល ពត និយាយថា មានជំងឺនៅក្នុងបក្ស ។ មេដឹកនាំបក្សបាននិងកំពុងតែស្វែងរកមេរោគ ប៉ុន្តែមិនទទួលបានជោគជ័យ ដោយសារតែមេរោគទាំងនោះវាកប់នៅជ្រៅ ។ ប៉ុន្តែប៉ុលពតបាននិយាយទៀតថា «ត្រូវតែស្រាវជ្រាវរកនៅគ្រប់ច្រកល្ហករបស់បក្សទាំងអស់ នៅក្នុងជួរប្រជាជននិងក្នុងជួរកងទ័ព» ដើម្បីបោសសម្អាតចេញពីបក្ស ។

សុន សេន បាននិយាយថា បណ្តាញខ្មាំងសំខាន់ៗពីរដែលរួមគំនិតក្បត់ដើម្បីផ្តួលរំលំបក្សកុម្មុយនិស្តកម្ពុជាគឺ «បណ្តាញសេ.អ៊ី.អា តៃវ៉ាន់ បារាំង និងចក្រពត្តិអាមេរិក» និង «បណ្តាញសេរីនិយមវៀតណាមនិងសូវៀត» ។ សុន សេន បានបន្ថែមទៀតថា «ជារួម សេ.អ៊ី.អានិងក្រុមសេរីនិយមគឺដូចតែគ្នា» ។ អត្រានៃការចាប់ខ្លួនបានកើនឡើងយ៉ាងខ្ពស់នៅចុងឆ្នាំ១៩៧៦ ។

ការបោសសម្អាតត្រូវធ្វើមួយភូមិភាគម្តង ។ ការបោសសម្អាតបានចាប់ផ្តើមធ្វើនៅភូមិភាគពាយ័ព្យបន្ទាប់ពីការរាយការណ៍របស់ អៀង ធីរិទ្ធ ។ នៅខែមេសានិងឧសភាឆ្នាំ១៩៧៧ មានការបញ្ជូនកម្មាភិបាលនៅភូមិភាគពាយ័ព្យមកគុកទួលស្លែង ។ អ្នកដែលត្រូវចាប់ខ្លួនខ្លះមានទំនាក់ទំនងជាមួយក្រុមបញ្ញវន្ត ហើយអ្នកផ្សេងទៀតត្រូវបោសសម្អាតដោយសារបានបំផ្លាញផែនការរបស់បក្ស ។ កម្មាភិបាលដែលត្រូវបានបោសសម្អាតត្រូវបានជំនួសដោយកម្មាភិបាលមកពីភូមិភាគបស្ចិមនិងភូមិភាគនិរតី ហើយការបោសសម្អាតនេះបានធ្វើឲ្យមនុស្សរាប់ម៉ឺននាក់ស្លាប់ ។

កុយ ធួន លេខាភូមិភាគឧត្តរនិងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិង«បណ្តាញក្រុមបញ្ញវន្ត» ត្រូវបានចាប់ខ្លួន ។ អ្នកដែលត្រូវចាប់ខ្លួនបន្ទាប់ទៀតនោះគឺកម្មាភិបាលក្រសួងពាណិជ្ជកម្មចំនួន ២៤០នាក់ កម្មាភិបាលកិច្ចការសាធារណៈ១៥៥នាក់ អគ្គសេនាធិការ៨០នាក់ ក្រសួងឧស្សាហកម្មនិងកសិកម្ម៥០នាក់ ក្រសួងការបរទេស៣៧នាក់ មន្ទីរស-២១ ២១៨នាក់ និងរដ្ឋមន្ត្រីក្រសួងពត៌មាន ហ៊ូ នឹម ។ មានសេចក្តីរាយការណ៍ថា បន្ទាប់ពីបានលាតត្រដាងខ្សែរយៈរបស់ កុយ ធួន បញ្ហាសន្តិសុខនិងជីវភាពរបស់ប្រជាជនត្រូវបានដោះស្រាយ ។ ឥឡូវនេះ «ចលនាបដិវត្តន៍អាចបន្តបោះជំហានទៅមុខនៅគ្រប់ផ្នែកទាំងអស់» ។

កងកម្លាំងពីភូមិភាគនិរតីបានចាប់ផ្តើមផ្លាស់ទៅភូមិភាគបូព៌ារួចទៅហើយនៅឆ្នាំ១៩៧៦ ។ បន្ទាប់ពីបរាជ័យរបស់កងទ័ពនៅភូមិភាគបូព៌ាក្នុងការទប់ស្កាត់ការឈ្លានពានរបស់វៀតណាមនៅខែធ្នូឆ្នាំ១៩៧៧ ការបោសសម្អាតបានចាប់ផ្តើមម្តងទៀត ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ វិទ្យុទីក្រុងភ្នំពេញបានចាក់ផ្សាយសេចក្តីអំពាវនាវឲ្យកម្ទេច (សម្លាប់ផ្តាច់ពូជ) ជនជាតិវៀតណាម និង«ធ្វើវិសុទ្ធកម្ម»នៅក្នុងជួរកងទ័ព បក្ស និងប្រជាជន ។ កងទ័ពមកពីភូមិភាគកណ្តាលត្រូវបានបញ្ជូនទៅបោសសម្អាតនៅភូមិភាគបូព៌ា ជាកន្លែងដែល សោ ភឹម ត្រូវបានចោទប្រកាន់ថាបានដឹកនាំ«បក្សពលករ»ខុសច្បាប់មួយដែលបង្កើតដោយវៀតណាមនិងសេ.អ៊ី.អាដើម្បីដណ្តើមអំណាច ។ មានការប្រឆាំងតបវិញខ្លះៗ ប៉ុន្តែមិនមានរយៈពេលយូរទេ ។ សោ ភឹម បានធ្វើអត្តឃាត ។ បន្ទាប់ពីការប្រយុទ្ធចុះអន់ថយ ការសម្លាប់ដើម្បីសងសឹកបានចាប់ផ្តើម ។ ប្រជាជននៅភូមិភាគបូព៌ាមាន«ក្បាលយួនខ្លួនខ្មែរ» ដូច្នេះត្រូវតែកម្ទេចអ្នកទាំងនោះចោល ។ មិនត្រឹមតែចាប់ខ្លួនជនបះបោរនិងក្រុមគ្រួសារប៉ុណ្ណោះទេ អ្នកភូមិទាំងមូលដែលផ្តល់ជម្រកឲ្យជនក្បត់ក៏ត្រូវសម្លាប់ ហើយចំនួនអ្នកស្លាប់ប្រហែលជាច្រើនជាង១០ម៉ឺននាក់ ។ ប្រជាជនប្រមាណ១,៣ត្រូវបានជម្លៀសទៅកាន់តំបន់ដែលមានជំងឺគ្រុនចាញ់នៅភាគខាងលិចប្រទេសកម្ពុជា ដែលក្រោយមកប្រមាណពាក់កណ្តាលនៃប្រជាជនទាំងនេះបានស្លាប់ដោយការប្រហារជីវិត ការអត់ឃ្លាន និងជំងឺ ។

នៅឆ្នាំ១៩៧៧មានការដាក់ចេញនូវបញ្ជាមួយថា ត្រូវតែ

បញ្ជូនជនជាតិវៀតណាមទាំងអស់និងជនជាតិខ្មែរទាំងអស់ដែលចេះនិយាយភាសាវៀតណាមឬមានមិត្តភក្តិជាជនជាតិវៀតណាម ទៅឲ្យកងកម្លាំងសន្តិសុខ ។

នៅខែកក្កដា នួន ជា បានកត់សម្គាល់ថា ខ្មាំងមូលដ្ឋាន និងសមាជិកបក្សដែលមានគ្រោះថ្នាក់ត្រូវបានបោសសម្អាតរួចហើយកាលពី៦ខែដំបូង ។ នៅខែកញ្ញា ប៉ុល ពត បានថ្លែងថា អ្នកដែលប្រឆាំងនឹងបដិវត្តន៍គឺភ្នាក់ងារខ្មាំងមួយក្តាប់តូច ហើយខ្មាំងទាំងនេះត្រូវ"ធ្លាក់ខ្លួនឯកោជាទីបំផុត" ។ ប៉ុល ពត បានអះអាងទៀតថា "នៅពេលដែលបក្សចាប់ខ្លួនខ្មាំងដែលគួរឲ្យស្អប់ខ្ពើម និងបានដោះស្រាយបញ្ហាជីវភាពរួច ប្រជាជនមានក្តីរីករាយនិងសប្បាយចិត្តយ៉ាងខ្លាំងជាមួយបក្ស" ។ ប្រជាជនមិនមានការព្រួយបារម្ភខ្លាចត្រូវសម្លាប់ទៀតទេ ដោយសារតែស្ថានភាពនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរជាងមុន ។

## ៨) សេចក្តីសន្និដ្ឋាន

គោលបំណងនៃការសិក្សានេះគឺស្រាវជ្រាវអំពីយន្តការដែលនាំទៅដល់ការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាជាច្រើននាក់នៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនិស្តកម្ពុជា ។ មូលហេតុនៃការស្លាប់គឺដោយសារតែការអត់ឃ្លាន ការងារហួសកម្លាំង ជំងឺដែលមិនបានទទួលការព្យាបាល និងការសម្លាប់រង្គាល ។

### ក) សេចក្តីសង្ខេប

ដំណើរការប្រល័យពូជសាសន៍បានចាប់ផ្តើមដំណាលគ្នានឹងការផ្ទុះសង្គ្រាមនៅឆ្នាំ១៩៧០ដែរ ។ សេចក្តីសម្រេចចិត្តដើម្បីទទួលបានជ័យជម្នះយ៉ាងឆាប់រហ័សដែល ប៉ុល ពត បានលើកឡើងនៅខែតុលា ប្រហែលជាមានសារសំខាន់នាំដល់ការសម្លាប់មនុស្ស ។ សេចក្តីសម្រេចនេះមិនមែនមានន័យត្រឹមតែដើម្បីឈ្នះសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានន័យថា បក្សកុម្មុយនិស្តកម្ពុជាត្រូវតែគ្រប់គ្រងអំណាច ហើយត្រូវតែលុបបំបាត់ចោលនូវរាល់អ្នកប្រឆាំងជំទាស់ទាំងអស់ ។ នៅពេលប្រកាសជាផ្លូវការអំពី"បដិវត្តប្រជាធិបតេយ្យជាតិ" នៅខែកក្កដាឆ្នាំ១៩៧១ បក្សបានបញ្ជាឲ្យសម្លាប់ភ្នាក់ងាររបស់ខ្មាំងនិងចាត់វិធានការគ្រប់គ្រងប្រជាជន ។ ការសម្លាប់រង្គាលជាលើកដំបូងបំផុតបានចាប់ផ្តើមនៅក្នុងឆ្នាំនោះ ។ មានសញ្ញាណអំពី"ខ្មែរបនីយកម្ម" នៃជនជាតិភាគតិចនៅក្នុងឆ្នាំ១៩៧១-៧២ ដែលនាំទៅដល់ការសម្លាប់រង្គាល ។

នៅក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនិស្តកម្ពុជាបានអនុវត្តនយោបាយនេះនៅទូទាំងប្រទេស ។ មេដឹកនាំបក្សបានសម្រេចចិត្តកសាងសង្គមនិយមភ្លាមៗ ដោយមិនអនុញ្ញាតឲ្យប្រជាជនមានពេលសម្រាកដូចប្រជាជនរបស់ប្រទេសសង្គមនិយមដទៃទៀតទេ ហើយបានបញ្ជាឲ្យប្រជាជនធ្វើកិច្ចការធ្ងន់ធ្ងរជាទីបំផុត ។

### ខ) ផែនការរបស់បក្ស

"ផែនការបួនឆ្នាំរបស់បក្សដើម្បីកសាងសង្គមនិយមលើគ្រប់វិស័យទាំងអស់" គឺជាផែនការឆ្ពោះទៅរកមហន្តរាយ ។ ផែនការនេះកសាងឡើងតាមរយៈគំនិតរវើរវាយដែលមិនមែនជាការពិត ។ មេដឹកនាំបានអះអាងថា បក្សកុម្មុយនិស្តកម្ពុជាបានទទួលជ័យជម្នះយ៉ាងគ្រប់គ្រាន់ដោយមិនមានការលូកដៃចូលពីសំណាក់បរទេសទេ ។ ការអះអាងនេះគឺមិនពិតទាល់តែសោះ ។ មេដឹកនាំទាំងនោះបាននិយាយទៀតថា បក្សកុម្មុយនិស្តកម្ពុជាខុសពីបក្សផ្សេងៗទៀត ហេតុដូច្នេះហើយបក្សនេះមានលទ្ធភាពពិសេសដើម្បីអភិវឌ្ឍប្រទេសលឿនជាងអ្នកណាទាំងអស់ ។ ភាពរុងរឿងនៅក្នុងសម័យអង្គរបានធ្វើឲ្យមេដឹកនាំខ្មែរក្រហមជឿថាប្រជាជនខ្មែរអាចធ្វើអ្វីៗបានទាំងអស់ ។ អង្គការបានប្រយុទ្ធជាមួយម្ចាស់ដីដែលមិនមានរូបរាង ហើយបានធ្វើឲ្យប្រជាកសិករយល់ថាខ្លួនខុសប្លែកពីជនកម្ពុជាដទៃទៀត ។

នៅពេលដែលមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចេញសេចក្តីសម្រេចថាត្រូវតែបង្កើនទិន្នផលស្រូវឲ្យបានផលលើសមុនពាងដងដោយពុំចាំបាច់ប្រើប្រាស់ជីនិងមិនចាំបាច់ប្រើប្រាស់គំនិតរបស់បរទេសនោះ មេដឹកនាំទាំងនោះមិនបានយល់ដឹងអំពីស្ថានភាពដីរបស់ប្រទេសកម្ពុជាទេ ។ មេដឹកនាំទាំងនោះបានផ្តោតគោលនយោបាយរបស់ខ្លួនលើប្រព័ន្ធធារាសាស្ត្រដែលអាចឲ្យការធ្វើស្រែបានលើសមុនចំនួនពីរដង ប៉ុន្តែមិនបានបង្កើនទិន្នផលស្រូវទេ ។ មេដឹកនាំបានប្រគល់បេសកកម្មដែលហួសលទ្ធភាពទៅឲ្យកម្មាភិបាលដែលមានអាយុក្មេងៗនិងមិនមានបទពិសោធន៍នៅក្នុងកិច្ចការស្រែចម្ការ ។ "គោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យ" ទំនងជាបរាជ័យរួចទៅហើយ ។

ទិសដៅដ៏ធំសម្បើមក្នុងការនាំស្រូវចេញទៅក្រៅប្រទេសរបស់ផែនការ៤ឆ្នាំបានធ្វើឲ្យប្រជាជនខ្វះខាតអាហារ ដោយសារប្រជាជនមិនអាចផលិតស្រូវបានច្រើនតាមផែនការកំណត់ ។ លទ្ធផលនោះបានបណ្តាលឲ្យប្រជាជនជួបប្រទះភាពអត់ឃ្លាន ។

ការលើកទឹកចិត្តឲ្យការអនុវត្តផែនការនេះគឺដើម្បីកុំឲ្យប្រទេសកម្ពុជាធ្លាក់ទៅក្រោមឥទ្ធិពលរបស់វៀតណាមជាលើកទីពីរ ។ រូបិយវត្ថុត្រូវបានលុបបំបាត់ដើម្បីការពារកុំឲ្យសង្គមដ៏ស្អាតស្អំរបស់បក្សកុម្មុយនិស្តកម្ពុជាក្លាយទៅជា «វៀតណាម» ។ ប្រសិនបើមានទីផ្សារនោះនឹងមាន «ទីក្រុង ចលាចល និងទាសភាព» ។ មូលហេតុនៃការបង្កើតសហករណ៍គឺដើម្បីការពារកុំឲ្យ«លក្ខណៈចក្រពត្តិនិយម»និងការសេរីនិយមកើតឡើងសាជាថ្មី ។ បច្ចេកវិទ្យារបស់បរទេសនឹងនាំមកនូវគ្រោះថ្នាក់ដល់អាយុជីវិតរបស់បក្ស ។

បក្សកុម្មុយនិស្តកម្ពុជាមើលឃើញសតិអារម្មណ៍នយោបាយជាកត្តាសំខាន់បំផុត ។ ប៉ុន្តែ«កម្លាំងរបស់ប្រជាជន»មិនមែនកើនឡើងដោយសារបញ្ជាពីមជ្ឈិមទេ ។ ផែនការបានសរសេរថា បក្សត្រូវតែរួបរួមគ្នា បើមិនដូច្នោះទេផែនការមិនអាចដើរទៅមុខបានឡើយ ហើយអ្វីៗទាំងអស់នឹងបរាជ័យជាមិនខាន ។ ប៉ុន្តែបក្សមិនបានរួបរួមគ្នាទេ ហើយក៏មិនដែលធ្លាប់រួបរួមគ្នាដែរ ។ ការខ្វែងគំនិតគ្នាត្រូវបានមើលឃើញយ៉ាងច្បាស់រួចទៅហើយតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ហើយក្រោយមកមេដឹកនាំកំពូលៗមួយចំនួនតូចនិងសមាជិកបក្សថ្នាក់ក្រោមជាច្រើនបានជំទាស់ទៅនឹងសេចក្តីសម្រេចជាយុទ្ធសាស្ត្រខ្លះៗរបស់បក្ស ។ នៅក្នុងពេលសង្គ្រាម កងទ័ពនៅតាមភូមិភាគផ្សេងៗបានប្រយុទ្ធនៅតាមទិសដៅផ្សេងៗគ្នា ហើយបន្ទាប់ពីទទួលបានជ័យជម្នះ កងទ័ពទាំងអស់ត្រូវបានដាក់បញ្ចូលគ្នាឲ្យនៅក្រោមបញ្ជារបស់មជ្ឈិម ។ ការណ៍នេះបាននាំទៅដល់ការបោសសម្អាតយ៉ាងរីករាលដាល ។

បញ្ជារបស់មជ្ឈិមជាបញ្ជាដែលត្រឹមត្រូវជាទីបំផុត ហើយដោយសារតែកម្មាភិបាលក្មេងៗរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានបញ្ចូលមនោគមវិជ្ជាឲ្យគិតថា «អង្គការ» មិនចេះភ្លាំងភ្លាត់ កម្មាភិបាលទាំងនោះបានទម្លាក់កំហុសទាំងអស់ទៅលើបុគ្គល ។ សេចក្តីសម្រេចក្នុងការពឹងផ្អែកលើប្រជាជនដើម្បីបកអាក្រាតខ្មាំងបានផ្តល់ជាសញ្ញាទៅឲ្យកម្មាភិបាលនៅតាមមូលដ្ឋានថា អ្នកទាំងនោះអាច«កម្ទេច»ប្រជាជនដោយមិនមានទោស ។ នៅក្នុងនេះក៏មានធាតុផ្សំបែបវប្បធម៌នៃការសងសឹកជ្រុលហួសហេតុដែរ ។

គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាមានលក្ខណៈខុសគ្នាខ្លះៗទៅនឹងទ្រឹស្តីរបស់ម៉ាក្ស-លេនីន ។ ប៉ុន្តែទស្សនៈរបស់ ម៉ាក្ស អំពីវណ្ណៈ ត្រូវបានផ្លាស់ប្តូរទៅជាការតស៊ូរវាងកម្មសិទ្ធិរួមនិងកម្មសិទ្ធិផ្ទាល់ខ្លួន ។ ការបកស្រាយសាជាថ្មីអំពីទស្សនៈសម្ភារនិយមបានបន្សល់ទុកនូវការយល់ឃើញដែលថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានការចងចាំស្រពេចស្រពិលអំពីសៀវភៅដែលខ្លួនបានអានកាលពី២៥ឆ្នាំមុន ។

ពិតជាចម្លែកណាស់ដែលរូបិយវត្ថុរបស់កម្ពុជាត្រូវបានកំណត់តម្លៃទៅតាមប្រាក់ដុល្លាររបស់សហរដ្ឋអាមេរិក និងនៅពេលដែលការដោះដូរទំនិញនៅក្នុងស្រុកត្រូវបានកំណត់តម្លៃដូចទៅនឹងតម្លៃទីផ្សារពិភពលោក ។ ទង្វើនេះមិនសមគ្នាទាល់តែសោះជាមួយនឹងការពឹងផ្អែកលើខ្លួនឯងរបស់បក្សកុម្មុយនិស្តកម្ពុជា និងជាមួយនឹងនិក្ខេបបទនៅឆ្នាំ១៩៥៩របស់ ខៀវ សំផន និងទ្រឹស្តីប្រព័ន្ធពិភពលោក ។

នៅពេលដែលមើលឃើញអំពីបរាជ័យ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមិនបានរៀបចំគោលនយោបាយរបស់ខ្លួនសាជាថ្មីទេ ផ្ទុយទៅវិញ បែរជាបញ្ជាឲ្យតាមរក «អ្នកបំផ្លាញផែនការ» និងភ្នាក់ងារបរទេស ដើម្បីកម្ទេចចោលដើម្បីឲ្យផែនការបានទទួលជោគជ័យទៅវិញ ។ មេដឹកនាំទាំងនោះបានបញ្ជាឲ្យមានការតស៊ូវណ្ណៈ និងបានគំរាមថា អ្នកដែលមិនអាចផលិតបានផល «៣តោនក្នុងមួយហិកតា» គឺជាសត្រូវរបស់វណ្ណៈដែលត្រូវតែកម្ទេចចោល ។

## ក) បុរេល័ក្ខខ័ណ្ឌនៃអំពើប្រល័យពូជសាសន៍

បុរេល័ក្ខខ័ណ្ឌនៃអំពើប្រល័យពូជសាសន៍ដែលបានលើកឡើងនិងបានរៀបចំដោយ ហ្វេន គឺមានវត្តមាននៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ សង្គមកម្ពុជាជាសង្គមចម្រុះជាតិពន្ធ មានប្រពៃណីប្រើប្រាស់ហិង្សា និងមិនចង់ឲ្យបរទេសលូកដៃចូលក្នុងសង្គមរបស់ខ្លួនទេ ។ អភិជនខ្មែរបានឲ្យនិយមន័យ

ជាតិពន្ធវៀតណាមនៅក្រៅពិភពនៃសីលធម៌ជាយូរមកហើយ ។

ជាតិពន្ធវៀតណាមត្រូវបានសម្លាប់រង្គាលនៅក្នុងសតវត្សរ៍ទី១៩និងទសវត្សរ៍ឆ្នាំ៧០នៃសតវត្សរ៍ទី២០ ។ បក្សកុម្មុយនិស្តកម្ពុជាបានទទួលយកគំនិតព្រួយបារម្ភចំពោះប្រទេសវៀតណាមពីអតីតជនទាំងនោះ ហើយការព្រួយបារម្ភនេះបានកើនឡើងនៅពេលដែលបក្សនេះបានក្លាយជាអ្នកដែលពឹងផ្អែកទៅលើវៀតណាមខាងជើងដែលប្រព្រឹត្តចំពោះខ្លួនតាមមធ្យោបាយឧបត្ថម្ភដូចដែលរាជាធិរាជវៀតណាមធ្លាប់បានប្រព្រឹត្តចំពោះកម្ពុជាកាលពីអតីតកាលដែរ ។

ទិដ្ឋភាពមួយផ្សេងទៀតនៅក្នុងសង្គមកម្ពុជានៅមុនពេលមានសង្គ្រាមគឺ ការបាក់បែករវាងជនបទខ្មែរនិងទីក្រុងដែលពោរពេញទៅដោយជនបរទេស ។ ការបាក់បែកនេះកាន់តែធ្ងន់ធ្ងរថែមទៀតនៅពេលមានសង្គ្រាម ដែលនៅពេលនោះអ្នកធ្វើបដិវត្តបានប្រយុទ្ធតទល់នឹងការទម្លាក់គ្រាប់បែករបស់អាមេរិក ចំណែកសត្រូវរបស់ខ្លួន (អ្នករស់នៅទីក្រុង) រស់នៅយ៉ាងមានសុវត្ថិភាពនៅក្នុងទីក្រុង ។

សង្គ្រាមបានក្លាយជាឱកាសល្អសម្រាប់មន្ត្រីដែលមានឋានៈទាបៗរបស់បក្សកុម្មុយនិស្តកម្ពុជាដើម្បីឡើងទៅកាន់តំណែងធំៗនៅក្នុងស្ថានភាពនៃការកាប់សម្លាប់គ្នានៅក្នុងបក្ស និងការធ្លាក់ចុះនៃសង្គម ។ បក្សនេះបានក្លាយទៅជាប្រព័ន្ធផ្តាច់ការជាទីបំផុត ។ បក្សនេះមានមហិច្ឆិតាដណ្តើមយកមកវិញនូវទឹកដីដែលបាត់បង់ ជាពិសេសគឺទឹកដីកម្ពុជាក្រោម ។

ការបំផ្លិចបំផ្លាញត្រូវបានរៀបចំដោយបក្ស ដែលមានមូលដ្ឋានពឹងផ្អែកយ៉ាងសំខាន់លើសន្តិសុខយោធា ។ ប្រធានបទសំខាន់នៃផែនការគឺប្រឆាំងនឹងសត្រូវនៅក្នុងភូមិភាគបូព៌ានិងបស្ចិម ជាពិសេសគឺភូមិភាគបូព៌ា ពោលគឺវៀតណាម ។ កម្ពុជាប្រជាធិបតេយ្យត្រូវតែអនុវត្តនយោបាយ“មហាលោតផ្លោះ” និងបង្កើនកម្រិតជីវភាពរបស់ប្រជាជនបានឆាប់រហ័ស ព្រោះខ្មាំងនៅក្នុងបក្សមានកម្លាំងខ្លាំងក្លាជាងខ្មាំងមកពីខាងក្រៅ ។ ដើម្បីលុបបំបាត់ខ្មាំងទាំងនេះ បក្សកុម្មុយនិស្តកម្ពុជាមានកម្មាភិបាលនិងកងទ័ពជាម៉ាស៊ីនសម្លាប់មនុស្ស ដែលជ្រើសរើសក្នុងពេលសង្គ្រាម ។ កងទ័ពក្មេងៗជាច្រើនរៀនវិធីសម្លាប់មនុស្សដូចនៅក្នុងប្រទេសរ៉ាន់ដា ម៉ូហ្សំប៊ិក និងបដិវត្តន៍វប្បធម៌របស់ចិន ។

បក្សកុម្មុយនិស្តកម្ពុជាមិនបានដាក់បញ្ចូលក្រុមមួយចំនួនទៅក្នុងកាតព្វកិច្ចរបស់ខ្លួនទេ ។ ក្រុមទាំងនោះរួមមាន កងទ័ពមន្ត្រីរាជការស៊ីវិល និងក្រុមគ្រួសារនៃរដ្ឋាភិបាលដែលចាញ់សង្គ្រាម អ្នកទីក្រុង (ប្រជាជនថ្មី) បញ្ញវន្ត និងអ្នកដទៃទៀតដែលត្រូវបានបំពុលដោយគំនិតរបស់បរទេស ក្រុមជាតិពន្ធដែលមិនមែនជាខ្មែរ ជាពិសេសវៀតណាម ចិន និងអ្នកដែលមាន“ក្បាលយួនខ្លួនខ្មែរ” ។ នៅទីបញ្ចប់ អ្នកទាំងឡាយដែលប្រឆាំងនឹងគោលនយោបាយរបស់បក្សកុម្មុយនស្តកម្ពុជាមិនត្រូវបានរាប់បញ្ចូលទៅក្នុងវណ្ណៈកម្មករ-កសិករទេ ទោះបីអ្នកទាំងនោះបដិសេធមិនចង់ក្លាយជាជនជាតិខ្មែរ ប្រតិបត្តិសាសនា ឬក៏គ្រាន់តែជាកសិករខ្មែរដែលសម្តែងការមិនពេញចិត្តចំពោះបក្សកុម្មុយនិស្តកម្ពុជាដោយសារតែខ្លួនបានបាត់បង់ក្រុមគ្រួសារ ដីធ្លីនិងវត្តអារាមក៏ដោយ ។ អ្នកទាំងឡាយដែលមិនគោរពឬខកខានមិនបានបំពេញតាមបញ្ជារបស់អង្គការនឹងក្លាយជាខ្មាំង ហើយជាលទ្ធផលគឺ “ការប្រល័យពូជសាសន៍ខ្លួនឯង” ។

បក្សកុម្មុយនិស្តកម្ពុជាគ្មានហេតុផលដើម្បីភ័យខ្លាចការសងសឹកពីកសិករដែលជានិច្ចកាលតែងតែ“ឱនលំទោន” ឬក៏ការសងសឹកពីពិភពលោកខាងក្រៅនោះទេ ដោយសារតែកម្ពុជាប្រជាធិបតេយ្យមានអ្នកគាំទ្រដ៏មានអំណាចគឺប្រទេសចិនដែលមើលទៅហាក់បីដូចជាអ្នកការពារកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងវៀតណាម ។

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាខុសប្លែកខ្លះៗពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្សេងទៀត ។ កម្ពុជាប្រជាធិបតេយ្យមិនមែនជាអ្នកចាញ់សង្គ្រាមដូចជាអាល្លឺម៉ង់និងទួរគីទេ ។ ការប្រកាន់ពូជសាសន៍របស់បក្សកុម្មុយនិស្តកម្ពុជាខុសគ្នាពីការប្រកាន់ពូជសាសន៍របស់ណាហ្ស៊ីដែលដាក់ឲ្យជនជាតិជ្វីហ្វនៅដាច់ដោយឡែក ។ បក្សនេះប៉ុនប៉ងដាក់បញ្ចូលជនជាតិភាគតិចដោយអនុវត្តទាំងបង្ខំនូវ“ខ្មែរូបនីយកម្ម” ។

សំណួរមួយដែលមិនមានចម្លើយនោះគឺថា តើមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាត្រូវបានលើកទឹកចិត្តដោយការភ័យខ្លាចចំពោះវៀតណាម ឬក៏ប្រើអារម្មណ៍ប្រឆាំងនឹងជនជាតិវៀតណាម

ដើម្បីប្រមូលកងទ័ព? សម្តេច សីហនុ បានមានព្រះបន្ទូលអំពីសេចក្តីថ្លែងការណ៍មួយរបស់ ខៀវ សំផន ដែលថា «ដើម្បីបង្រួបបង្រួមអ្នកស្នេហាជាតិនៅក្នុងបក្សទាំងមូលរបស់យើង ដើម្បីធ្វើឲ្យកម្មករអាចផលិតបានដល់កម្រិតខ្ពស់បំផុត និងដើម្បីឲ្យកងទ័ពមានឥទ្ធិពលនិងសេចក្តីក្លាហានក្នុងការប្រយុទ្ធកាន់តែខ្លាំងក្លាជាងមុនថែមទៀត កិច្ចការល្អបំផុតដែលយើងត្រូវធ្វើនោះគឺញុះញង់អ្នកទាំងអស់នោះឲ្យកាន់តែស្អប់ជនជាតិវៀតណាមពីមួយថ្ងៃទៅមួយថ្ងៃ ។ កម្មាភិបាលស្ម័គ្រចិត្តបូជាអ្វីៗទាំងអស់នៅគ្រប់នាទីដែលខ្លួនគ្រវីទង់ជាតិស្អប់វៀតណាម» ។

ការប្រមាថអាចជាការពន្យល់មួយ ។ ពាក្យ «ទាសភាព» បានលេចចេញជាញឹកញាប់នៅក្នុងអត្ថបទរបស់បក្សកុម្មុយនិស្តកម្ពុជា ។ នៅកម្ពុជា ការប្រមាថមើលងាយជាតិមានន័យថាជារណបរបស់វៀតណាម ។ ការប្រមាថមានទំនាក់ទំនងទៅនឹងការសងសឹក ។ បក្សកុម្មុយនិស្តកម្ពុជាបានប្រើប្រាស់ការឈឺចាប់របស់សង្គមនិងបទពិសោធន៍ដែលធ្លាប់ជាជនរងគ្រោះនៃការទម្លាក់គ្រាប់បែកដើម្បីប្រមូលកសិករក្រីក្រប្រឆាំងនឹងអ្នកមាន និងអ្នកទីក្រុង និងបានជ្រើសរើសកូនចៅរបស់កសិករក្រីក្រទាំងនោះធ្វើជាកងទ័ពនិងឲ្យកាន់តំណែងដឹកនាំ ។

ការប្រមាថមើលងាយជាតិអាចជាកត្តាមួយដែលត្រូវបានមើលរំលងនៅក្នុងដំណើរការប្រល័យពូជសាសន៍ ។ ណាហ្ស៊ីអាល្លឺម៉ង់គឺជាឧទាហរណ៍មួយ ។ អ៊ីត្លែរ មានការអាក់អន់ចិត្តជាខ្លាំងចំពោះការចាញ់សង្គ្រាមលោកលើកទីមួយរបស់អាល្លឺម៉ង់និងការប្រមាថលើសន្ធិសញ្ញាវែរសៃ ។ ស្លូបូដាន មីឡូសេវិក បានប្រមូលការគាំទ្រដោយប្រើប្រាស់អារម្មណ៍ចាញ់សង្គ្រាមរបស់ជនជាតិស៊ែបនៅកូសូវ៉ូនិងការបាត់បង់កូសូវ៉ូដែលជាកន្លែងផ្តល់កំណើតដល់ជនជាតិស៊ែប ។ នៅរ្វ៉ាន់ដា ជនជាតិហ៊ូទូមានអារម្មណ៍ថាខ្លួនឯងត្រូវបានកេងប្រវ័ញ្ចផលប្រយោជន៍ ។ នៅក្នុងចំណោមគហបតីអាហ្វ្រិក អាណានិគមនិយមបានបន្សល់ទុកនូវភាពជូរចត់យ៉ាងខ្លាំង ។

### ឃ) ការប្រៀបធៀបទៅនឹងករណីមិនមែនប្រល័យពូជសាសន៍

បុរេល័ក្ខខ័ណ្ឌខ្លះៗនៃអំពើប្រល័យពូជសាសន៍ក៏មានវត្តមាននៅក្នុងប្រទេសវៀតណាមដែរ ។ បក្សម៉ាក្ស-លេនីនដែលជាបក្សកុម្មុយនិស្តវៀតណាមបានបង្កើតនូវការគ្រប់គ្រងផ្តាច់ការដែលដាក់ឲ្យអនុវត្តនៅទូទាំងប្រទេសនៅក្នុងឆ្នាំ១៩៧៥ ។ បក្សនេះបានពឹងផ្អែកយ៉ាងខ្លាំងទៅលើសន្តិសុខយោធា ។ សមាជិកភាគច្រើនរបស់បក្សត្រូវជ្រើសឲ្យធ្វើកងទ័ព ។ សត្រូវរបស់បក្សនេះបានរស់នៅយ៉ាងមានសុវត្ថិភាពនៅក្នុងទីក្រុងខណៈពេលដែលជនបដិវត្តកំពុងតែប្រយុទ្ធនៅតាមជនបទដែលទទួលរងនូវការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរ ។ ហេតុដូច្នេះហើយទើបជនបដិវត្តមានមូលហេតុដើម្បីសងសឹក ។ សង្គ្រាមបានធ្វើឲ្យស្ថានភាពនៅវៀតណាមខាងត្បូងពោរពេញទៅដោយជម្លោះផ្ទៃក្នុងនិងការធ្លាក់ចុះនៃសង្គម ។ មេដឹកនាំបក្សកុម្មុយនិស្តវៀតណាមត្រូវបានលើកទឹកចិត្តដោយជ័យជម្នះ និងបានធ្វើផែនការសេដ្ឋកិច្ចដែលមិនពិតទាំងស្រុងមួយដើម្បីឲ្យវៀតណាមក្លាយជារដ្ឋមួយដែលមានកសិកម្មនិងឧស្សាហកម្មទំនើបក្នុងរយៈពេល២០ឆ្នាំ ។ មេដឹកនាំបក្សកុម្មុយនិស្តវៀតណាមក៏ជួបប្រទះនឹងបញ្ហាក្នុងការថែរក្សាអំណាចប្រឆាំងនឹងការគំរាមកំហែងក្នុងស្រុកនិងបរទេស ។ វៀតណាមមានជនជាតិភាគតិចជាច្រើន ហើយជនជាតិភាគតិចចិនត្រូវបានដាក់ឲ្យរស់នៅដោយឡែក ។ នៅពេលដែលជម្លោះជាមួយចិនបានកើនឡើងបន្ទាប់ពីឆ្នាំ១៩៧៥ ជនជាតិចិននៅវៀតណាមត្រូវបានមើលឃើញថាជាកម្លាំងទីប្រាំ ហើយត្រូវបានដកចេញពីកាតព្វកិច្ចរបស់បក្សកុម្មុយនិស្តវៀតណាមដូចជាមន្ត្រីនៃរដ្ឋាភិបាលដែលចាញ់សង្គ្រាមនិងពាណិជ្ជករកុំប្រាដ័រដែរ ។ ប៉ុន្តែបក្សមិនបានសម្លាប់ជនជាតិចិនទាំងនោះទេ ។

ផ្ទុយគ្នាពីបក្សកុម្មុយនិស្តកម្ពុជា បក្សកុម្មុយនិស្តវៀតណាមមានហេតុផលដែលត្រូវតែភ័យខ្លាចការសងសឹក ។ កសិករជនជាតិវៀតណាមមិនដែល«ឱនលំទោន»ទេ ប៉ុន្តែតែងតែ«ងើបឈរប្រឆាំង» ជានិច្ច ហើយប្រទេសចិនគឺជាការគំរាមកំហែងមួយយ៉ាងធំ ។

នៅមានចំណុចខុសគ្នាផ្សេងៗទៀត ។ ប្រវត្តិសាស្ត្រគឺជាចំណុចខុសគ្នាមួយ ។ នៅខណៈពេលដែលប្រវត្តិសាស្ត្របានធ្វើឲ្យកម្ពុជាទទួលរងការប្រមាថមើលងាយជាតិ វៀតណាមបែរជាមានមោទកភាពជាតិទៅវិញ ដោយហេតុថាខ្លួនបានបណ្តេញបរទេស (ភាគច្រើនគឺជនជាតិចិន) ចេញពីប្រទេសម្តងហើយម្តងទៀត ។

នៅពេលដែលកម្ពុជាគោរពព្រះរាជាដូចជាព្រះអាទិទេពនិងការគ្រប់គ្រងអំណាចបែបមជ្ឈការ វៀតណាមជានិច្ចកាលមានរចនាសម្ព័ន្ធអំណាចបែបទុំកនិយមតាមសុភាសិតដ៏ល្បីមួយ "បញ្ជារបស់ព្រះរាជាត្រូវតែគោរពតាមទំនៀមទម្លាប់របស់ភូមិ" ។

បក្សកុម្មុយនិស្តកម្ពុជាបានបង្កើតសហករណ៍ ដោយគ្មានការប្រឆាំងទាល់តែសោះ ចំណែកឯបក្សកុម្មុយនិស្តវៀតណាមជួបការលំបាកជាច្រើន ហើយនៅទីបញ្ចប់បានបោះបង់ចោលគម្រោងការ ។ បក្សកុម្មុយនិស្តវៀតណាមក៏បានជួបប្រទះការប្រឆាំងនៅក្នុងកិច្ចប្រឹងប្រែងដើម្បីប្រមូលផលស្រូវពីសហករណ៍និងពីកសិករម្នាក់ៗដែរ ។ ការពន្យល់មួយអាចថា ជានិច្ចកាលអ្នកភូមិវៀតណាមត្រូវបានរៀបចំយ៉ាងហ្មត់ចត់ ចំណែកនៅក្នុងប្រទេសកម្ពុជាវិញ ផ្ទះនីមួយៗគឺជាកោះមួយ ។

បក្សទាំងពីរនេះ (បក្សកុម្មុយនិស្តកម្ពុជានិងបក្សកុម្មុយនិស្តវៀតណាម) មានចរិតលក្ខណៈខុសគ្នាខ្លះៗទៀត ។ នៅពេលដែលបក្សកុម្មុយនិស្តកម្ពុជាមានលក្ខណៈជាតិនិយម បក្សកុម្មុយនិស្តវៀតណាមបានបដិសេធលក្ខណៈជាតិនិយមថាជាមនោគមវិជ្ជាគហបតីរបស់លោកខាងលិច ហើយបានចាប់យកទស្សនៈស្នេហាមាតុភូមិជាទស្សនៈដែលមានទំនាក់ទំនងទៅនឹងដីធ្លីនិងការគោរពបូជាដីដូនដីតា ។

សរុបមក នៅពេលដែលប្រឈមមុខនឹងបរាជ័យ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានជ្រើសរើសការស្រាវជ្រាវរកមេរោគដើម្បីបោសសម្អាត ចំណែកមេដឹកនាំបក្សកុម្មុយនិស្តវៀតណាមបានសម្រេចចិត្តពិចារណាចំពោះគោលនយោបាយរបស់ខ្លួនសាជាថ្មី។ នេះជាចំណុចដែលគួរតែពិភាក្សា ។ ការប្រៀបធៀបបុរេល័ក្ខខ័ណ្ឌនៃការដឹកនាំផ្តាច់ការដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍និងមិនមានអំពើប្រល័យពូជសាសន៍អាចផ្តល់នូវការពន្យល់ខ្លះៗ ។

**ម៉ុង សាន់ឃ្វីស**

# មិននិយាយមិនមែនមានន័យថាភ្លេចទេ

៣០ឆ្នាំមុន គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកកាន់កាប់អំណាចនៅប្រទេសកម្ពុជា និងបានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងឲ្យទៅកាន់ទីជនបទស្រុកស្រែចម្ការ ។ ប្រជាជនទាំងអស់ត្រូវតែចាកចេញតាមបញ្ជារបស់អង្គការដោយគ្មានការលើកលែង មិនថាអ្នកនោះមានជំងឺធ្ងន់ធ្ងរ ពិការ ចាស់ជរា ឬត្រូវសម្រាលកូនឡើយ ។ ម៉ាយ៉ាស់ និងប្អូនស្រីរបស់គាត់ឈ្មោះ ខទី ត្រូវកងទ័ពខ្មែរក្រហមវ័យក្មេងៗបណ្តេញចេញពីផ្ទះនៅក្នុងខណៈពេលដែលគាត់ទាំងពីរនាក់កំពុងតែជិតដល់ពេលវេលាសម្រាលកូន ។

កាលណោះគឺនៅម៉ោង៩ព្រឹក ពេលដែលកងទ័ពខ្មែរក្រហមចាប់ផ្តើមបណ្តេញប្រជាជននៅក្នុងភូមិដែល យ៉ាម៉ាស់ រស់នៅគឺភូមិអូរខ្ទាយ (បច្ចុប្បន្នភូមិកំពង់អំពិល) នៅក្នុងឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ។ ប្រជាជននៅក្នុងភូមិរៀបចំវេចសម្លៀកបំពាក់និងរបស់របរប្រើប្រាស់ និងចាប់ផ្តើមចេញដំណើរនៅពេលរសៀល ។ គោលដៅគឺភូមិអូរស្រឡៅដែលមានចម្ងាយប្រមាណ ៦គីឡូម៉ែត្រពីភូមិអូរខ្ទាយ ។ ម៉ាយ៉ាស់ និង ខទី ដឹងខ្លួនថានឹងត្រូវសម្រាលកូនក្នុងពេលដ៏ខ្លីខាងមុខ ប៉ុន្តែគាត់នៅតែមិនហ៊ានសុំអនុញ្ញាតពីកងទ័ពខ្មែរក្រហមទាំងនោះដើម្បីនៅក្នុងផ្ទះរង់ចាំការសម្រាលកូនឡើយ ។ ក្រុមគ្រួសាររបស់គាត់បានរៀបចំអីវ៉ាន់ដើម្បីចាកចេញទៅជាមួយនឹងអ្នកភូមិដែរ ។ ទាំងពីរនាក់ដើរបណ្តើរក្នុងចិត្តគិតបារម្ភបណ្តើរក្រែងលោគាត់ឈឺពោះសម្រាលកូនតាមផ្លូវ ។ ម៉ាយ៉ាស់ និយាយថា "ចិត្តពិបាកដែរភ័យដែរមិនដឹងធ្វើយ៉ាងម៉េចទេ យើងចេះតែទ្រាំទៅមិនដឹងធ្វើម៉េចបើយើងខ្លាចគេ ។ នៅតាមផ្លូវឈប់ខ្លះអីខ្លះទៅ" ។

ក្បួនប្រជាជនដែលមានមនុស្សចំនួនប្រមាណ៥០០-៦០០នាក់ធ្វើដំណើរដោយយឺតៗ ។ រហូតដល់ម៉ោង៩យប់ ក្រុមគ្រួសាររបស់ ម៉ាយ៉ាស់ និង ខទី ធ្វើដំណើរបានតែជាង២គីឡូម៉ែត្រប៉ុណ្ណោះ ។ ពេលនោះ ម៉ាយ៉ាស់ ចាប់ផ្តើមឈឺពោះសម្រាលកូន ។ ប្តីរបស់គាត់បានគ្រាហ៍គាត់ទៅរកដើមឈើធំ និងសុំអនុញ្ញាតពីកងទ័ពខ្មែរក្រហមឲ្យប្រពន្ធបានឈប់ដើម្បីសម្រាលកូន ។ ម៉ាយ៉ាស់

សម្រាលបានកូនស្រីដោយមានឆ្មបបុរាណម្នាក់ជួយ ។ គាត់បានដាក់ឈ្មោះកូនស្រីរបស់គាត់ថា ខរី ។ ប្រមាណបួនប្រាំម៉ោងបន្ទាប់ពី ម៉ាយ៉ាស់ ប្រសូត្ររួច ខទី ជាប្អូនស្រីរបស់គាត់ក៏ឈឺពោះសម្រាលកូនដែរ ។ ពេលនោះឆ្មបបានបន្តដំណើរទៅខាងមុខបាត់ទៅហើយ ដូច្នេះមានតែសមាជិកគ្រួសារតែប៉ុណ្ណោះដែលជួយ ខទី ឲ្យសម្រាលកូន ។ ខទី ប្រសូត្របានកូនប្រុសម្នាក់ដាក់ឈ្មោះថា ហ្រ៊ីតះ ។ ម៉ាយ៉ាស់ និង ខទី ដេកអាំងភ្លើងនៅក្រោមដើមឈើអស់រយៈពេលប្រមាណបីថ្ងៃ ។ ប្តីរបស់គាត់បានដើរកាប់ដើមឈើឫសឈើមកធ្វើថ្នាំដាំឲ្យគាត់ផឹក ។ ម៉ាយ៉ាស់ រំឭកថា “អាំងភ្លើងអាំងអីហ្នឹងអាំងចំហៀងខ្លួនអត់មានគ្រែទេបីថ្ងៃ ។ ហើយកាប់ឫសឈើអីហ្នឹងពីអូរមក មានថ្នាំបុរាណថ្នាំខ្មែរយកមកស្ងោរហូប ។ ប្តីខ្ញុំទៅកាប់ឲ្យ” ។ កម្មាភិបាលខ្មែរក្រហមបានមកមើល ម៉ាយ៉ាស់ និង ខទី ហើយប្រាប់ថា បើគាត់អាចដើរបានគួរតែចេញដំណើរទៅតាមគេតាមឯងហើយ កុំនៅយូរថ្ងៃពេក ។ ពីរបីថ្ងៃក្រោយមក ម៉ាយ៉ាស់ និង ខទី ព្រមទាំងក្រុមគ្រួសារធ្វើដំណើរបន្តទៅភូមិអូរស្រឡៅ ។




ម៉ាយ៉ាស់ និង ខទី មិនហ៊ានទុកកូនតូចនៅមណ្ឌលកុមារទេ ព្រោះបារម្ភក្រែងអ្នកមើលក្មេងបញ្ចុកអាហារដែលមានជាតិសាច់ជ្រូក ។ ដូច្នេះជារៀងរាល់ថ្ងៃ ស្ត្រីទាំងពីរនាក់ផ្លាស់វេនគ្នា ម្នាក់ទៅធ្វើការម្នាក់ទៀតនៅមើលកូនតូចទាំងពីរនៅផ្ទះ ។ រំឭកដល់ពេលនោះ ម៉ាយ៉ាស់ និយាយថា “ដល់៣-៤ខែក្រោយមកបានគេឲ្យចេញទៅដាំចម្ការ អ្នកខ្លះចូលខាងកិនស្រូវបុកអង្ករអីទៅ ។ ខ្ញុំមានកូនតូចដូចគ្នាពីរនាក់បងប្អូនហ្នឹងផ្លាស់គ្នា ។ គេថាបើយើងចេញធ្វើការគេមានចាស់ៗមើលកូន ប៉ុន្តែខ្ញុំខ្លាចយើងមិនមែនអ្នកស៊ីសាច់ស៊ីអី ខ្លាចគេយកមកបញ្ចុកកូនយើង ដូច្នេះទាំងពីរនាក់ផ្លាស់គ្នាមើលកូនម្នាក់ម្តង ។ ម្នាក់ចេញទៅធ្វើពលកម្ម ម្នាក់នៅមើលកូន” ។ ម៉ាយ៉ាស់ គ្មានសង្ឃឹមថាកូនរបស់គាត់រស់ឡើយ ព្រោះគ្មានអាហារបរិភោគគ្រប់គ្រាន់ ហើយគាត់ក៏មិនសូវមានទឹកដោះគ្រប់គ្រាន់ឲ្យកូនបៅទៀត ។ គាត់បារម្ភក្រែងកូនរបស់គាត់មានជំងឺ មិនដឹងបានថ្នាំសង្កូវឯណាមកព្យាបាល ។ គាត់រំលែកទឹកបបរដែលជារបបរបស់គាត់យកមកបញ្ចុកកូន ហើយពីមួយថ្ងៃទៅមួយថ្ងៃកូនរបស់គាត់ក៏ធំធាត់ ។

មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥នេះ ខរី មានអាយុ ៣០ឆ្នាំគត់ ។ គាត់គឺជាកូនទី៦ និងជាកូនពៅនៅក្នុងគ្រួសារ ។ ម៉ាយ៉ាស់ មិនដែលបានរំឭកអំពីកំណើតរបស់កូនគាត់ឡើយ ហើយ ខរី ផ្ទាល់ក៏មិនបានចាប់អារម្មណ៍អំពីកំណើតរបស់គាត់ដែរ ។ ខរី និយាយថា “ខ្ញុំមិនបានចាប់អារម្មណ៍ថាខ្ញុំកើតចំថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលមានសង្គ្រាមទេ ហើយក៏មិនដឹងថាម្តាយខ្ញុំលំបាកយ៉ាងម៉េចដែរ ។ ប៉ុន្តែបើក្រឡេកមើលទៅក្រោយវិញ ទើបខ្ញុំដឹងថាម្តាយខ្ញុំលំបាកណាស់ក្នុងការបង្កើតនិងចិញ្ចឹមខ្ញុំ” ។ ជាងនេះទៅទៀត ខរី ក៏មិនដែលសួរនាំម្តាយ ឬនរណាម្នាក់អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដែរ ។ ក្រុមគ្រួសារទាំងមូលហាក់ដូចជាមិនបាននឹកនាដល់រឿងរ៉ាវនោះទៀតឡើយ ។ ខរី បានទៅសាលារៀន ហើយនៅក្នុងសៀវភៅរៀនអានរបស់គាត់មានអត្ថបទមួយចំនួននិយាយអំពីរបបខ្មែរក្រហម ។ ខរី ឈប់រៀនត្រឹមថ្នាក់ទី៣ ហើយនៅជួយធ្វើកិច្ចការជាមួយម្តាយ នៅផ្ទះនិងរៀនសូត្រធម៌វិន័យសាសនាឥស្លាម ។ ខរី ប្រតិបត្តិសាសនាឥស្លាមយ៉ាងខ្ជាប់ខ្ជួននិងតឹងរ៉ឹង ។ ក្រោយពីបានស្តាប់ម្តាយរៀបរាប់ហេតុការណ៍ប្រសូត្ររូបគាត់ ខរី មានចិត្តចង់ដឹងរឿងរ៉ាវនេះឲ្យបានច្រើនជាងមុន និងចង់ដឹងរឿងរ៉ាវផ្សេងៗទៀតនៅក្នុងរបបខ្មែរក្រហម ។ ខរី បានមើលឃើញសារសំខាន់នៃការនិយាយរឿងរ៉ាវទាំងនេះ ហើយបានសំណូមពរឲ្យមានការសិក្សាអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនៅតាមសាលាដើម្បីឲ្យក្មេងជំនាន់ក្រោយបានរៀនសូត្រនិងបានដឹងអំពីអ្វីដែលកើតឡើងនៅក្នុងរបបមុន ។

មកដល់សព្វថ្ងៃនេះ ម៉ាយ៉ាស់ មានអាយុ៦៧ឆ្នាំហើយ ។ ថ្វីដ្បិតតែគាត់មិនរំឭករឿងរ៉ាវអំពីរបបខ្មែរក្រហម ប៉ុន្តែគាត់នៅតែមិនភ្លេចអ្វីដែលគាត់បានឆ្លងកាត់កាលពីរបបនោះ ។

**សូ ហ្វារីណា**

# វាលពិឃាតបឹងជើងឯក៖ ការចងចាំអំពើប្រល័យពូជសាសន៍នៅកម្ពុជា

*«ទាក់ទងនឹងស្ថានភាពដែលប៉ះពាល់ធ្ងន់ធ្ងរដល់ផ្នែកស្មារតី និងជាពិសេសទាក់ទងនឹងការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅសម័យសង្រ្គាមលោកលើកទីពីរ ការចាត់វិធានការគឺមានសារសំខាន់និងមិនអាចចៀសវាងបាន» ។*

*«កន្លែងដែលយើងកំពុងតែទស្សនានេះជាកន្លែងថែរក្សាការចងចាំ...[អូសវិត្ស] មិនមែនកើតឡើងនៅទីនេះទេ ប៉ុន្តែព័ត៌មានអំពីការសម្លាប់រង្គាលនៅ «អូសវិត្ស» បានរីកសាយភាយទៅពាសពេញពិភពលោក នៅក្នុងការចងចាំទាំងថ្ងៃទាំងយប់របស់ជនរងគ្រោះដែលរស់រានមានជីវិត» ។*



បូជនីដ្ឋានជើងឯក

នៅក្នុង «វេទិកាអន្តរជាតិដើម្បីការពិត យុត្តិធម៌ និងការចងចាំ» ដែលបានប្រារព្ធធ្វើនៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ នៅខែមេសា ឆ្នាំ២០០២ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រាប់ឲ្យដឹងថា សព្វថ្ងៃនេះមជ្ឈ-មណ្ឌលឯកសារកម្ពុជាដឹងថាមានបូជនីយដ្ឋានចំនួន៧៧ នៅក្នុងប្រទេសកម្ពុជាដែលបានកសាងឡើងដើម្បីរំឭកដល់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

វប្បធម៌នៃការចងចាំរបស់ប្រជាជនកម្ពុជាបានចាប់កំណើតឡើងជាពិសេសនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ការចងចាំនេះមិនត្រឹមតែពោរពេញទៅដោយភាពឃោរឃៅហួសហេតុនឹកស្មានមិនដល់ប៉ុណ្ណោះទេ ថែមទាំងមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អារម្មណ៍ ។ ការចងចាំនេះពោរពេញទៅដោយការឈឺចាប់យ៉ាងខ្លាំងរហូតដល់ធ្វើមនុស្សទាំងអស់សូម្បីតែនៅអឺរ៉ុបនិងសហរដ្ឋអាមេរិកក៏បានដឹងអំពីព្រឹត្តិការណ៍នេះដែរ ។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រវត្តិវិទូនិងរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមយកចិត្តទុកដាក់ដល់សារសំខាន់នៃការចងចាំ ។ ជាមួយនឹងការរុះរើចេញកាលពីឆ្នាំ២០០២នូវផែនទីដ៏ល្បីល្បាញដែលធ្វើពីគ្រោងឆ្អឹងលលាដ៍ក្បាលរបស់ជនរងគ្រោះមជ្ឈមណ្ឌលឯកសារកម្ពុជា ហាក់បីដូចជាបានចាប់ផ្តើមចំណាត់ការដំបូងមួយជានិមិត្តរូប ឆ្ពោះទៅអនុវត្តការចងចាំមួយដែលមានតុល្យភាពនិងអត់ខឹង ។

ទោះជាយ៉ាងណាក៏ដោយ វានៅតែមានសារសំខាន់នៅក្នុងការសួរសំណួរថាហេតុអ្វីបានជាវប្បធម៌ចងចាំរបស់កម្ពុជាបានកើតឡើងនៅក្នុងទម្រង់ដូចសព្វថ្ងៃនេះ និងថាតើវប្បធម៌ចងចាំរបស់កម្ពុជានេះមានឥទ្ធិពលខ្លះដែលអាចធ្វើឲ្យមានសុពលភាពនៅថ្ងៃអនាគតដែរឬទេ ។

**វាលពិឃាតបឹងជើងឯក**

បូជនីយដ្ឋានដែលស័ក្តិសមបំផុតសម្រាប់បង្ហាញអំពីវប្បធម៌ចងចាំរបស់កម្ពុជានៃទសវត្សរ៍ឆ្នាំ១៩៨០គឺវាលពិឃាតបឹងជើងឯកដែលស្ថិតនៅចម្ងាយប្រមាណ១៣គីឡូម៉ែត្រ ភាគនិរតីនៃទីក្រុងភ្នំពេញ ។

ចាប់ពីឆ្នាំ១៩៧៧រហូតដល់ចុងឆ្នាំ១៩៧៨ វាលពិឃាតបឹងជើងឯកបានដើរតួនាទីជាវាលពិឃាតនិងជាកន្លែងកប់សាកសពអ្នកទោសមន្ទីរស-២១ដែលបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនៅខែកញ្ញា ឆ្នាំ១៩៧៥ ។ នៅក្រោមរបបនោះ អ្នកទោសប្រមាណ១ម៉ឺន៤៣ពាន់នាក់ ដែលភាគច្រើនជាបុរស

ត្រូវបានឃុំឃាំងសួរចម្លើយ ធ្វើទារុណកម្ម និងក្រោយមកប្រហារជីវិត ។ មុនដំបូងការប្រហារជីវិតបានប្រព្រឹត្តទៅនៅក្នុងទីធ្លានៃមន្ទីរឃុំឃាំងដែលជាអតីតសាលារៀនមួយនេះ ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៧ ទីធ្លាសម្រាប់កប់សាកសពនៅក្នុងមន្ទីរឃុំឃាំងនេះមិនមានកន្លែងទំនេរសម្រាប់បន្តដាក់សាកសពទៀតទេ ហើយបឹងជើងឯកដែលជាអតីតឈាបនដ្ឋានជនជាតិចិនត្រូវបានយកមកប្រើប្រាស់ជាវាលពិឃាតនិងជាកន្លែងសម្រាប់កប់សាកសព ។ នៅក្នុងរយៈពេលមិនដល់ពីរឆ្នាំផង បឹងជើងឯកបានក្លាយជាកន្លែងប្រហារជីវិតអ្នកទោសមន្ទីរស-២១ប្រមាណ ១១៣៨៤នាក់ ។ ភាគច្រើននៃអ្នកទោសត្រូវបានប្រហារជីវិតនិងកប់នៅបឹងជើងឯក ចំណែកអ្នកទោសសំខាន់ៗនៅតែត្រូវសម្លាប់នៅក្នុងទីធ្លារបស់មន្ទីរឃុំឃាំងទួលស្លែង ។

នៅក្នុងអំឡុងឆ្នាំ១៩៨០ មួយឆ្នាំបន្ទាប់ពីការចូលកាន់កាប់ទីក្រុងភ្នំពេញរបស់កងកម្លាំងវៀតណាម រណ្តៅសាកសពរួមចំនួន៨៦ក្នុងចំណោមរណ្តៅ១២៩នៅបឹងជើងឯកត្រូវបានរកឃើញនិងគាស់កកាយ ។ គ្រោងឆ្អឹងសាកសពចំនួន៨៩៨៥ ត្រូវបានរកឃើញ ។ គោលបំណងចំពោះមុខនៅពេលនោះគឺដើម្បីពិនិត្យមើលនិងដើម្បីចងក្រងឯកសារឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយមកវាលពិឃាតនេះត្រូវបានបើកបម្រើជូនសាធារណជន ។ លោកវរសេនីយ៍ឯក ម៉ៃ ឡាំ ជាជនជាតិវៀតណាមដែលជាអ្នករៀបចំ «សារមន្ទីរក្រិដ្ឋកម្មសង្គ្រាម»នៅទីក្រុងហូជីមិញត្រូវបានតែងតាំងឲ្យទទួលបន្ទុកបង្កើតសារមន្ទីរមួយនៅក្នុងអតីតមន្ទីរឃុំឃាំងទួលស្លែង និងបូជនីយដ្ឋានមួយនៅលើទីតាំងវាលពិឃាតបឹងជើងឯក ។

## បូជនីយដ្ឋាន

វាលពិឃាតបឹងជើងឯកមានពីរផ្នែកៈ «ផ្នែកដាំដុះ» ដែលមានដើមឈើនិងគម្ពោតព្រៃដែលហ៊ុមព័ទ្ធដោយរបងទាបៗ ហើយនៅពីក្រោយផ្នែកនេះជា«ផ្នែកមិនដាំដុះ»ដែលជាទីវាលដ៏ធំ ។ អ្នកចូលទស្សនាត្រូវចូលតាមផ្នែកដាំដុះ ។ នៅតាមផ្លូវចូលទៅកាន់វាលពិឃាតមានបូជនីយដ្ឋានដ៏ធំមួយ ។ នៅពីក្រោយបូជនីយដ្ឋាននេះមានរណ្តៅសាកសពដែលគាស់រួចជាច្រើនជួរវែងៗ ។ រណ្តៅខ្លះធំ រណ្តៅខ្លះទៀតតូច ។ សម្លៀកបំពាក់និងគ្រោងឆ្អឹងមនុស្សនៅរាយពាសពេញរណ្តៅសាកសពទាំងនោះ ។ មានផ្លាកសញ្ញាសរសេរជាឃ្លាខ្លីៗថាៈ «សាកសពចំនួន៤៥០» «សាកសពឥតក្បាលចំនួន១៦៦» «ស្ត្រីនិងកុមារចំនួន១០០នាក់ដែលភាគច្រើនឥតមានសម្លៀកបំពាក់» ។ គ្រោងឆ្អឹងមនុស្ស សម្លៀកបំពាក់ និងក្រណាត់រុំភ្នែក នៅរាយប៉ាយតាមផ្លូវដើរជុំវិញរណ្តៅសាកសពទាំងនោះ ។ មិនឆ្ងាយប៉ុន្មានពីបូជនីយដ្ឋាននេះ មានខបដ្ឋានសាលាមួយដែលរូបភាពនៅតាមជញ្ជាំងបង្ហាញអំពីការត្រួតពិនិត្យជាបឋមនិងការចុះបញ្ជីឈ្មោះសាកសព ។ ផ្នែកមិនដាំដុះមានបូជនីយដ្ឋានមួយដែលមានរណ្តៅសាកសពធំៗ ដែលមិនទាន់ជីកកកាយនិងមានទឹកដក់ ។

ស្តូបដែលធ្លាប់ជាចេតិយនិងជាកន្លែងសម្រាប់តាំងបង្ហាញលលាដ៍ក្បាលនិងឆ្អឹងបានក្លាយជាកន្លែងកាន់ទុក្ខដ៏សំខាន់និងជាកន្លែងចងចាំ ។ ស្តូបនេះមានកម្ពស់ប្រមាណ២៥ម៉ែត្រនិងគ្របដណ្តប់លើផ្ទៃដីប្រមាណ៨១ម៉ែត្រការ៉េ មានលាបកំបោរពណ៌សនៅជាន់ខាងក្រោម និងប្រក់ដំបូលដែលមានរាងស្រួចទៅលើ ។ បង្អួចនិងទ្វារពាសដោយកញ្ចក់ដែលអាចឲ្យយើងមើលឃើញលលាដ៍ក្បាលប្រមាណ២៥០០ដែលត្រូវបានដាក់តម្រៀបនៅលើធ្នើបែរមុខទៅរកបង្អួចតាមលំដាប់ភេទ អាយុ និងជាតិពន្ធុ ។

## លលាដ៍ក្បាលជនរងគ្រោះៈ ឯកសារនិងការចោទប្រកាន់

លលាដ៍ក្បាលជនរងគ្រោះដែលបានដាក់តាំងបង្ហាញនៅជើងឯកបានបង្កើតនិងរំឭកដល់អំពើមនុស្សឃាតនៅក្នុងទំហំដ៏ធំនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយការតាំងបង្ហាញលលាដ៍ក្បាលនេះមិនត្រឹមតែត្រូវបានមើលឃើញថាជាសកម្មភាពចងក្រងឯកសារដ៏សាមញ្ញនិងអព្យាក្រឹតប៉ុណ្ណោះទេ ថែមទាំងជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីចងក្រងឯកសារនៃការសម្លាប់ជីវិតមនុស្សតាមរបៀបដ៏មានអំណាចបំផុត ។ មូលហេតុនៃសកម្មភាពនេះហាក់បីដូចជាបានដាក់ទម្ងន់ទៅលើការចោទប្រកាន់តាមរយៈសកម្មភាពចងក្រងឯកសារនេះនិងដើម្បីទាញយកចំណាប់អារម្មណ៍របស់ប្រជាជនកម្ពុជានិងអន្តរជាតិតាមរយៈការដាស់កំហឹង ។ ទន្ទឹមគ្នានោះដែរ វាទំនងថាម៉ៃ ឡាំ មានឆន្ទៈប្រឆាំងទៅនឹងការប៉ុនប៉ងណាមួយក្នុងការធ្វើឲ្យគ្មានខ្លឹមសារ ធ្វើឲ្យមានភាពមិនច្បាស់លាស់ ឬបដិសេធ

អំពើប្រល័យពូជសាសន៍នៅកម្ពុជា និងសារជាតិឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## ភាពមិនសមរម្យ

ការតាំងបង្ហាញលលាដ៍ក្បាលពិតជាមានលក្ខណៈស្របច្បាប់ ខ្លះៗ ប៉ុន្តែក៏មានរូបភាពអសីលធម៌មួយចំនួនត្រូវបានលើកឡើងចំពោះការអនុវត្តបែបនេះដែរ ។

នៅក្នុងប្រទេសកម្ពុជា ការដាក់តាំងបង្ហាញគ្រោងឆ្អឹងរបស់ជនរងគ្រោះគឺមិនត្រឹមតែបង្ហាញនូវការមិនគោរពចំពោះជនរងគ្រោះដែលបានបាត់បង់ជីវិតនិងចំពោះក្រុមគ្រួសាររបស់សាកសពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការមិនគោរពចំពោះទំនៀមទម្លាប់របស់ប្រជាជនកម្ពុជាក្នុងការបញ្ចុះសពថែមទៀតផង ។ ចំណុចមួយទៀតគឺភាពមិនសមរម្យនិងចម្លែកនៃការតាំងបង្ហាញ ។ ផ្ទុយពីនេះ សម្លៀកបំពាក់និងគ្រោងឆ្អឹងដែលនៅរាយប៉ាយហាក់បីដូចជាធ្វើឲ្យអ្នកទេសចរស្ងៀនស្ងាត់និងភ្ញាក់ផ្អើល ដូចជាពត៌មានដែលសរសេរនៅលើផ្លាកសញ្ញាដាក់នៅតាមរណ្តៅសាកសពថា «សាកសពចំនួន៤៥០» «សាកសពឥតក្បាលចំនួន១៦៦» «ស្ត្រីនិងកុមារចំនួន១០០នាក់ដែលភាគច្រើនឥតមានសម្លៀកបំពាក់» ។

បញ្ហាទីបីដែលជាបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងការតាំងបង្ហាញលលាដ៍ក្បាលគឺ នេះមិនត្រឹមតែអាចបណ្តាលឲ្យព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍មិនត្រូវបានលាតត្រដាងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្វែរចំណាប់អារម្មណ៍របស់ប្រជាជនអំពីព្រឹត្តិការណ៍ទាំងនេះទៀត ជាពិសេសអំពីព្រឹត្តិការណ៍ដែលទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងធ្វើសង្គ្រាមរបស់វៀតណាមខាងជើងនៅក្នុងប្រទេសកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០និង១៩៧០ ។

## ការទទួលខុសត្រូវរបស់វៀតណាម

ការណ៍ដែលកម្ពុជាប្រជាធិបតេយ្យអាចដណ្តើមអំណាចបាននៅក្នុងឆ្នាំ១៩៧៥គឺបណ្តាលមកពីមូលហេតុមួយចំនួន ។ មូលហេតុចម្បងគឺការចូលរួមរបស់កម្ពុជានៅក្នុងសង្គ្រាមវៀតណាម ។

នៅក្នុងឆ្នាំ១៩៦៥ វៀតណាមខាងជើងបានបង្កើតមូលដ្ឋានយុទ្ធសាស្ត្រនិងផ្លូវផ្គត់ផ្គង់នៅក្នុងទឹកដីកម្ពុជាក្បែរព្រំដែនវៀតណាមខាងត្បូង ដើម្បីដឹកជញ្ជូនអាវុធនិងសម្ភារផ្គត់ផ្គង់ទៅឲ្យកងទ័ពនៅក្នុងទឹកដីវៀតណាមខាងត្បូង និងដើម្បីអនុវត្តបេសកកម្មប្រឆាំងអាវុធឯករាជ្យ ។ ដោយគ្មានមធ្យោបាយដែលមានប្រសិទ្ធភាពដើម្បីបញ្ឈប់វត្តមានរបស់កងទ័ពបរទេសនៅលើទឹកដីកម្ពុជានិងដោយការគាបសង្កត់ពីប្រទេសវៀតណាមនិងចិន រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយព្រះបាទ នរោត្តម សីហនុ បានសម្រេចចិត្តបិទភ្នែកចំពោះការរំលោភលើអធិបតេយ្យភាពកម្ពុជាដើម្បីឯករាជ្យភាពនិងស្ថិរភាពជាតិ ។ ប្រធានាធិបតីសហរដ្ឋអាមេរិករីឆាដ និកសុន មិនមានអារម្មណ៍ថាខ្លួនមានកាតព្វកិច្ចក្នុងការពិចារណាដូច្នេះឡើយ ។ ភ្លាមៗបន្ទាប់ពីការឡើងកាន់តំណែងរបស់ រីឆាដ និកសុន នៅក្នុងឆ្នាំ១៩៦៩ ខ្លួនបានចាប់ផ្តើមប្រតិបត្តិការទម្លាក់គ្រាប់បែកលើមូលដ្ឋាននិងផ្លូវផ្គត់ផ្គង់ស្បៀងនិងអាវុធរបស់វៀតណាមខាងជើងដែលជាបន្ទានៅក្នុងកែវភ្នែកជាយូរមកហើយ ។ លទ្ធផលតែមួយគត់នៃការទម្លាក់គ្រាប់បែកនេះគឺកងទ័ពវៀតណាមខាងជើងចូលកាន់តែជ្រៅទៅក្នុងទឹកដីកម្ពុជាដែលកាលនោះជាប្រទេសមិនចូលបក្សសម្ព័ន្ធ ។

នៅខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានដណ្តើមអំណាចនៅក្នុងរដ្ឋប្រហារមួយនៅប្រទេសកម្ពុជា ។ ដោយសារចង់បង្ហាញឆន្ទៈរបស់ខ្លួនចំពោះសហរដ្ឋអាមេរិកនិងវៀតណាមខាងត្បូង លន់ នល់ និងរដ្ឋាភិបាលរបស់លោក បានចាប់ផ្តើមបើកយុទ្ធនាការយ៉ាងឆាប់រហ័សប្រឆាំងនឹងវត្តមានរបស់កងទ័ពវៀតណាមខាងជើង ។ រដ្ឋាភិបាលទីក្រុងភ្នំពេញបានដាក់ឱសានវាទរយៈពេលខ្លីដល់ទីក្រុងហាណូយ (វៀតណាមខាងជើង) ក្នុងការដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា និងបានចាប់ផ្តើមយុទ្ធនាការសម្លាប់រង្គាលជនអន្តោប្រវេសន៍វៀតណាមនៅក្នុងប្រទេស ។ ដើម្បីថែរក្សាផ្លូវសម្រាប់ដឹកជញ្ជូនសម្ភារផ្គត់ផ្គង់របស់ខ្លួន ទីក្រុងហាណូយបានចាប់ផ្តើមចងសម្ព័ន្ធមិត្តជាមួយចលនាខ្មែរក្រហមកុម្មុយនិស្តដ៏តូចមួយ ហើយបានប្រើប្រាស់ឈ្មោះរបស់ខ្មែរក្រហមដើម្បីធ្វើសង្គ្រាមជាមួយរដ្ឋាភិបាល លន់ នល់ ។

បើទោះបីជាចលនាខ្មែរក្រហមទើបតែត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៦៣ក៏ដោយ ក៏ចលនានេះមិនមានស្ថិរភាពដែរ ។

នៅក្នុងឆ្នាំ១៩៧០ ចលនានេះមានសមាជិករបស់ខ្លួនតែប្រមាណ ៤ពាន់នាក់ប៉ុណ្ណោះ ។ ដោយសារតែយុទ្ធសាស្ត្រនយោបាយរបស់ព្រះបាទ នរោត្តម សីហនុ ប្រជាប្រិយភាពរបស់ព្រះអង្គនិងស្ថិរភាពសេដ្ឋកិច្ចដែលល្អប្រសើរបន្តិចបើប្រៀបធៀបនឹងប្រទេសផ្សេងៗទៀត ចលនាកុម្មុយនិស្តបានបាត់បង់ទាំងទំហំនិងសន្ទុះរបស់ខ្លួនពីទសវត្សរ៍ឆ្នាំ១៩៤០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៦០ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ រដ្ឋប្រហារ សង្គ្រាមស៊ីវិល ការទម្លាក់គ្រាប់បែក និងការគាំទ្រយោធារបស់វៀតណាមខាងជើង បានកើតឡើងព្រមគ្នានៅក្នុងដំណើរការនេះ ។ ពេលដែលកងកម្លាំងខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ចលនានេះមានសមាជិកប្រមាណ ១២ម៉ឺននាក់ ហើយពាក់កណ្តាលនៃចំនួននេះប្រដាប់ដោយអាវុធ ។

ទោះជាយ៉ាងណាក៏ដោយ វៀតណាមមិនអាចទទួលខុសត្រូវចំពោះទង្វើឧក្រិដ្ឋរបស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៣ ដែលជាឆ្នាំចាប់ផ្តើមជម្លោះរវាងទីក្រុងហាណូយនិងខ្មែរក្រហមនោះទេ ។ ការសម្រេចចិត្តរបស់ទីក្រុងហាណូយក្នុងការបង្កើត និងក្រោយមកប្រយុទ្ធដើម្បីដណ្តើមកាន់កាប់មូលដ្ឋាននិងផ្លូវផ្គត់ផ្គង់ គឺជាមូលហេតុដោយគ្មានសង្ស័យនៃការកើនឡើងនូវការចូលរួមក្នុងសង្គ្រាមរបស់កម្ពុជា ។ ទន្ទឹមគ្នានោះដែរ វៀតណាមខាងជើងមានការទទួលខុសត្រូវច្រើនចំពោះការកើនឡើងនិងចំពោះភាពរឹងមាំរបស់ចលនាខ្មែរក្រហម ។ តាំងពីមុនរហូតដល់ឆ្នាំ១៩៧៣ កងទ័ពវៀតណាមខាងជើងបានចាប់ដៃគ្នាជាមួយកងទ័ពខ្មែរក្រហម និងបានជួយឧបត្ថម្ភដល់ចលនានេះនូវសព្វាវុធ យោបល់ផ្នែកយោធា និងនយោបាយ ក៏ដូចជាការអប់រំនិងការប្រមូលកងទ័ព ។

នាពេលបច្ចុប្បន្ននេះ ការប៉ុនប៉ងណាមួយក្នុងការប្រើប្រាស់លលាដ៍ក្បាលជនរងគ្រោះជាមធ្យោបាយនៃការឃោសនាដើម្បីដាក់ការចោទប្រកាន់ឲ្យកាន់តែធ្ងន់ធ្ងរតាមដែលអាចធ្វើទៅបាន និងដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ហាក់បីដូចជាមានបញ្ហាចម្រូងចម្រាស់ ។ ការប៉ុនប៉ងបែបនេះគួរតែត្រូវបានមើលឃើញបន្ទាប់ពីការតស៊ូជាបន្តរវាងកងទ័ពវៀតណាមដែលគាំទ្រដោយកម្លាំងរដ្ឋាភិបាលកម្ពុជានិងកងទ័ពខ្មែរក្រហមដែលនៅតស៊ូក្នុងព្រៃរហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ ។ ដោយសារតែអង្គការសហប្រជាជាតិ ប្រទេសចិន និងប្រទេសជាច្រើនទៀតនៅលោកខាងលិច បានផ្តល់ការគាំទ្រចំពោះកម្ពុជាប្រជាធិបតេយ្យ ចំណុចនេះមានសារសំខាន់ណាស់សម្រាប់វៀតណាម ក្នុងការចងក្រងជាឯកសារនូវឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យនិងក្នុងការដណ្តើមយកការគាំទ្រពីសហគមន៍កម្ពុជានិងអន្តរជាតិ ។ ដូច្នេះហើយការអនុវត្តការចងចាំដែលត្រូវបានដាក់តាំងនៅបឹងជើងឯកនិងចេតនានៅពីក្រោយការដាក់តាំងបង្ហាញលលាដ៍ក្បាលនេះអាចត្រូវបាននិយាយថាមានភាពស្របច្បាប់តាមប្រវត្តិសាស្ត្រ ។ ដូចដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលស្គាល់ នោះគឺថា ការណ៍នេះក៏មានន័យថា ឥឡូវនេះដោយសារតែគ្រោះថ្នាក់ពីរបបកម្ពុជាប្រជាធិបតេយ្យបានកន្លងផុតទៅហើយនោះ ដល់ពេលវេលាសម្រាប់ការអនុវត្តការចងចាំមួយដែលមានតុល្យភាព អត់ឱន និងអាចទទួលយកបាន ពោលគឺមិនត្រឹមតែបង្ហាញនិងចងក្រងឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងដកស្រង់និងឆ្លុះបញ្ចាំងពីមូលហេតុនៅពីក្រោយសោកនាដកម្មនេះទៀតផង ។

**អំពើប្រល័យពូជសាសន៍ៈ បាតុភូតដែលមិនអាចជួសជុល មិនអាចគ្រប់គ្រង និងមាននៅគ្រប់ទីកន្លែង**

ហាក់បីដូចជាដល់ពេលវេលាហើយសម្រាប់កែប្រែនិងអភិវឌ្ឍន៍រូបភាពនៃការចងចាំរបស់ប្រជាជនកម្ពុជា ប៉ុន្តែវាមានសារសំខាន់ក្នុងការទទួលស្គាល់គុណសម្បត្តិខ្លះៗនៃការអនុវត្តការចងចាំតាមរយៈការតាំងបង្ហាញនេះ ។ ជាក់ស្តែងនៅបឹងជើងឯកអ្នកទស្សនាប្រាកដជាគិតដល់លទ្ធភាពនៃបូជនីយដ្ឋាននិងទីតាំងដែលបានបង្ហាញអំពីលក្ខណៈដែល «មិនអាចជួសជុល មិនអាចគ្រប់គ្រង និងមាននៅគ្រប់ទីកន្លែង» នៃអំពើប្រល័យពូជសាសន៍ ។

លលាដ៍ក្បាលទាំងនោះហាក់បីដូចជាបានអំពាវនាវដល់អ្នកទស្សនាតាមរយៈការសម្លឹងយ៉ាងស្ងៀមស្ងាត់ ។ ការអំពាវនាវគឺកប់នៅក្នុងដួងចិត្តនិងពោរពេញដោយទុក្ខសោកជាជាងដោយផ្ទាល់ ។ លលាដ៍ក្បាលបានបង្ហាញអំពីការបាត់បង់ជីវិតរបស់ជនរងគ្រោះជាច្រើននាក់ ហើយការបាត់បង់នេះមិនអាចជួសជុលវិញបានជារៀងរហូត ។ ប្រឈមមុខនឹងការសម្លឹងមើលយ៉ាង

ស្មៀមស្ងាត់របស់លលាដ៍ក្បាល ក្តីឈឺចាប់និងកំហឹងហាក់បីដូចជាមិនអាចរក្សាទុកនៅក្នុងចិត្តបានឡើយ ។

បើប្រៀបធៀបទៅនឹងបូជនីយដ្ឋាននិងកន្លែងរំឭកអំពើមហាប្រល័យនៅអ៊ីស្រាអែល អាមេរិក និងអឺរ៉ុប បឹងជើងឯកក៏មានសារប្រយោជន៍ដែរ ។ ជាទូទៅ បូជនីយដ្ឋាននិងកន្លែងរំឭកអំពើមហាប្រល័យ នៅអ៊ីស្រាអែល អាមេរិក និងអឺរ៉ុប ត្រូវបានសាងសង់ក្នុងអត្ថន័យជាក់លាក់ដើម្បីបង្ហាញការឈឺចាប់របស់ជនរងគ្រោះ ឬបញ្ជាក់អំពីផ្នែកដែលជាវីរភាពនៃការប្រឆាំងនឹងអំពើមហាប្រល័យនៅក្នុងសម័យសង្គ្រាមលោកលើកទីពីរ ដូចជាការរើបម្រាស់របស់ជនជាតិជ្វីហ្វនៅទីក្រុងវ៉ាសូវីនៅក្នុងរដូវផ្ការីកនៃឆ្នាំ១៩៤៣ ។ បូជនីយដ្ឋាននៅបឹងជើងឯកមានលក្ខណៈជ្រួលបន្តិច ប៉ុន្តែគួរឲ្យចាប់អារម្មណ៍ ។ ការតាំងបង្ហាញលលាដ៍នៅបឹងជើងឯក មិនត្រឹមតែបានបង្ហាញពីអំពើប្រល័យពូជសាសន៍ដែលកើតមាននៅកម្ពុជាដោយផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជិតទាស់ទៅនឹងការប៉ុនប៉ងណាមួយដែលផ្តល់តម្លៃតិចតួចបំផុតដល់អំពើមហាប្រល័យនៅបឹងជើងឯក ។ សូម្បីតែវិភាគទានដ៏មានតម្លៃនេះដែលក្នុងនោះបូជនីយដ្ឋានត្រូវបានកសាងឡើងដើម្បីរំឭកដល់អ្នកដែលបានបាត់បង់ជីវិត ក៏ត្រូវបានបន្ថយនូវតម្លៃរបស់វា ដោយសារតែការបង្ហាញលលាដ៍ក្បាលនេះ ។ ដូច្នេះហើយ ការដាក់តាំងលលាដ៍ក្បាលនេះបានបង្ហាញថា អំពើប្រល័យពូជសាសន៍នៅកម្ពុជាគឺគ្មានអ្វីក្រៅពីអំពើមហាប្រល័យដែលមិនមានអត្ថន័យនោះទេ ។ អ្នកទស្សនាមានអារម្មណ៍ថាស្គាល់រូបថតជិត៦ពាន់សន្លឹកដែលដាក់តាំងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ ហើយចំណាប់អារម្មណ៍ពីអំពើមហាប្រល័យនេះនឹងកាន់តែខ្លាំងឡើងថែមទៀត ។

លលាដ៍ក្បាលហាក់បីដូចជាបានធ្វើឲ្យទន់ខ្សោយនូវដួងវិញ្ញាណរបស់បូជនីយដ្ឋាន ។ តាមរយៈការសម្លឹងដ៏ស្ងៀមស្ងាត់ទៅទេសភាពនៅជុំវិញបូជនីយដ្ឋាន លលាដ៍ក្បាលមិនត្រឹមតែបានបញ្ជាក់ថាអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានប៉ះពាល់ដល់ប្រទេសទាំងមូល និងថាមិនមានការរត់គេចខ្លួនរួចប៉ុណ្ណោះទេ ជាងនេះទៅទៀតការសម្លឹងហាក់បីដូចជាមិនបញ្ឈប់ទាល់តែសោះ ។ អ្នកស្លាប់មិនទាន់បានទៅដល់សុគតិភពនៅឡើយ ហើយថែមទាំងនៅចាំកន្លែងដែលខ្លួនត្រូវប្រហារជីវិតថែមទៀត ។ ទស្សនៈអំពីជីវិតរបស់ព្រះពុទ្ធសាសនាដែលថា បន្ទាប់ពីស្លាប់មនុស្សនឹងទៅកាន់កន្លែងដ៏មានន័យមួយបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។ ភាពស្ងៀមស្ងាត់របស់លលាដ៍ក្បាលទាំងនោះមិនមែនមានន័យថាព្រលឹងទាំងនោះបានស្ងប់ទេ ប៉ុន្តែជាភាពស្ងៀមស្ងាត់មួយបន្ទាប់ពីអំពើដែលមិននឹកស្មានដល់និងមិនអាចជួសជុលវិញបាន ។

តាមរយៈគម្រោងរបស់បឹងជើងឯក ទីតាំងបូជនីយដ្ឋានអាចត្រូវបាននិយាយថាមានការបង្កប់អត្ថន័យដែលថាអំពើប្រល័យពូជសាសន៍ជាព្រឹត្តិការណ៍មួយដែលមិនអាចយល់ឲ្យបានច្បាស់ ហើយដែលត្រូវតែយកចិត្តទុកដាក់ ។ ដូចដែលបានកត់សម្គាល់រួចហើយ ផ្នែកមិនមានការដាំដុះត្រូវបានខណ្ឌដាច់ពីវាលដ៏ធំដោយទំនប់មួយដែលស្រដៀងនឹងភ្លឺស្រែ ។ ដោយសារតែភាពស្រដៀងគ្នារវាងផ្នែកមិនដាំដុះនិងតំបន់ជនបទដែលព័ទ្ធជុំវិញផ្នែកនេះហាក់បីដូចជាបានបង្ហាញអំពីភាពមិនអាចយល់បានអំពីទំហំនៃការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជា ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាមានឥទ្ធិពលទៅលើប្រទេសកម្ពុជាទាំងមូល ហើយមនុស្សគ្រប់រូបមិនគួរមើលឃើញព្រឹត្តិការណ៍នេះថាគ្រាន់តែជាព្រឹត្តិការណ៍ក្នុងស្រុកប៉ុណ្ណោះទេ ។ ដូចគ្នានេះដែរ ទឹកដែលដក់នៅក្នុងរណ្តៅសាកសពដែលមិនទាន់ជីកកកាយបានបង្ហាញថាអំពើប្រល័យពូជសាសន៍ជាបាតុភូតដែលមិនអាចគ្រប់គ្រងបាន ។

ជារួម តាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចូលទម្រង់បែបព្រះពុទ្ធសាសនានិងទម្រង់បែបវិទ្យាសាស្ត្រ ជាពិសេសទម្រង់ព្រះពុទ្ធសាសនាដែលត្រូវគ្នានឹងទម្រង់វិទ្យាសាស្ត្រ បូជនីយដ្ឋានអាចត្រូវបាននិយាយថាបានបង្កភាពមន្ទិលសង្ស័យដល់តម្លៃនៃវិធានការទាំងនេះ ។ ទស្សនៈអំពីជីវិតទាំងតាមបែបព្រះពុទ្ធសាសនានិងតាមវិទ្យាសាស្ត្រត្រូវបានអះអាងថាជាទម្រង់សកលនៃការយល់ដឹង ។ ប្រឈមមុខចំពោះសកម្មភាពប្រល័យពូជសាសន៍ ម៉ៅឡាំ បានរកឃើញសារសំខាន់នៅក្នុងការអនុវត្តទម្រង់ទាំងពីរនេះ ។ ដូច្នេះបូជនីយដ្ឋាននៅបឹងជើងឯកបានធ្វើជាសក្ខីភាពចំពោះកង្វះខាតនៃទស្សនៈទាំងពីរនេះចំពោះអំពើប្រល័យពូជសាសន៍ ។ នេះជាសញ្ញាដ៏ច្បាស់លាស់មួយដែលថាព្រឹត្តិការណ៍អាក្រក់បានបំផ្លាញនូវមធ្យោបាយដែលមានទាំងអស់ ។

**វ៉ោហ៊ែន គ្រីស្ទីណា ប៉ុស្ត**

# ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម ចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ

***(តចប់)***

***៥) ឋានៈផ្លូវច្បាប់នៃការចូលរួមរបស់អង្គការសហប្រជាជាតិ និង ការដកថយរបស់អង្គការសហប្រជាជាតិ***

មានការសន្មតពីមុនៗមកថា សេចក្ដីព្រាងអនុស្សរណៈយោគយល់នឹងត្រូវចុះហត្ថលេខាដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានៅពេលដែលច្បាប់មួយគោរពទៅតាមពាក្យពេចន៍របស់សេចក្ដីព្រាងនេះត្រូវបានអនុម័តរួច ។ ក៏ប៉ុន្តែ ខរក្សាសិទ្ធិជាច្រើនរបស់អង្គការសហប្រជាជាតិដែលផ្ដល់ទៅឲ្យរាជរដ្ឋាភិបាលកម្ពុជាមិនត្រូវបានដាក់បញ្ចូលទៅក្នុងអត្ថបទចុងក្រោយនៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលបានអនុម័តកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ទេ ។ ដូច្នេះធ្វើមានមន្ទិលសង្ស័យយ៉ាងខ្លាំងទៅលើច្បាប់នេះ ។

លោក ហែន ខូរែល ទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិបានទទួលអត្ថបទច្បាប់តុលាការជាផ្លូវការដែលបកប្រែជាភាសាអង់គ្លេសនិងភាសាបារាំង នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ។ ពីដំបូង បទអត្ថាធិប្បាយប្រកបដោយការផ្សះផ្សាចំពោះលទ្ធផលនេះត្រូវបានធ្វើឡើងថា ការលំបាកទាំងឡាយមិនមែនមិនអាចជម្នះបាននោះទេ ប៉ុន្តែការចរចាបន្ថែមទៀតគឺជាការចាំបាច់ដើម្បីធ្វើឲ្យច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញស្របទៅតាមសេចក្ដីព្រាងនៃអនុស្សរណៈយោគយល់ ។ ការវាយប្រហាររបស់ភេរវករទៅលើសហរដ្ឋអាមេរិកនៅខែកញ្ញា និងការវាយប្រហារផ្លូវអាកាសទៅលើប្រទេសអាហ្វហ្គានីស្ថានបានធ្វើឲ្យថមថយចំណាប់អារម្មណ៍ក្នុងរឿងសាលាជម្រះក្ដីនេះ ហើយភាគីទាំងសងខាងបានបន្ទោសគ្នាទៅវិញទៅមកចំពោះការខកខានមិនបានឈានទៅរកការបញ្ចប់ ។

នៅថ្ងៃទី១០ ខែតុលា លោក ហែន ខូរែល បានផ្ដល់យោបល់មួយចំនួនអំពីច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងភ្ជាប់មកជាមួយនូវសេចក្ដីព្រាងអនុស្សរណៈយោគយល់ដែលបានកែប្រែរួច ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា លោក ហែន ខូរែល បានទទួលលិខិតមួយច្បាប់ពីឯកឧត្ដម សុខ អាន ដែលជូនដំណឹងថានឹងឆ្លើយតបជាលម្អិតនៅពេលក្រោយ ។ ទោះជាយ៉ាងណាក៏ដោយ លិខិតនេះបានក្លាយទៅជាខបសគ្គថ្មីមួយទៀត ដោយសារតែលិខិតនេះបានបដិសេធដាច់ខាតនូវការកែប្រែច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលកាត់បន្ថយឋានៈរបស់សេចក្ដីព្រាងអនុស្សរណៈយោគយល់ឲ្យនៅត្រឹមតែជា "អត្ថបទសហប្រតិបត្តិការគ្នា" និងបានកំណត់យ៉ាងច្បាស់អំពីទម្រង់នៃកិច្ចសហការគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុរបស់បរទេស ។ នៅទីបញ្ចប់នៅថ្ងៃទី២២ ខែមករា ឯកឧត្ដម សុខ អាន បានឆ្លើយតបចំពោះចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងលិខិតរបស់លោក ហែន ខូរែល ចុះថ្ងៃទី១០ ខែវិច្ឆិកា ក៏ប៉ុន្តែចម្លើយនេះមិនបានបំពេញទៅតាមចំណុចទាំងឡាយដែលអង្គការសហប្រជាជាតិចង់បានទេ ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ លោក កូហ្វី អាណាន់ បានឆក់យកឱកាសប្រឈមមុខដាក់គ្នាថ្មីនេះដើម្បីទាញអង្គការសហប្រជាជាតិចេញពីដំណើរការ ដោយបានបញ្ជាក់ថា រចនាសម្ព័ន្ធនេះមិនអនុញ្ញាតឲ្យអង្គការសហប្រជាជាតិធានាបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិទេ ។ លោកអគ្គលេខាធិការបានកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាចង់បន្ថយឋានៈរបស់ "អត្ថបទសហប្រតិបត្តិការគ្នា" ឲ្យនៅត្រឹមតែជា "ឯកសាររដ្ឋបាលនិងបច្ចេកទេសបន្ទាប់បន្សំ" ។ ឯកឧត្ដម សុខ អាន បានឆ្លើយតបទៅវិញថានេះមិនមែនជាបញ្ហានោះទេ និងបានលើកឡើងថាអនុស្សរណៈយោគយល់និងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញជាឯកសារជំនួយបន្ថែមដែលមានតម្លៃស្មើគ្នា គ្មានមួយណាមាន

អត្ថិភាពខ្ពស់ជាងមួយណាទេ ។

ភាពមិនចុះសម្រុងគ្នាថ្មីនេះទាក់ទិនទៅនឹងឋានៈផ្លូវច្បាប់ពិតប្រាកដនិងលទ្ធផលស្រដៀងគ្នានៃអនុស្សរណៈយោគយល់ដែលធ្លាប់បានចុះហត្ថលេខារួចហើយ ។ ហេតុផលផ្លូវច្បាប់ខ្លះៗប្រសិនបើមិនមែនតិចតួចទេនោះមកពីភាគីទាំងសងខាងបានធ្វើឲ្យសំណួរនេះមានលក្ខណៈស្មុគស្មាញ ។ អាស្រ័យហេតុនេះហើយការរំពឹងឡើងវិញនូវគោលការណ៍ពាក់ព័ន្ធជាមូលដ្ឋានមួយចំនួនគឺមានសារសំខាន់ខ្លាំងណាស់ ។ ក៏ប៉ុន្តែ ទន្ទឹមករណ៍ទាក់ទងទៅនឹងឋានៈក៏បានលើកឡើងនូវបញ្ហាពាក់ព័ន្ធជាច្រើនស្តីពីធម្មជាតិនៃសកម្មភាពរបស់អង្គការសហប្រជាជាតិដែលភាគីទាំងសងខាងបានប្រមើល គឺការចូលរួមការគ្រប់គ្រងបែបបទរដ្ឋបាល ការត្រួតពិនិត្យ ការពិនិត្យបញ្ជាក់ ឬកិច្ចសហប្រតិបត្តិការ ផ្នែកបច្ចេកទេស ។

### ក) ឋានៈផ្លូវច្បាប់ពិតប្រាកដរបស់អនុស្សរណៈយោគយល់

ទោះជាសេចក្តីព្រាងអនុស្សរណៈយោគយល់បានបញ្ជាក់ច្បាស់ថាកិច្ចព្រមព្រៀងនេះនឹងចូលជាធរមានល្គឹកណាភាគីទាំងសងខាងបានគោរពទៅតាមតម្រូវការខាងផ្លូវច្បាប់ជាមូលដ្ឋានក្តី ក៏កិច្ចព្រមព្រៀងនេះនៅតែបើកចំហចំពោះសំណួរថាតើការចុះហត្ថលេខាជាផ្លូវការត្រូវធ្វើឡើងមុនឬបន្ទាប់ពីការអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ អង្គការសហប្រជាជាតិចង់ឲ្យអនុស្សរណៈនេះត្រូវបានចុះហត្ថលេខាមុនពេលអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដូចកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតដែរ ប៉ុន្តែសម្តេច ហ៊ុន សែន បានបដិសេធ ហើយទទូចឲ្យមានការបែកអំណាចដាច់ពីគ្នាតាមលទ្ធិប្រជាធិបតេយ្យតាមរយៈដំណើរការរដ្ឋសភា ។ អាស្រ័យហេតុនេះហើយ សេចក្តីព្រាងអនុស្សរណៈយោគយល់មិនដែលត្រូវបានចុះហត្ថលេខាទេ ហើយក៏មិនដែលបានចូលជាធរមានដែរ ។ «១»នេះនាំឲ្យអង្គការសហប្រជាជាតិអះអាងថា ការទទូចរបស់កម្ពុជាដែលថាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញមានឧត្តមភាពខ្ពស់ជាងអនុស្សរណៈយោគយល់នោះគឺជាការរំលោភទៅលើគោលការណ៍មូលដ្ឋាននៃកាតព្វកិច្ចអន្តរជាតិ *pecta sunt servanda* ពីព្រោះថាប្រទេសកម្ពុជាមិនបានជាប់កិច្ចសន្យាចំពោះកាតព្វកិច្ចអន្តរជាតិណាមួយនៅក្រោមអនុស្សរណៈយោគយល់នេះទេ ។ ឥឡូវនេះអនុស្សរណៈនេះត្រូវបានជំនួសដោយកិច្ចព្រមព្រៀងឆ្នាំ២០០៣ដែលស្រដៀងគ្នាមួយភាគធំ ។

គិតមកត្រឹមពេលដែលក្រុមអ្នកជំនាញការបានធ្វើដំណើរមកដល់ប្រទេសកម្ពុជា អង្គការសហប្រជាជាតិហាក់ដូចជាខកខានមិនបានបញ្ជាក់ថាស្ថានការណ៍នយោបាយបានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ហើយនាយករដ្ឋមន្ត្រីថ្មី សម្តេច ហ៊ុន សែន បានប្រាប់ក្រុមអ្នកជំនាញការថាសម្តេចចង់បានដំណោះស្រាយខាងក្នុងជាង ។ អង្គការសហប្រជាជាតិបានបញ្ជាក់តាមក្រោយថា អនុសាសន៍ថ្មីៗរបស់ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិមិនបានផ្អែកទៅលើសំណើរបស់កម្ពុជាដែលសុំឲ្យមានតុលាការអន្តរជាតិពិសេសទេ ផ្ទុយទៅវិញ មិនបានផ្អែកការប្តេជ្ញាចិត្តដោយឯកភាពដែលថាទង្វើនេះជាចម្លើយតបដ៏ស័ក្តិសមបំផុតចំពោះស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា ស្របទៅនឹងអាណត្តិដែលផ្តល់ឲ្យដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។

ការឆ្លើយតបរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិចំពោះសំណើសុំជំនួយរបស់កម្ពុជាមិនជាប់ពាក់ព័ន្ធនឹងសិទ្ធិអំណាចក្នុងការផ្តល់ជំនួយផ្នែកបច្ចេកទេសពីសំណាក់រដ្ឋជាសមាជិកនៅក្នុងបញ្ហាតុលាការនោះទេ ។ សិទ្ធិអំណាចនេះបានមកពីការផ្តល់ឲ្យដ៏ជាក់លាក់មួយពីសំណាក់មហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែធ្នូឆ្នាំ១៩៩៧ ។ ការផ្លាស់ប្តូរសារជាតិនៃការចូលរួមរបស់អង្គការសហប្រជាជាតិមិននាំឲ្យមានការប្រែប្រួលឋានៈផ្លូវច្បាប់របស់អង្គការនេះទេ ។ ភាពស្របគ្នាជាមួយនឹងជំនួយបច្ចេកទេសគឺជាសក្ខីភាពមួយបង្ហាញច្បាស់ ជាពិសេសតាំងពីពេលដែលអង្គការសំខាន់ៗរបស់អង្គការសហប្រជាជាតិមិនធ្វើបទអន្តរាគមន៍ណាមួយដើម្បីធានាសុពលភាពរបស់អនុស្សរណៈយោគយល់ ។ រចនាសម្ព័ន្ធដែលប្រកាន់យកនោះមិនពាក់ព័ន្ធជាមួយនឹងការបង្កើតតុលាការអន្តរជាតិ *sui generis* ដូចករណីប្រទេសសៀរ៉ាឡេអូន ដោយទាមទារយ៉ាងច្បាស់ឲ្យមានកិច្ចព្រមព្រៀងអន្តរជាតិចងភ្ជាប់គ្នាមួយ ។ អាស្រ័យហេតុនេះ ឋានៈនៃ

កិច្ចព្រមព្រៀងនៅតែបើកចំហសម្រាប់ការប្តេជ្ញាចិត្តតាមរយៈការព្រមព្រៀងគ្នាទៅវិញទៅមករវាងភាគីទាំងសងខាង ។

នៅក្នុងករណីណាក៏ដោយ របៀបដែល "ឲ្យអត្ថិភាពទៅលើផ្លូវច្បាប់" បានដាក់ឲ្យអង្គជំនុំជម្រះវិសាមញ្ញស្ថិតនៅក្នុងដែនច្បាប់ជាតិរបស់កម្ពុជាតែមួយគត់ ផ្ទុយពី"តុលាការពិសេស" សម្រាប់ប្រទេសសៀរ៉ាឡេអូនដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលសៀរ៉ាឡេអូន និងជាតុលាការដែលផ្អែកទៅលើសន្ធិសញ្ញា *sui generis* ដោយមានយុត្តាធិការនិងសមាសភាពចៅក្រមចម្រុះ ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលអនុស្សរណៈយោគយល់គ្មានបទបញ្ញត្តិច្បាស់លាស់ បញ្ហាឋានានុក្រមប្រាកដជានឹងកើតមាន ហើយមិនគ្រាន់តែពាក់ព័ន្ធនឹងច្បាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងគោលការណ៍ធម្មនុញ្ញរបស់កម្ពុជាទៀតផង ។ ទោះជារដ្ឋាភិបាលកម្ពុជាអះអាងថាបញ្ហាឋានានុក្រមនឹងមិនកើតឡើងទេដោយសារតែច្បាប់នេះមានលក្ខណៈ"ស្របនិងបំពេញបន្ថែម" ឲ្យអនុស្សរណៈយោគយល់ដែលនេះគ្របដណ្តប់តែទៅលើទិដ្ឋភាពអន្តរជាតិសម្រាប់ការជំនុំជម្រះក្តីក៏ដោយ ក៏វាហាក់ដូចជាច្បាស់ណាស់ថា ចេញពីពាក្យ "សេចក្តីព្រាងអនុស្សរណៈយោគយល់"នេះ ភាពស្មុគស្មាញខ្លះនឹងកើតមានឡើង ។ ការគូសបញ្ជាក់លើចំណុចនេះឲ្យបានច្បាស់គឺជាមូលហេតុនាំឲ្យមានការចរចាគ្នាសាជាថ្មីទៀតដែលឈានទៅរកការអនុម័តកិច្ចព្រមព្រៀងនៅឆ្នាំ២០០៣ ។

ខណៈពេលដែលអនុស្សរណៈយោគយល់ត្រូវបានបញ្ចប់នៅក្នុងខែកក្កដា ឆ្នាំ២០០០ អង្គការសហប្រជាជាតិបានបង្កើតគណៈវិនិច្ឆ័យឧក្រិដ្ឋកម្មធ្ងន់ធ្ងរសម្រាប់ទីម័រខាងកើត ។ នៅដើមឆ្នាំ២០០២ អង្គការសហប្រជាជាតិបានចុះហត្ថលេខាលើសន្ធិសញ្ញាជាមួយប្រទេសសៀរ៉ាឡេអូនស្តីអំពីការបង្កើតតុលាការពិសេសដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ ។ នៅក្នុងករណីទាំងពីរនេះ រដ្ឋបាលសាលាជំនុំជម្រះក្តីស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងរឹងមាំរបស់អង្គការសហប្រជាជាតិ (ទោះជាទីតាំងរបស់សាលាជំនុំជម្រះក្តីស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិឬស្ថិតនៅក្រោមកាតព្វកិច្ចចងភ្ជាប់ដោយសន្ធិសញ្ញាក្តី) ហើយចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិដែលត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិមានចំនួនច្រើនលើសលប់ ។ ទោះបីជាទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិមិនបាននិយាយអំពីសមិទ្ធិផលទាំងនេះនៅពេលដែលអង្គការសហប្រជាជាតិប្រកាសដកខ្លួនពីកម្ពុជាក៏ដោយ បើប្រៀបធៀបទៅ ប្រព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញបានទទួលរងនូវផលប៉ះពាល់យ៉ាងច្បាស់ក្រឡែត ។

### ១) សារជាតិនៃការចូលរួមរបស់អង្គការសហប្រជាជាតិ

ដោយមិនគិតអំពីឋានៈផ្លូវច្បាប់ អនុស្សរណៈយោគយល់ (ឥឡូវនេះបានក្លាយទៅជាកិច្ចព្រមព្រៀងឆ្នាំ២០០៣) មិនបានផ្តល់សិទ្ធិគ្រប់គ្រងទៅឲ្យអង្គការសហប្រជាជាតិដើម្បីកាត់ទោសខ្មែរក្រហមនោះទេ ។ តាមពិត តួនាទីរបស់អង្គការសហប្រជាជាតិនៅក្នុងការបំពេញរចនាសម្ព័ន្ធអង្គជំនុំជម្រះគឺជាការរួមចំណែកដ៏មានសារសំខាន់តែមួយគត់បើប្រៀបធៀបទៅនឹងការទទួលខុសត្រូវរបស់កម្ពុជាក្នុងការគោរពពាក្យសន្យា ការការពារអ្នកចូលរួម ការកំណត់អត្តសញ្ញាណជនសង្ស័យ ការចាប់ខ្លួននិងឃុំខ្លួនជនសង្ស័យ និងការដាក់ពន្ធនាគារដោយគ្មានការអត់ឱនដល់អ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាមានកំហុស ។

តាមពិត តាមរយៈអនុប្រធានការិយាល័យរដ្ឋបាល ការគ្រប់គ្រងមូលនិធិសម្រាប់ការចូលរួមរបស់អន្តរជាតិជាចំណុចជាក់ស្តែងតែមួយគត់ដែលអនុញ្ញាតឲ្យអង្គការសហប្រជាជាតិមានឥទ្ធិពលខ្លះៗទៅលើដំណើរការជំនុំជម្រះនេះ ។ ក្នុងករណីដែលភាគីកម្ពុជារំលោភទៅលើអនុស្សរណៈយោគយល់ អង្គការសហប្រជាជាតិនឹងដាក់ទណ្ឌកម្មដោយការគំរាមកំហែងដកខ្លួនចេញ ប៉ុន្តែសម្តេច ហ៊ុន សែន បានសម្តែងឲ្យឃើញថាគាត់ជាអ្នកលេងល្បែងបៀដ៏ប៉ិនប្រសប់ម្នាក់ដែរ ។

ទាក់ទងទៅនឹងការជ្រើសរើសបុគ្គលិកអន្តរជាតិចេញពីបញ្ជីរៀបចំដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ វាមានការលំបាកក្នុងការវិនិច្ឆ័យថាតើអង្គការសហប្រជាជាតិមានតួនាទីត្រួតពិនិត្យឬគ្រប់គ្រងអង្គជំនុំជម្រះនេះ ។ ជាងនេះ

ទៅទៀត តួនាទីរដ្ឋបាលរបស់អង្គការសហប្រជាជាតិត្រូវកម្រិតឲ្យនៅត្រឹមតែការជ្រើសរើសបុគ្គលិកអន្តរជាតិប៉ុណ្ណោះ មិនមែនសកម្មភាពការងាររបស់អង្គជំនុំជម្រះនោះទេ ។ ត្រូវតែគូសបញ្ជាក់ឲ្យបានច្បាស់នូវចំណុចថាតើអ្វីនឹងកើតឡើងក្នុងករណីដែលអង្គការសហប្រជាជាតិខកខានមិនបានផ្តល់បេក្ខជនគ្រប់គ្រាន់សម្រាប់តែងតាំង ។

សេចក្តីព្រាងអនុស្សរណៈយោគយល់បានចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបំពេញកន្លែងទំនេរដោយបេក្ខជនដែលជ្រើសរើសចេញពីបញ្ជីរបស់អង្គការសហប្រជាជាតិ ។ ធ្វើដូច្នេះធានាឲ្យមានការបន្តការចូលរួមពីអន្តរជាតិនៅតាមកម្រិតថ្នាក់ដែលព្រមព្រៀងគ្នារួចហើយ ។ តាមពិត ការទទូចសុំរបស់អង្គការសហប្រជាជាតិចំពោះការទទួលខុសត្រូវតែម្នាក់ឯងសម្រាប់ការផ្តល់បេក្ខជនដ៏មានសក្តានុពលត្រូវបានធ្វើឡើងដើម្បីរារាំងបទបញ្ញត្តិរបស់កម្ពុជាដែលមិនអាចទទួលយកបាននៅក្នុងសេចក្តីព្រាងច្បាប់កាលពីខែមករាឆ្នាំ២០០០ ដែលទុកឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមបរទេសតាមការស្នើសុំរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ឬតាមការស្នើសុំរបស់រដ្ឋាភិបាលនៃរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ឬក្នុងចំណោមឥស្សរជនច្បាប់សញ្ជាតិបរទេសផ្សេងៗទៀតបន្ទាប់បានជួបពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានធ្វើឲ្យមានតុល្យភាពគ្នារវាងមុខតំណែងដ៏មានសារសំខាន់នេះ ។ មួយវិញទៀត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងបុគ្គលិកបរទេសតែនៅពេលណាដែលមានការចាត់តាំងឈ្មោះដែលជ្រើសរើសចេញពីបញ្ជីរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ការនិយាយយោងទៅដល់ "រដ្ឋាភិបាលនៃរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ...ឬឥស្សរជនច្បាប់ដទៃទៀត" នៅតែមានដដែល ។ សេចក្តីយោងនេះលេចឡើងនៅក្នុងមាត្រាទី៤៦ដែលទាក់ទងទៅនឹងបញ្ហាខ្វះបុគ្គលិកដែលផ្តល់ដោយអង្គការសហប្រជាជាតិដែលលែងជាប្រភពបុគ្គលមានស្រាប់ទៀតហើយ ក៏ប៉ុន្តែក្លាយទៅជាតួនាទីបម្រុងដោយអនុញ្ញាតឲ្យមានការតែងតាំងបេក្ខជនបន្ថែមថ្មីទៀត "នៅក្នុងករណីអស់បេក្ខជនពីបញ្ជីឈ្មោះរបស់អង្គការសហប្រជាជាតិ" ។ ដំណោះស្រាយចុងក្រោយបង្អស់គឺក្រោយពីមានការស្វះស្វែងរកការចូលរួមរបស់បរទេសតាមរយៈការរៀបចំទ្វេភាគីរួចហើយ ប្រសិនបើអង្គការសហប្រជាជាតិនៅតែមិនបានផ្តល់បុគ្គលិកបរទេសតាមតម្រូវការរបស់តុលាការ "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសរើសចៅក្រមកម្ពុជាចៅក្រមស៊ើបអង្កេតកម្ពុជា ឬព្រះរាជអាជ្ញាកម្ពុជា មកជំនួសបាន" ។ ក៏ប៉ុន្តែប្រការនេះទំនងជានឹងមិនកើតឡើងទេ ព្រោះថាបុគ្គលិកបរទេស"ត្រូវបានតែងតាំងសម្រាប់ពេញមួយអំឡុងពេលនៃដំណើរការជំនុំជម្រះនេះ" ដោយធានាឲ្យប្រាកដថាអាចមានការផ្លាស់ប្តូរតែបន្តិចបន្តួចតែប៉ុណ្ណោះ ។

បើទោះជាមានដំណោះស្រាយដែលហាក់ដូចជាសមហេតុផលដើម្បីចៀសវាងរាំងស្ទះដំណើរការជំនុំជម្រះនៅក្នុងករណីមានការដកថយរបស់អង្គការសហប្រជាជាតិក៏ដោយ ហើយបើទោះជាថា បទបញ្ញត្តិពាក់ព័ន្ធបានបញ្ជាក់អំពីសិទ្ធិរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងការដាក់ឈ្មោះបេក្ខជនទៅក្នុងបញ្ជីនីមួយៗក៏ដោយ ក៏បញ្ហាអស់ឈ្មោះពីក្នុងបញ្ជីនៅតែជាបញ្ហាដែលលើកឡើងដោយទីប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ បន្ទាប់ពីការអនុម័តច្បាប់នេះរួច ។ ប្រការនេះបាននាំឲ្យអង្គការសហប្រជាជាតិខ្វះជំនឿទុកចិត្តរបស់ទៅលើសុចរិតភាពរបស់កម្ពុជា ហើយឯកឧត្តម សុខ អាន បានបដិសេធភ្លាមៗនៅក្នុងការឆ្លើយតបលម្អិតមួយកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ដោយបញ្ជាក់ថា "...យោងតាមស្មារតីនៃកិច្ចសហប្រតិបត្តិការគ្នាយើងគ្មានបំណងកម្រិតសិទ្ធិសេរីភាពនិងឱកាសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងការបញ្ចូលឈ្មោះបេក្ខជនបន្ថែមទៀត ទៅក្នុងបញ្ជីនៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះទេប្រសិនបើប្រការនេះចាំបាច់មែននោះ" ។ ឯកឧត្តម សុខ អាន បានបន្ថែមទៀតថា "ទាំងអស់នេះអាចមើលឃើញកាន់តែច្បាស់នៅក្នុងអត្ថបទនៃកិច្ចសហប្រតិបត្តិការ" ។ តាមពិត នៅត្រង់ចំណុចនេះ កិច្ចព្រមព្រៀងឆ្នាំ២០០៣បានប្រើប្រាស់ពាក្យ

ពេចន៍ធ្ងន់ជាងនេះ ។

ទោះជាយ៉ាងណាក៏ដោយ ការចោទប្រកាន់អតីតមេបញ្ជាការខ្មែរក្រហមឈ្មោះ តាម៉ុក ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធ្វើឲ្យមានមន្ទិលសង្ស័យកាន់តែខ្លាំងឡើងទៅលើឆន្ទៈរបស់អាជ្ញាធរកម្ពុជាក្នុងការគោរពបទបញ្ញត្តិរបស់ខ្លួនទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ តាមពិត អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការទៅលើមាត្រាទី៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលបានចែងអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយយោងតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា ។ បុគ្គលិកដែលតែងតាំងស្របទៅតាមច្បាប់តុលាការគួរតែទទួលបន្ទុកចោទប្រកាន់ ប៉ុន្តែផ្ទុយទៅវិញបែរជាព្រះរាជអាជ្ញារបស់តុលាការយោធាក្រុងភ្នំពេញជាអ្នកចាត់វិធានការនៅក្នុងរឿងក្តីនេះទៅវិញ ។ ទោះបីជាបានទទួលស្គាល់ថាបទបញ្ញត្តិបម្រុងនៅក្នុងច្បាប់អាចត្រូវបានបកស្រាយថាអនុញ្ញាតឲ្យបុគ្គលិកកម្ពុជាធ្វើកិច្ចការជាឯកតោភាគីក្នុងពេលរង់ចាំការតែងតាំងបុគ្គលិកអន្តរជាតិក្តី ក៏ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតកម្ពុជាគួរតែទទួលបានការតែងតាំងជាផ្លូវការនៅក្នុងអង្គជំនុំជម្រះសិនមុននឹងធ្វើសេចក្តីសម្រេចចិត្តណាមួយ ។ ជាការពិត បន្ទាប់ពីប្រឈមមុខនឹងការបន្តឲ្យដោះលែង តាម៉ុក នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០២ ក្រោយពីហួសកាលកំណត់បីឆ្នាំដែលជារយៈពេលជាអតិបរមាសម្រាប់ការឃុំខ្លួនមុនពេលជំនុំជម្រះ រដ្ឋាភិបាលកម្ពុជាមិនអើពើដល់សិទ្ធិរបស់ចុងចោទឡើយ ។

## ៦) កិច្ចព្រមព្រៀងឆ្នាំ២០០៣

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ បន្ទាប់ពីបានត្រួតពិនិត្យទៅលើសម្បទានទាំងឡាយដែលធ្វើឡើងដោយអង្គការសហប្រជាជាតិ លោកអគ្គលេខាធិការ កូហ្វី អាណាន់ បានទាញអង្គការសហប្រជាជាតិចេញពីដំណើរការនេះ ។ រដ្ឋដ៏មានឥទ្ធិពលមួយចំនួនដែលជាសមាជិករបស់អង្គការសហប្រជាជាតិបានជំទាស់យ៉ាងខ្លាំងចំពោះសេចក្តីសម្រេចចិត្តនេះ ។ នៅក្នុងខែសីហា ឆ្នាំ២០០២ លោកអគ្គលេខាធិការ កូហ្វី អាណាន់ "បានបញ្ជាក់ច្បាស់ថា គាត់ត្រូវការអាណត្តិជាក់លាក់មួយពីមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខ ដើម្បីអាចឲ្យគាត់ចូលរួមនៅក្នុងការចរចាបន្តទៀត" ។ អាណត្តិនេះនឹងត្រូវធ្វើឡើងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ នៅពេលដែលមហាសន្និបាតអនុម័តសេចក្តីសម្រេចដែលស្នើសុំឲ្យលោកអគ្គលេខាធិការបន្តការចរចា "ដោយផ្អែកទៅលើការចរចាពីមុនៗមក ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលស្របជាមួយនឹងបទបញ្ញត្តិនៃសេចក្តីសម្រេចចិត្តដែលបានដាក់ជូន..." ។ លោកអគ្គលេខាធិការមានពេល៩០ថ្ងៃដើម្បីរាយការណ៍អំពីការអនុវត្តសេចក្តីសម្រេចចិត្តនេះ ហើយនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ក្រុមអ្នកចរចាអង្គការសហប្រជាជាតិនិងកម្ពុជាបានអនុម័តយកសេចក្តីព្រាងនៃកិច្ចព្រមព្រៀងទាក់ទងទៅនឹងការជំនុំជម្រះ (កិច្ចព្រមព្រៀងឆ្នាំ២០០៣) ។ ដូចបានចរចារួចហើយ រាជរដ្ឋាភិបាលកម្ពុជាទទួលយកសេចក្តីព្រាងនេះនៅថ្ងៃទី២៨ ខែមីនា ហើយមហាសន្និបាតអង្គការសហប្រជាជាតិទទួលយកនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាជាផ្លូវការដោយភាគីទាំងសងខាងនៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ និងចូលជាធរមានបន្ទាប់ពីសភាជាតិរបស់កម្ពុជាបានផ្តល់សច្ចាប័ន ។ កិច្ចពិភាក្សាអំពីវិសោធនកម្មក៏មានជាបន្តបន្ទាប់ ។

### ក) ឋានៈផ្លូវច្បាប់របស់កិច្ចព្រមព្រៀងឆ្នាំ២០០៣

ឋានៈផ្លូវច្បាប់របស់កិច្ចព្រមព្រៀងឆ្នាំ២០០៣ត្រូវបានបកស្រាយយ៉ាងច្បាស់ ។ ខណៈពេលកម្ពុជាចាត់ទុកកិច្ចព្រមព្រៀងនេះថាគ្រាន់តែធ្វើឡើងដើម្បីត្រួតពិនិត្យមើលកិច្ចសហប្រតិបត្តិការរបស់អន្តរជាតិនៅក្នុងការជំនុំជម្រះ កិច្ចព្រមព្រៀងនេះក៏បានបញ្ជាក់ថាបានផ្តល់នូវមូលដ្ឋានផ្លូវច្បាប់ចំពោះកិច្ចសហប្រតិបត្តិការនេះដែរ ។ នៅក្នុងន័យនេះ ច្បាប់តុលាការត្រូវបានបន្ថយឲ្យមកនៅត្រឹមតែជាច្បាប់ដែលកំពុងអនុវត្ត ។ នៅពេលណាដែលកិច្ចព្រមព្រៀងនេះត្រូវបានផ្តល់សច្ចាប័ន កិច្ចព្រមព្រៀងនឹងក្លាយទៅជាកិច្ចព្រមព្រៀងអន្តរជាតិចងភ្ជាប់រវាងអង្គការសហប្រជាជាតិនិងកម្ពុជា ដែលត្រូវយកមកអនុវត្ត "ជាច្បាប់ស្ថិតនៅក្រោមច្បាប់កម្ពុជា" (មាត្រាទី១ និងទី២) ។ ទោះជាលោក

អគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់ទុកប្រការទាំងអស់នេះថាជាចំណុចវិជ្ជមានក៏ដោយ កិច្ចព្រមព្រៀងនេះនៅតែមានគុណវិបត្តិមួយចំនួន ។

ឈរលើទិដ្ឋភាពវិជ្ជមាននេះមានន័យថា ឥឡូវនេះដំណើរការស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មហាសន្និបាតដែលត្រូវបានតម្រូវឲ្យផ្តល់សិទ្ធិអំណាចផ្លូវការដល់លោកអគ្គលេខាធិការឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ ទាំងនេះជាការគាំទ្រកាន់តែធំធេងពីសំណាក់សហគមន៍អន្តរជាតិ ។ ជាងនេះទៅទៀត ដោយសារតែមានគោលការណ៍ *pacta sunt servanda* ភាគីទាំងសងខាងត្រូវតែអនុវត្តកិច្ចព្រមព្រៀងនេះក្នុងភាពត្រង់ទៅត្រង់មក ហើយកម្ពុជាមិនអាចសំអាងលើបទបញ្ញត្តិផ្សេងៗទៀតនៃច្បាប់ក្នុងស្រុកដើម្បីធ្វើជាដំណោះស្រាយចំពោះការខកខានមិនបានបំពេញតាមការចូលរួមរបស់ខ្លួននោះទេ ។ អាស្រ័យហេតុនេះហើយកិច្ចព្រមព្រៀងឆ្នាំ២០០៣បានផ្តល់ការធានាខាងផ្លូវច្បាប់ថា អង្គជំនុំជម្រះវិសាមញ្ញនឹងដើរតួនាទីនិងប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចបានប្រមើលនៅក្នុងកិច្ចព្រមព្រៀង ហើយផ្តល់មូលដ្ឋានដែលមិនអាចប្រកែកបានដើម្បីកំណត់ការរំលោភពីសំណាក់ប្រទេសកម្ពុជា ។

ទោះជាយ៉ាងណាក៏ដោយ វាមិនច្បាស់នៅឡើយថាការផ្លាស់ប្តូរជាផ្លូវការនេះនឹងដាក់សម្ពាធកាន់តែខ្លាំងឡើងថែមទៀតទៅលើប្រទេសកម្ពុជាដើម្បីឲ្យមានកិច្ចសហការគ្នាដ៏ពេញលេញមួយនៅក្នុងដំណើរការជំនុំជម្រះក្តីបន្ថែមពីលើសម្ពាធពីសំណាក់អង្គការក្រៅរដ្ឋាភិបាល ដៃគូពាណិជ្ជកម្ម និងទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ។ តាមពិត ដូចបានប្រមើលនៅក្នុងមាត្រាទី២៨នៃកិច្ចព្រមព្រៀងឆ្នាំ២០០៣ ប្រសិនបើក្រោយមករដ្ឋាភិបាលចង់ផ្លាស់ប្តូររចនាសម្ព័ន្ធ ឬធ្វើឲ្យអង្គជំនុំជម្រះដំណើរការក្នុងលក្ខណៈមួយដែលមិនគោរពទៅតាមកិច្ចព្រមព្រៀង អង្គការសហប្រជាជាតិអាចគំរាមបញ្ឈប់ជំនួយឧបត្ថមគាំទ្ររបស់ខ្លួនបាន ។ ក៏ប៉ុន្តែប្រកចេញបន្ទាន់ដ៏ឆាយស្រួលរបស់អង្គការសហប្រជាជាតិនឹងមិនអាចបញ្ចប់និទណ្ឌភាពរបស់ខ្មែរក្រហមឡើយ ។

លើសពីនេះទៀត ឋានៈជាអន្តរជាតិរបស់កិច្ចព្រមព្រៀងនឹងបង្កើតបាននូវសក្តានុពលភាពមួយក្នុងចេតនាធ្វើឲ្យខ្ជះខ្ជាយពេលវេលាបន្ថែមទៀតដោយអាជ្ញាធរកម្ពុជា ។ ដំបូង កិច្ចព្រមព្រៀងត្រូវតែឆ្លងកាត់នីតិវិធីទូទៅនៃការផ្តល់សច្ចាប័ន រាប់បញ្ចូលទាំងការអនុម័តយល់ព្រមពីសភាជាតិនិងព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញមាត្រាទី២៦ថ្មី) ។ ជាការពិតណាស់ ការយោគយល់គ្នាទៅវិញទៅមកពីលើកមុនត្រូវបានព្រមព្រៀងគ្នានៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣ ។ គ្មានអ្វីគួរឲ្យសង្ស័យទេ ទោះជាប្រការនេះមិនអាចទទួលបានជោគជ័យភ្លាមៗដោយរដ្ឋសភាកម្ពុជាបន្ទាប់ពីការបោះឆ្នោតជាទូទៅនៅក្នុងខែកក្កដាឆ្នាំ២០០៣ក៏ដោយ ក៏បញ្ហានេះមិនបញ្ចប់នៅរដ្ឋសភាដែរ ។

ជាអកុសល គ្មានបទបញ្ញត្តិណាមួយជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាដែលបង្កើតឋានៈសន្ធិសញ្ញាដែលបានផ្តល់សច្ចាប័នមានសុពលភាពនៅក្នុងប្រព័ន្ធក្នុងស្រុកទេ ។ រដ្ឋាភិបាលបានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍យូរៗម្តងរបស់ខ្លួននៅក្នុងឆ្នាំ១៩៩៧ ដែលផ្ញើទៅគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីអំពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ **(CERD)** ថាខ្លួនប្រកាន់ខ្ជាប់នូវទម្រង់ទ្វិកនិយមទាក់ទងទៅនឹងអនុសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាបានផ្តល់សច្ចាប័ន ។ កម្ពុជា "ប្រហែលជាមិនប្រើប្រាស់អនុសញ្ញានេះដោយផ្ទាល់នៅចំពោះមុខតុលាការឬអាជ្ញាធររដ្ឋបាល" នោះទេ គ្រាន់តែ"ផ្តល់មូលដ្ឋានដើម្បីបង្កើតច្បាប់ជាតិតែប៉ុណ្ណោះ..." ។

អាស្រ័យហេតុនេះហើយ កម្ពុជាហាក់ដូចជាទាមទារឲ្យច្បាប់ក្នុងស្រុកស្របជាមួយនឹងកិច្ចព្រមព្រៀងឆ្នាំ២០០៣ជាពិសេសច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ តាមពិតទោះជាកិច្ចព្រមព្រៀងចែងថានឹងក្លាយខ្លួនជាច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយកម្ពុជាមិនចាំបាច់អនុម័តច្បាប់បន្ថែមទៀតក៏ដោយក៏បទបញ្ញត្តិនេះផ្ទុយពីប្រព័ន្ធទ្វិកនិយមរបស់កម្ពុជា ។ ក្នុងកម្រិតមួយដែលកិច្ចព្រមព្រៀងមានបទបញ្ញត្តិជាក់លាក់ផ្ទុយពីខ្លឹមសារច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វាជាការប្រសើរសម្រាប់កម្ពុជាក្នុងការធ្វើវិសោធនកម្មជាផ្លូវការ ។ តាមពិតការខកខានមិនបានធ្វើវិសោធនកម្មច្បាប់បង្កើតអង្គជំនុំជម្រះ

វិសាមញ្ញនឹងរំលោភទៅលើកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជាចំពោះអង្គការសហប្រជាជាតិ (ដែលនៅទីបញ្ចប់នាំឲ្យអង្គការសហប្រជាជាតិដកខ្លួនចេញពីដំណើរការ) ក៏ប៉ុន្តែមិនបណ្តាលឲ្យច្បាប់នេះគ្មានសុពលភាពនៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា ឬមិនផ្តល់មូលដ្ឋានសម្រាប់ការពិនិត្យប្រព័ន្ធតុលាការកម្ពុជាឡើងវិញទេ ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើវិសោធនកម្មច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលមានស្រាប់នឹងពាក់ព័ន្ធមិនត្រឹមតែដំណើរការរបស់រដ្ឋសភានិងការត្រួតពិនិត្យឡើងវិញរបស់រដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធទៅនឹងការពិភាក្សាបន្ថែមទៀតជាមួយអង្គការសហប្រជាជាតិ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងផ្ទាល់ [មាត្រាទី២(៣)] ។ កាលពីមុន កម្ពុជាបានអូសបន្លាយដំណើរការនេះអស់រយៈពេល៨ខែគត់ ។

## ខ) រចនាសម្ព័ន្ធ

កិច្ចព្រមព្រៀងឆ្នាំ២០០៣បានបង្កលក្ខណៈងាយស្រួលដល់រចនាសម្ព័ន្ធអង្គជំនុំជម្រះវិសាមញ្ញ តាមរយៈការដកចេញនូវអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលនៅកណ្តាល ដោយទុកតែរចនាសម្ព័ន្ធពីរថ្នាក់ប៉ុណ្ណោះ ។ រចនាសម្ព័ន្ធថ្មីនេះនៅតែផ្តល់ដល់ជនជាប់ចោទនូវសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ដែលស្រដៀងគ្នាទៅនឹងបណ្តឹងដែលធ្វើឡើងនៅចំពោះមុខសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិពិសេសដែរ ហើយនឹងជួយកាត់បន្ថយនូវការចំណាយនិងរយៈពេលនៃការកាត់សេចក្តីបានច្រើនគួរឲ្យកត់សម្គាល់ ។ នៅឯសាលាដំបូង ចៅក្រមកម្ពុជាមានចំនួនបីរូបក្នុងចំណោមចៅក្រមប្រាំរូប និងនៅសាលាកំពូល ចៅក្រមកម្ពុជាមានចំនួនបួនរូបក្នុងចំណោមចៅក្រមប្រាំពីររូប (មាត្រាទី៣) ។ បើទោះជានៅតែមានកង្វល់អំពីឯករាជ្យភាពរបស់ប្រព័ន្ធតុលាការកម្ពុជាក្តី ក៏ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិនៅតែគ្មានលទ្ធភាពបញ្ចុះបញ្ចូលអាជ្ញាធរកម្ពុជាឲ្យព្រមទទួលយកចំនួនចៅក្រមបរទេសភាគច្រើន និងប្រព័ន្ធបោះឆ្នោតហាសិបបូកមួយដដែល ។ ដូច្នេះហើយ ខណៈពេលដែលប្រព័ន្ធ "ភាគច្រើនដាច់ខាត" រក្សាទុកនៅដដែលរូបមន្តបោះឆ្នោតថ្មីគឺចៅក្រមបួនរូបក្នុងចំណោមប្រាំរូបនៅសាលាដំបូង និងចៅក្រមប្រាំរូបក្នុងចំណោមប្រាំពីររូបនៅសាលាកំពូល (មាត្រាទី៤) ។

ការព្យាយាមរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីចៀសវាងការរាំងខ្ទប់ដោយថាហេតុណាមួយនៅក្នុងដំណាក់កាលចោទប្រកាន់តាមរយៈការផ្តល់សិទ្ធិឲ្យព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតអន្តរជាតិ ឬបើមិនដូច្នោះទេផ្តល់ដល់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតនូវសិទ្ធិសម្រេចចុងក្រោយក្នុងករណីមានការមិនចុះសម្រុងគ្នា (តាមរយៈនេះទុកឲ្យអង្គបុរេជំនុំជម្រះជាអ្នកសម្រេច) ត្រូវបានច្រានចោលភ្លាមៗដោយភាគីកម្ពុជា ។ សម្បទានតែមួយគត់ដែលកម្ពុជាធ្វើក្នុងការតែងតាំងបុគ្គលិកបរទេសនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣គឺ ចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញាបរទេសដែលអវត្តមាននឹងត្រូវជំនួសដោយឈ្មោះដែលជ្រើសចេញពីបញ្ជីរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ក៏ប៉ុន្តែកិច្ចព្រមព្រៀងនេះមិនបានចែងអំពីករណីដែលអស់ឈ្មោះបេក្ខជនពីបញ្ជីឈ្មោះរបស់អង្គការសហប្រជាជាតិនោះទេ ។

មាត្រាទី២៦(៣)របស់សេចក្តីព្រាងអនុស្សរណៈយោគយល់បានចាត់ទុកតួនាទីរបស់អង្គការសហប្រជាជាតិថាជាកត្តាខាងក្រៅដោយចែងថាៈ *នៅក្នុងករណីបុគ្គលិកដែលខ្វះត្រូវបានបញ្ជូនមកដោយរដ្ឋនីមួយៗ ឬមូលនិធិដែលខ្វះបានទទួលមកពីមូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ "អង្គការសហប្រជាជាតិគួរតែរួចផុតពីកាតព្វកិច្ចរបស់ខ្លួន..." អនុលោមតាមកិច្ចព្រមព្រៀងនេះ ។* ក៏ប៉ុន្តែ ដើម្បីរក្សាឋានៈរបស់កិច្ចព្រមព្រៀងឆ្នាំ២០០៣ បទបញ្ញត្តិនេះត្រូវបានបោះបង់ចោលវិញ ។

ទាក់ទងទៅនឹងមុខតំណែងដ៏មានសារសំខាន់ គឺមុខតំណែងអនុប្រធានការិយាល័យរដ្ឋបាល កិច្ចព្រមព្រៀងឆ្នាំ២០០៣បានពង្រឹងមុខនាទីរបស់អង្គការសហប្រជាជាតិដោយដាក់បញ្ញត្តិជាក់លាក់ថា រាជរដ្ឋាភិបាលកម្ពុជាចាត់តាំងភ្លាមៗនូវអនុប្រធានបរទេសនៃការិយាល័យរដ្ឋបាលដែលតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## គ) យុត្តាធិការនិងនីតិវិធី

កិច្ចព្រមព្រៀងឆ្នាំ២០០៣បានបង្ហាញអំពីការផ្លាស់ប្តូរដ៏

គួរឲ្យចាប់អារម្មណ៍ចំពោះយុត្តាធិការដែលជាប់វិវាទរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយសារតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលែងត្រូវបានឲ្យនិយមន័យស្របទៅតាមតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាទៀតហើយ ក៏ប៉ុន្តែស្របទៅតាមលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ។ ទោះជាមិនជ្រើសរើសយកលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាក្តី ក៏លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិអាចនាំឲ្យមានបញ្ហាថ្មីៗជាច្រើនទៀត គឺបានចោទប្រកាន់រាល់អំពើទាំងឡាយណាដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលមានអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ។ ជាពិសេស "ការចោទប្រកាន់"ត្រូវបានពង្រីកដើម្បីរាប់បញ្ចូលអំពើដែល"ប្រឆាំងនឹងក្រុមមួយចំនួនដូចជា ក្រុមនយោបាយ ជាតិសាសន៍ សញ្ជាតិ ជាតិពន្ធ វប្បធម៌ សាសនា ភេទ... ឬរាប់បញ្ចូលហេតុផលផ្សេងៗទៀតដែលត្រូវបានហាមប្រាមនៅក្រោមច្បាប់អន្តរជាតិ..." (លក្ខន្តិកៈច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ មាត្រាទី៧(H)) ។

កិច្ចព្រមព្រៀងឆ្នាំ២០០៣បានពង្រីកនិងពង្រឹងនូវបទបញ្ញត្តិដែលមានស្រាប់នេះទាក់ទងទៅនឹង"បទដ្ឋានយុត្តិធម៌អន្តរជាតិ" ពោលគឺដោយដាក់បន្ថែមនូវសេចក្តីយោងដ៏ជាក់លាក់ទៅលើមាត្រាទី១៥របស់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ (មាត្រាទី១២) ។ ជាងនេះទៅទៀត ទោះជាមានការធានារបស់កម្ពុជាក៏ដោយ ក៏អង្គការសហប្រជាជាតិទទូចសុំឲ្យដាក់បញ្ចូលការអះអាងជាផ្លូវការនូវសិទ្ធិរបស់មេធាវីបរទេសឬមេធាវីក្នុងស្រុកទៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣ (មាត្រាទី១៣) ។ ខណៈដែលការដាក់បន្ថែមទាំងអស់នេះបានទទួលការយល់ព្រមក៏ពិតមែន កិច្ចព្រមព្រៀងនេះបានគូសបញ្ជាក់ថាគោលការណ៍ពាក់ព័ន្ធផ្សេងៗទៀតដូចជាបទបញ្ញត្តិចាប់ខ្លួននៃមាត្រាទី៩របស់អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មិនត្រូវបានដាក់បញ្ចូលទេ ។ បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀតដោយសារតែច្បាប់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញគ្រាន់តែតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញ "ស្វែងរកការណែនាំ" នៅក្នុងច្បាប់អន្តរជាតិដែលអាចទទួលយកបាន ។ ជាការពិតណាស់ ការរាប់បញ្ចូលនូវបទដ្ឋានទាំងអស់នេះនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣នឹងអាចជួយដោះស្រាយនូវចំណុចខ្សោយទាំងឡាយ ដោយសារតែកិច្ចព្រមព្រៀងនេះមានអាទិភាពខ្ពស់ជាងច្បាប់កម្ពុជា ។

កិច្ចព្រមព្រៀងឆ្នាំ២០០៣ក៏បានធ្វើសម្បទានដល់ភាគីទាំងសងខាងទាក់ទិនទៅនឹងសុពលភាពខាងផ្លូវច្បាប់នៃការលើកលែងទោសនិងការអត់ឱនទោសពីមុនៗមក ។ មួយវិញទៀត កិច្ចព្រមព្រៀងបានគោរពទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា តាមរយៈការជំនួសបញ្ញត្តិនៅក្នុងអនុស្សរណៈយោគយល់ដែលទាត់ចោលការលើកលែងទោសទាំងអស់ ដោយចែងនៅក្នុងច្បាប់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញហាមប្រាមរដ្ឋាភិបាលមិនឲ្យស្នើសុំការលើកលែងទោសដល់ជនណាម្នាក់ឡើយ ។ ម្យ៉ាងវិញទៀត កិច្ចព្រមព្រៀងឆ្នាំ២០០៣បានទទួលស្គាល់ជាផ្លូវការថា បញ្ហាខាងលើនេះគួរតែទុកឲ្យអង្គជំនុំជម្រះវិសាមញ្ញដោះស្រាយ (មាត្រាទី១១(២)) ។ ទោះជាបទបញ្ញត្តិនេះត្រូវបានពិពណ៌នាថា"មិនអាចទទួលយកបាន"បើប្រៀបធៀបជាមួយនឹងបទបញ្ញត្តិរបស់តុលាការអន្តរជាតិផ្សេងៗទៀតក៏ដោយ ក៏បទបញ្ញត្តិនេះត្រូវបានដាក់ជូនដោយហេតុផលថានេះជាដំណោះស្រាយដ៏ស្មើភាពតែមួយគត់ចំពោះបញ្ហាស្មុគស្មាញបែបនេះដែលលើកឡើងដោយអង្គជំនុំជម្រះក្តីនៅតុលាការក្នុងស្រុក ។

## ៧) សន្និដ្ឋានៈ គ្មានការផ្សះផ្សាជាតិណាមួយដោយមិនចាំបាច់មានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះទេ

បទពិសោធន៍របស់ប្រទេសកម្ពុជាបានគាំទ្រដល់ការអះអាងថា "សង្គមប្រជាធិបតេយ្យមួយមិនអាចបានមកពីការភូតកុហកឬការប្រមាថទៅលើអតីតកាលដ៏ឧក្រិដ្ឋបែបនេះទេ" ។ យុត្តិធម៌សម្រាប់បទឧក្រិដ្ឋជាធាតុផ្សំនៃការផ្សះផ្សាជាតិដ៏ចាំបាច់បំផុតបន្ទាប់អំពើឧក្រិដ្ឋកម្មទាំងឡាយត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ការបង្កើតសាលាជំនុំជម្រះក្តីអន្តរជាតិកន្លងមកជាពិសេសតុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានជួយឲ្យមានការរីក

ចម្រើនយ៉ាងខ្លាំងដល់ច្បាប់អន្តរជាតិ ។ តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែរចនាសម្ព័ន្ធដែលផ្អែកលើសន្ធិសញ្ញារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលចងភ្ជាប់តែរដ្ឋជាភាគីប៉ុណ្ណោះ នោះការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិមិនអាចបញ្ចប់នូវយន្តការផ្សេងៗទៀតទេ ។

នៅក្នុងគោលការណ៍ទាំងអស់នេះ ជម្រើសយុត្តិធម៌អន្តរកាលមួយចំនួននឹងនៅតែមាន រាប់ចាប់តាំងពីតុលាការអន្តរជាតិថ្មីពិសេសរហូតដល់មានការចោទប្រកាន់នៅក្នុងស្រុក ។ បែបផែនដ៏ស័ក្តិសមបំផុតសម្រាប់សភាពការណ៍ពិសេសនោះនឹងអាស្រ័យទៅលើការពិនិត្យពិចារណាក្នុងនិងក្រៅផ្លូវច្បាប់ ។ ភាពទៀងត្រង់របស់ភាគីទាំងសងខាងប្រហែលជាមានសារសំខាន់ដូចការធានាខាងផ្នែកបច្ចេកទេសសម្រាប់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដែរ ។ វាហាក់ដូចជាថា ស្ទើរតែរាល់ដំណោះស្រាយជាយថាហេតុណាមួយ រាប់បញ្ចូលទាំងជម្រើសមួយចំនួនដែលចង់បានសម្រាប់ដំណើរការជំនុំជម្រះក្នុងស្រុកមានលក្ខណៈអន្តរជាតិ ត្រូវបានប្រមើលសម្រាប់កម្ពុជាក្នុងឱកាសមួយឬឱកាសមួយទៀតកាលពីប្រាំឆ្នាំមុន ។ ប្រហែលជាយន្តការតែមួយគត់ដែលមិនមែនជាចំណុចសំខាន់សម្រាប់សំណើផ្លូវការគឺប្រព័ន្ធ"តុលាការពិសេស" ដែលបានប្រកាន់យកដោយប្រទេសសៀរ៉ាឡេអូន ។ នេះគឺមួយផ្នែកដោយសារតែទស្សនៈនេះកើតចេញពីការមិនសប្បាយចិត្តជាមួយនឹងដំណោះស្រាយដែលប្រកាន់យកដោយប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ បន្ទាប់ពីមានការទទូចរបស់រាជរដ្ឋាភិបាលសុំឲ្យថែរក្សា "អធិបតេយ្យភាព" ។

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញពិតជាបានចាប់ផ្តើមមែននោះ ការវិនិច្ឆ័យតាមផ្លូវច្បាប់អាចនាំឲ្យយល់កាន់តែច្បាស់ទៅលើស្ថានភាពច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ព្រមទាំងការលំបាកទាំងឡាយក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មកាលពីអតីតកាល ។

ក៏ប៉ុន្តែ យុត្តិធម៌បែបនេះនឹងមិនចំគោលដៅទេដរាបណាទម្រង់ដែលបានប្រកាន់យកអនុញ្ញាតឲ្យមានការប្តេជ្ញាចិត្តដ៏ត្រឹមត្រូវមួយអំពីការទទួលខុសត្រូវរបស់បុគ្គលពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ អង្គជំនុំជម្រះចម្រុះដ៏ស័ក្តិសមនេះគួរតែពិនិត្យពិចារណាការទាមទាររបស់ប្រជាជនកម្ពុជា រាប់ទាំងសេចក្តីត្រូវការឲ្យសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ ។ ទោះជាអង្គការសហប្រជាជាតិមិនបានលើកពីបញ្ហានេះក៏ដោយ ច្បាប់សម្រាប់អង្គជំនុំជម្រះបានទទួលផលប៉ះពាល់យ៉ាងធំធេងបើប្រៀបធៀបទៅនឹងតុលាការអន្តរជាតិដទៃៗទៀតដែលបានបង្កើតឡើងចាប់តាំងពីរចនាសម្ព័ន្ធនេះត្រូវបានចរចា ។ ដំណោះស្រាយរបស់កម្ពុជានៅចុងបញ្ចប់ស្ថិតនៅលើទំហំនៃអង្គជំនុំជម្រះវិសាមញ្ញបើប្រៀបធៀបជាមួយនឹងតុលាការសេរ៉ាឡេអូន ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគខាងផ្លូវច្បាប់លម្អិតស្តីអំពីសារជាតិរចនាសម្ព័ន្ធ និងឋានៈផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញថាគុណប្រយោជន៍នៃយុត្តិធម៌អន្តរជាតិបានគាំទ្រដល់សម្បទានខ្លះៗរបស់អង្គការសហប្រជាជាតិ បើទោះជាមិនគាំទ្រទាំងអស់ក៏ដោយ ។ បញ្ហាគឺថា រដ្ឋាភិបាលកម្ពុជាហាក់ដូចជាមានចំណាប់អារម្មណ៍"ចង់បិទរឿងនេះចោល"ជាជាង"ចង់បានយុត្តិធម៌" ។ តាមពិត ការតាំងចិត្តប្រកបដោយភាពច្បាស់លាស់ជាងមុនចំពោះយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមនឹងក្លាយជាតម្រូវការចាំបាច់សម្រាប់ភាគីទាំងសងខាង ប្រសិនបើការជំនុំជម្រះក្តីដ៏យុត្តិធម៌ត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ។ មធ្យោបាយមួយសម្រាប់កម្រិតនូវឱកាសបង្វែរទិសដៅយុត្តិធម៌គឺជាតួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការអនុម័តច្បាប់ស្តីពីនីតិវិធីដែលដាក់បញ្ចូលនូវរាល់បទបញ្ញត្តិពាក់ព័ន្ធទាំងអស់ ។

ការទទូចរបស់លោកអគ្គលេខាធិការសុំឲ្យមានអាណត្តិថ្មីមួយមុនពេលបន្តការចរចាគ្នា បានបង្ហាញថារចនាសម្ព័ន្ធនេះមិនបានគោរពទៅតាមអាណត្តិថ្មីៗរបស់លោកអគ្គលេខាធិការដែលចង់នាំមកនូវការផ្សះផ្សាជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលដោយយុត្តិធម៌ដែលជាដំណើរជំនុំជម្រះឯករាជ្យ ។ ការទទូចសុំនេះក៏បង្ហាញដែរថា អង្គការសហប្រជាជាតិត្រូវបានបញ្ចុះបញ្ចូលថាមានតែការគាំទ្រពីអន្តរជាតិប្រកបដោយនិរន្តរភាពទេទើបអាចនាំមកនូវក្តីសង្ឃឹមចំពោះលទ្ធផលដ៏ជោគជ័យមួយ ។

សេចក្តីសម្រេចចិត្តក្នុងការបន្តចូលរួមពីអង្គការសហប្រជាជាតិនឹងមានឥទ្ធិពលហួសពីក្របខ័ណ្ឌក្នុងស្រុក ដោយសារតែនៅក្នុងបរិបទនៃអង្គការច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលកំពុងព្យាយាមដាក់ចេញនូវគោលការណ៍រួមជាច្រើន ក្រុមអ្នកចរចាកម្ពុជាបានតាមដានយ៉ាងប្រកៀកប្រកិត ។ ទោះជាមានវោហារសាស្ត្រពីមុនៗមកក៏ដោយ អង្គការសហប្រជាជាតិមិនបានចាត់ទុកការសម្រុះសម្រួលរបស់កម្ពុជាថាជាគំរូមួយឋិតថេរយូរអង្វែងនោះទេ ។ ភាពចម្រុះគ្នានៃទិដ្ឋភាពកាលបរិច្ឆេទ នយោបាយ វប្បធម៌ និងផ្លូវច្បាប់ចំពោះកម្ពុជា នឹងបន្តការលំបាកក្នុងការផ្លាស់ប្តូរទៅរកស្ថានភាពដទៃផ្សេងៗទៀត សូម្បីតែការសម្រុះសម្រួលគ្នានេះមានដំណើរការនៅក្នុងប្រទេសកម្ពុជាក៏ដោយ ។

បទពិសោធន៍នៅអាហ្វ្រិកខាងត្បូងបានបង្រៀនយើងថាការផ្សះផ្សាជាតិពិតប្រាកដទាមទារឲ្យមានការយល់ដឹងអំពីការពិត ។ ក៏ប៉ុន្តែ រាល់ប្រទេសនីមួយៗដែលប្រឈមមុខនឹងបញ្ហានេះ ត្រូវតែមានសេរីភាពក្នុងការជ្រើសរើសនូវផ្លូវដើម្បីស្វែងរកការពិតនេះ ។ ខណៈដែលការពិតនេះមិនស្ថិតនៅក្នុងការចាប់អារម្មណ៍របស់អង្គការសហប្រជាជាតិដែលថាការចរចាខកខានមិនបានទទូចសុំឲ្យមានប្រព័ន្ធច្បាប់បរទេសជាជាងច្បាប់ប្រពៃណីរបស់កម្ពុជា គ្មានអ្វីទទួលបានពីការជំនុំជម្រះដែលមិនអាចរស់បានជាមួយបទដ្ឋានអន្តរជាតិនោះទេ ។

រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិបានជ្រើសរើសការនាំយកអង្គការនេះទៅកាន់តុចរចាវិញ ជាជាងគេចចេញពីអង្គការសហប្រជាជាតិហើយចូលទៅក្នុងការរៀបចំទ្វេភាគីជាមួយប្រទេសកម្ពុជានៅក្នុងបទបញ្ញត្តិបុគ្គលិកអន្តរជាតិ ឬក៏ដូតដៃឲ្យជ្រះពីកិច្ចការទាំងអស់នេះ ។ ជាគោលការណ៍ ការពិតដែលថាការជំនុំជម្រះក្តីខ្មែរក្រហមបានដំណើរការឡើងវិញត្រូវបានស្វាគមន៍ បើពិនិត្យមើលផលប៉ះពាល់ដោយសារតែនិទណ្ឌភាពទៅលើកិច្ចសន្យាសង្គមរបស់ប្រជាជនកម្ពុជានិងសណ្តាប់ធ្នាប់សីលធម៌អន្តរជាតិ ។ ទោះជាយ៉ាងណា ដោយលើកឡើងពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធច្បាប់កម្ពុជា លោកអគ្គលេខាធិការបានព្រមានថា «ការដែលរដ្ឋាភិបាលកម្ពុជាបង្វែរចំណាប់អារម្មណ៍ចេញពីកាតព្វកិច្ចដែលត្រូវអនុវត្តនឹងអាចនាំទៅដល់ការដកខ្លួនថយរបស់អង្គការសហប្រជាជាតិចេញពីកិច្ចសហប្រតិបត្តិការនិងការជួយឧបត្ថម្ភដំណើរការនេះ» ។ ចាប់តាំងពីមហាសន្និបាតយល់ព្រមសម្រុះសម្រួលជាថ្មីក្នុងភាពឯកច្ឆ័ន្ទ ឥឡូវនេះមហាសន្និបាតបានដាក់ទម្ងន់សហគមន៍អន្តរជាតិឲ្យនៅពីក្រោយដំណើរការនេះនិងពីក្រោយប្រជាជនកម្ពុជា ដើម្បីធានាឲ្យប្រាកដថាយុត្តិធម៌ត្រូវបានរកឃើញ ។

នៅទីបញ្ចប់ ប្រទេសកម្ពុជាបានបំពេញនូវរាល់សេចក្តីត្រូវការផ្លូវការទាំងអស់សម្រាប់ការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម ។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៤ តែពីរថ្ងៃប៉ុណ្ណោះមុនពិធីរាជាភិសេកព្រះមហាក្សត្រថ្មីរបស់ប្រទេសកម្ពុជា នរោត្តម សីហមុនី ប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម បានអនុម័តច្បាប់ដែលធ្វើវិសោធនកម្មលើច្បាប់ខ្មែរក្រហមឆ្នាំ២០០១ ដើម្បីធ្វើឲ្យច្បាប់នេះស្របទៅតាមកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិកាលពីខែមិថុនាឆ្នាំ២០០៣ស្តីអំពីការស្នើសុំជំនួយអន្តរជាតិសម្រាប់ការជំនុំជម្រះក្តី (ដែលត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភាជាតិកម្ពុជានៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤) ។ ឥឡូវនេះ ការពិភាក្សានឹងផ្តោតតែទៅលើបញ្ហាថវិកាប៉ុណ្ណោះ ។

**ជាទីជ ច័យ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ថ្នាក់លើរាយការណ៍ទៅថ្នាក់ក្រោម:*** គឺជាការរៀនសូត្រ ការផ្ញើទស្សនាវដ្តី ឯកសារសេចក្តីសម្រេចចាត់តាំងផ្សេងៗ ។

◆ ***អប់រំមនុស្ស:*** គឺការអប់រំកសាងសង្គមនិយម ។

◆ ***ភារកិច្ចធំ:*** គឺប្រមូលកម្លាំងទាំងអស់យល់ដល់លើ ការពារបូរណភាពនិងអធិបតេយ្យព្រមជាមួយនោះការពារលទ្ធផលនៃធនធានរបស់បដិវត្តន៍ ។

***(សៀវភៅកំណត់ហេតុ២០៩)***

◆ ***មូលដ្ឋាន:*** ជាគ្រឹះដ៏រឹងមាំ ឬជាទម្រង់ដ៏រឹងមាំ ។

◆ ***សមូហភាព:*** ការប្រមូលផ្តុំសង្គមមនុស្ស ។

***(សៀវភៅកំណត់ហេតុអ៊ីវ)***

# សេចក្តីថ្លែងការណ៍របស់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ស្តីអំពីសន្តិសុខសម្រាប់សាក្សីនិងជនរងគ្រោះក្នុងការធ្វើជាកសិណសាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញ

នៅពេលដែលយើងកំពុងឈានទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះ យើងមានការលើកទឹកចិត្តដោយបានឃើញថា សាធារណជនកាន់តែមានការចាប់អារម្មណ៍ចំពោះដំណើរការនេះ និងទទួលបានការរួមវិភាគទានក្នុងន័យស្ថាបនា ដើម្បីធ្វើឲ្យការជំនុំជម្រះក្តីដែលត្រូវបានអូសបន្លាយនេះសម្រេចបានជោគជ័យ ។

ទោះជាយ៉ាងណាក្តី យើងក៏មានកង្វល់ដែរចំពោះការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ប្រាសចាកពីការពិតដែលអាចបណ្តាលឲ្យមានការព្រួយបារម្ភដែលមិនចាំបាច់នៅក្នុងដំណើរឆ្ពោះទៅរកការជំនុំជម្រះក្តីនោះ ។ ថ្មីៗកន្លងទៅនេះ អ្នកដឹកនាំអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលមួយចំនួន ព្រមទាំងក្រុមប្រតិភូដែលចូលរួមនៅក្នុងសន្និសីទមួយនៅទីក្រុងភ្នំពេញស្តីអំពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម បានចេញនូវសេចក្តីថ្លែងការណ៍មិនត្រឹមត្រូវមួយចំនួនដែលយើងសូមធ្វើការកែតម្រូវដូចខាងក្រោមនេះៈ

១-សន្តិសុខរបស់សាក្សីៈ ទីភ្នាក់ងារព័ត៌មាន *Associated Press* បានសរសេរថា "អង្គការសិទ្ធិមនុស្សកម្ពុជាអាដហុក និងលីកាដូ បាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា គ្មានគម្រោងថវិកាសម្រាប់សន្តិសុខរបស់សាក្សីទេ ដូចជាការរក្សាទុកសាក្សីនៅក្នុងកន្លែងមានសុវត្ថិភាពឬការផ្តល់ការការពារនូវអត្តសញ្ញាណរបស់ពួកគេ" ។

ការនិយាយបែបនេះមិនត្រឹមត្រូវទេ ។ ចាប់តាំងពីការពិភាក្សាលើកដំបូងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ រឿងសន្តិសុខគឺជាបញ្ហាសំខាន់មួយដែលទទួលបានការគិតគូរយ៉ាងម៉ត់ចត់ ហើយរាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវក្នុងការចាត់វិធានការប្រកបដោយប្រសិទ្ធភាពនិង"សមស្របដែលចាំបាច់ដើម្បីធានានូវសុវត្ថិភាពនិងការការពារចំពោះបុគ្គលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ" (កិច្ចព្រមព្រៀង មាត្រា២៤) ហើយ"អង្គជំនុំជម្រះវិសាមញ្ញ...ត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់និងកិច្ចការពារអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ" (ច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញ មាត្រា៣៣) ។

ភាគីទាំងពីរក៏បានព្រមព្រៀងផងដែរថា "អង្គការសហប្រជាជាតិទទួលខុសត្រូវលើ...ការធ្វើដំណើររបស់សាក្សីដែលមកពីក្នុងនិងមកពីក្រៅប្រទេសនិងការរៀបចំសុវត្ថិភាពនិងសន្តិសុខដូចដែលបានព្រមព្រៀងគ្នាដាច់ដោយឡែករវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាល" ។

សេចក្តីលម្អិតនៃការរៀបចំសុវត្ថិភាពនិងសន្តិសុខមាននៅក្នុងផែនការនិងគម្រោងថវិកាដែលភាគីទាំងពីរបានរៀបចំយ៉ាងសកម្ម ។ គណៈកម្មាធិការសន្តិសុខជាន់ខ្ពស់មួយត្រូវបានបង្កើតឡើងនៅក្រសួងមហាផ្ទៃកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៤ ហើយអង្គការសហប្រជាជាតិក៏បានបញ្ចូលអ្នកជំនាញខាងសន្តិសុខនៅគ្រប់បេសកកម្មវាយតម្លៃផ្នែកបច្ចេកទេសនាពេលថ្មីៗនេះមកកម្ពុជាដែរ ។

២-ការភ័យខ្លាចក្នុងការធ្វើជាកសិណសាក្សីៈ យើងក៏មានកង្វល់ផងដែរចំពោះការដែលអ្នករៀបចំសន្និសីទនិងប្រតិភូដែលជាវាគ្មិនខ្លះបានលើកឡើងថា គេមានការភ័យខ្លាចក្នុងការធ្វើជាកសិណសាក្សី ។ សេចក្តីថ្លែងការណ៍នេះគឺផ្ទុយគ្នាទៅនឹងលទ្ធផលដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានមកពីការស្រាវជ្រាវនិងការស្ទង់មតិជាច្រើនលើកច្រើនសារួចមកហើយដែលបានបញ្ជាក់ថា ប្រជាជនកម្ពុជាទាំងជនរងគ្រោះក៏ដូចជាចារីជន មានបំណងយ៉ាងមុតមាំថានឹងធ្វើជាសាក្សីអំពីបទពិសោធន៍របស់ខ្លួននៅក្រោមរបបខ្មែរក្រហម ។

៣-ការជួសជុលជាសំណងៈ អ្នករៀបចំសន្និសីទទាំងនោះត្រូវបានស្រង់សម្តីថា "គ្មានថវិកាសម្រាប់ការចេញសំណងជាទឹក

ប្រាក់ដល់ជនរងគ្រោះឡើយ គ្មានមធ្យោបាយណាមួយសម្រាប់ឲ្យជនរងគ្រោះបានចូលរួមក្នុងតុលាការ ឬគ្មានការគាំទ្រដល់ជនទាំងឡាយដែលនៅមានរបួសផ្លូវចិត្តនៅឡើយពីរបបខ្មែរក្រហម» ។

នៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជនរងគ្រោះមានសិទ្ធិចូលរួមជាភាគីរដ្ឋប្បវេណី ក្នុងរឿងក្តីព្រហ្មទណ្ឌ និងទាមទារនូវសំណងដល់ការខូចខាតដែលគេបានរងគ្រោះពីបទល្មើសដែលកំពុងជំនុំជម្រះ ។ ជាទូទៅតុលាការតម្រូវឲ្យជនដែលមានពិរុទ្ធសងជាទឹកប្រាក់ចំពោះការខូចខាតទាំងឡាយ ។ តើអង្គជំនុំជម្រះវិសាមញ្ញអាចដោះស្រាយយ៉ាងដូចម្តេចចំពោះសិទ្ធិនេះក្នុងស្ថានភាពមួយដែលពលរដ្ឋខ្មែរគ្រប់រូបអាចទាមទារថាខ្លួនទទួលរងការខូចខាតទាំងនេះ នេះជារឿងដែលត្រូវគិតគូរឲ្យបានប្រុងប្រយ័ត្ន ។ ពួកគេអាចប្រហែលជាមិនអាចទទួលបានអ្វីផ្សេងក្រៅពីសំណងដែលគ្រាន់ជានិមិត្តរូបប៉ុណ្ណោះ ដោយ ហេតុថា ទណ្ឌិតរាជរដ្ឋាភិបាលកម្ពុជាឬរដ្ឋាភិបាលដទៃទៀតឬអង្គការសហប្រជាជាតិពុំអាចមានលទ្ធភាពផ្តល់នូវថវិកាសម្រាប់ជួសជុលជាសំណងជាទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ បន្ថែមទៅលើថវិកាចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនោះឡើយ ។

យើងម្នាក់ៗគួរតែចាប់អារម្មណ៍ទៅលើពាក្យ «ការជួសជុលជាសំណង» ដែលពាក្យនេះក្លាយមកពីពាក្យ «ជួសជុល» ហើយមូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗក្នុងការបង្កើតតុលាការនេះគឺដើម្បីជួសជុលការខូចខាតដល់ប្រជាជនកម្ពុជាដោយនៅចុងបញ្ចប់ផ្តល់ឲ្យពួកគេនូវការទទួលស្គាល់ និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានធ្វើមកលើពួកគេ ។ លុយកាក់មិនមែនជាទម្រង់នៃការជួសជុលជាសំណងដ៏ចាំបាច់និងមានតម្លៃតែមួយគត់សម្រាប់ផ្តល់ជូនជនរងគ្រោះនោះទេ ។

ផ្នែកគាំពារសាក្សីនិងជនរងគ្រោះមួយនឹងត្រូវបង្កើតឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ក្រុមការងាររាជរដ្ឋាភិបាលទទួលបន្ទុកការជំនុំជម្រះក្តីខ្មែរក្រហមបានធ្វើការបោះពុម្ពផ្សាយនូវកូនសៀវភៅមួយក្រោមចំណងជើងថា «ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម» (បោះពុម្ពផ្សាយជាភាសាខ្មែរនិងភាសាអង់គ្លេស) ហើយបានចែកចាយដល់គ្រប់ឃុំសង្កាត់នៃប្រទេសកម្ពុជា ។ កូនសៀវភៅនេះបានពន្យល់ដល់សាធារណជនយ៉ាងទូលំទូលាយអំពីការគាំពារចំពោះសាក្សីនេះ និងផ្តល់ព័ត៌មានអំពីសេវាពិគ្រោះយោបល់ដែលមាននៅគ្រប់ខេត្ត ។

យើងសូមឲ្យសាធារណជនដែលមានចំណាប់អារម្មណ៍និងអង្គការទាំងឡាយអានកូនសៀវភៅនេះ ។ បន្ថែមពីលើនេះ សូមពិនិត្យមើលគេហទំព័រ *www.cambodia.gov.kh/krt/* ដែលមាននូវអត្ថបទច្បាប់ទាំងស្រុងនិងកិច្ចព្រមព្រៀងក៏ដូចជាឯកសារពាក់ព័ន្ធផ្សេងៗទៀត ឬក៏ទំនាក់ទំនងជាមួយនឹងលេខាធិការដ្ឋាននៃក្រុមការងារដែលឋិតនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទូរស័ព្ទនិងទូរសារលេខ ០២៣ ៤២៨ ៩៥២ ឬតាមអ៊ីមែល *stf@nida.gov.kh* ។

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **សុ ហ្វារីណា និង លី សុផល**

# សេចក្តីថ្លែងការណ៍របស់សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស សមាគមអាដហុក និងអង្គការលីកាដូ ពាក់ព័ន្ធនឹងការការពារសាក្សីនិងជនរងគ្រោះ ប៉ារីស-ភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៥

*សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស (FIDH) សមាគមអាដហុក (ADHOC) និងអង្គការលីកាដូ (LICADHO) សូមសម្តែងនូវការស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍របស់ក្រុមការងាររដ្ឋាភិបាលទទួលបន្ទុកអង្គជំនុំជម្រះវិសាមញ្ញកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៥ ស្តីអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំពារសន្តិសុខសាក្សីនិងជនរងគ្រោះនៅអំឡុងពេលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។*

*ការលើកឡើងរបស់វាគ្មិននៅក្នុងសន្និសីទទាក់ទងនឹងការព្រួយបារម្ភចំពោះសន្តិសុខរបស់សាក្សីនិងជនរងគ្រោះ បានឆ្លុះបញ្ចាំងអំពីកង្វល់របស់ប្រជាពលរដ្ឋកម្ពុជាដែលបានចូលរួមនៅក្នុងសន្និសីទនេះ ។ អ្នកចូលរួមក្នុងសន្និសីទនេះ ខ្លះបានលើកឡើងនូវការព្រួយបារម្ភអំពីជនជាប់ចោទ ជាពិសេសចំពោះជនជាប់ចោទដែលរស់នៅក្នុងទីក្រុងប៉ៃលិន ចំណែកឯអ្នកដទៃទៀតបានសម្តែងការព្រួយបារម្ភអំពីការគំរាមកំហែងពីសំណាក់អ្នកដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុន្តែមិនត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកចូលរួមដទៃទៀតនៅក្នុងសន្និសីទនោះ បាននិយាយថា ខ្លួនចង់ផ្តល់សក្ខីភាពនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនមានការព្រួយបារម្ភទាល់តែសោះ ។ ជាការពិត ថ្វីត្បិតតែច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងសន្តិសុខរបស់ជនរងគ្រោះនិងសាក្សីមិនបានចែងឲ្យបានច្បាស់ ប៉ុន្តែបានទទួលស្គាល់ថា ជនរងគ្រោះនិងសាក្សីគួរតែទទួលបានការការពារស្របច្បាប់នៅមុនពេលមានសវនាការ អំឡុងពេលសវនាការ និងក្រោយពេលសវនាការ ។*

*ទោះបីជាយ៉ាងណាក៏ដោយ គម្រោងការជាទូទៅនេះចាំបាច់ត្រូវមានការបំពេញបន្ថែមនិងត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីកាត់បន្ថយការព្រួយបារម្ភ ។ សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្សសូមសម្តែងការស្វាគមន៍ចំពោះការបង្កើត "គណៈកម្មាធិការសន្តិសុខកម្រិតខ្ពស់" សម្រាប់ការពារសន្តិសុខដល់សាក្សីនិងជនរងគ្រោះ ព្រមទាំងមានក្តីសង្ឃឹមយ៉ាងមុតមាំថាអង្គការក្រៅរដ្ឋាភិបាលនឹងត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងដំណើរការនេះ ព្រមទាំងត្រូវបានផ្តល់ព័ត៌មានអំពី "ការរៀបចំសន្តិសុខដោយឡែក" ដែលបានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ។*

### ការចូលរួមរបស់ជនរងគ្រោះ

*គួរតែមានការជំរុញឲ្យមានការអះអាងជាផ្លូវការផងដែរអំពីសិទ្ធិរបស់ជនរងគ្រោះនៅក្រោមច្បាប់កម្ពុជាក្នុងការចូលរួមស្តាប់សវនាការក្នុងនាមជាភាគីរដ្ឋប្បវេណី ត្រូវតែយកមក*


ប៊ុន ជីង
យុទ្ធជននៅមន្ទីរស-២១

អនុវត្តនៅក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ទោះជាយ៉ាងណាក៏ដោយ សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស សមាគមអាដហុក និងអង្គការលីកាដូ បានកត់សម្គាល់ថា ក្រុមការងាររបស់រដ្ឋាភិបាលបានសម្តែងនូវការព្រួយបារម្ភអំពីការអនុវត្តសិទ្ធិនេះនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន ។

ជាការពិត គោលបំណងចម្បងនៃសិក្ខាសីលាដែលរៀបចំដោយសហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស សមាគមអាដហុក និងអង្គការលីកាដូ នៅទីក្រុងភ្នំពេញកាលពីថ្ងៃទី២និងទី៣ ខែមីនា ឆ្នាំ២០០៥ គឺដើម្បីពង្រីកការយល់ដឹងនៅក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលនិងជនរងគ្រោះ អំពីតម្រូវការក្នុងការប្រមើលមើលអំពីយន្តការសម្រាប់ការចូលរួមយ៉ាងមានប្រសិទ្ធភាពរបស់ជនរងគ្រោះ និងដើម្បីពង្រីកបន្ថែមនូវយន្តការដែលមានស្រាប់សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ការធានានូវសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងផ្តល់ឲ្យជនរងគ្រោះទាំងនោះនូវការយល់ដឹងកាន់តែទូលាយជាងមុនអំពី «ភាពជាកម្មសិទ្ធិ» នៃអង្គជំនុំជម្រះវិសាមញ្ញ និងធានាសិទ្ធិរបស់ជនរងគ្រោះទាំងនោះ តាមរយៈមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ពោលគឺការចូលរួមនិងការតំណាងផ្នែកច្បាប់ ។


ជា ហុន
យុទ្ធជននៅមន្ទីរស-២១

ដោយឡែក បើយើងត្រួតពិនិត្យមើលអំពីអវត្តមាននៃការនិយាយយោងជាពិសេសទៅរកភាគីរដ្ឋប្បវេណីនៅក្នុងឯកសារច្បាប់ដែលពាក់ព័ន្ធ សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស សមាគមអាដហុក និងអង្គការលីកាដូ នឹងសម្តែងការស្វាគមន៍ចំពោះការបកស្រាយដែលថា ខចែងដែលទាក់ទងនឹងការការពារជនរងគ្រោះនិងសាក្សី (មាត្រា៣៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ) ឯករាជ្យភាពរបស់មេធាវី (មាត្រា៤២-៣ នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ) និងឯករាជ្យភាពនៃសាក្សីនិងអ្នកជំនាញការ (មាត្រា២២នៃកិច្ចព្រមព្រៀង) នឹងត្រូវបានអនុវត្តដោយសមភាពចំពោះជនរងគ្រោះក្នុងនាមជាភាគីរដ្ឋប្បវេណី មេធាវី សាក្សី និងអ្នកជំនាញការ ។

## ការជួសជុលសំណង

ជុំវិញបញ្ហាជួសជុលសំណងជំងឺចិត្ត សហព័ន្ធអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស សមាគមអាដហុក និងអង្គការលីកាដូ សូមសម្តែងការស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍របស់ក្រុមការងាររដ្ឋាភិបាលដែលថាខ្លួនកំពុងតែពិចារណាអំពីការជួសជុលសំណងនេះ ។ ការជួសជុលសំណងរួមមានៈ ការសងជំងឺចិត្តនិងការធ្វើឲ្យប្រសើរឡើងវិញ ។ វាមិនមែនមានន័យថាចាំបាច់ត្រូវតែមានសំណងជាថវិកានោះទេ ប៉ុន្តែទម្រង់នៃសំណងអាចមានលក្ខណៈជារូបឬជានិមិត្តរូប ក៏ដូចជាសិទ្ធិក្នុងការទទួលបាននូវជំនួយផ្នែកចិត្តសាស្ត្រ ។ ការលើកឡើងខ្លះៗទាក់ទងនឹងទម្រង់នៃសំណងរួមមាន ការសាងសង់បូជនីយដ្ឋាន ការរៀបចំពិធីសាសនាឬពិធីបញ្ចុះ និងការលាតត្រដាងការពិតដែលរួមមានទាំងការរៀបចំសៀវភៅសិក្សាអំពីរបបនេះ ។

ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងសម្រេចអំពីទម្រង់និងទំហំនៃការសងជំងឺចិត្ត ហើយរាជរដ្ឋាភិបាលកម្ពុជានឹងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការសហការនិងជួយសម្រួលដល់ការអនុវត្តសាលក្រម ដោយសារថាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា ទ្រព្យសម្បត្តិទាំងអស់ដែលទទួលបានដោយខុសច្បាប់របស់អ្នកដែលរកឃើញថាមានទោសនឹងត្រូវប្រគល់ជូនរដ្ឋ ។

# ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជាៈ សម្រាប់ការផ្សះផ្សាជាតិនិងការកសាងសន្តិភាព

(តពីលេខមុន)

### ជំពូក២

### ការអប់រំអំពីសន្តិភាពៈ ការអប់រំសម្រាប់ការផ្លាស់ប្តូរសង្គម

## ១) សេចក្តីផ្តើម

បន្ទាប់ពីមានស្នាដៃជាច្រើនត្រូវបំផ្លិចបំផ្លាញដោយសារសង្គ្រាមរួចមក ប្រជាជនចាប់ផ្តើមដឹងថា សេដ្ឋកិច្ចតែឯងមិនអាចជួយអភិវឌ្ឍន៍ពិភពលោកបានទេ ។ សន្តិសុខពិភពលោកអាចរក្សាបានតាមរយៈការជំរុញឲ្យមាន“វប្បធម៌សន្តិភាព”និងការបញ្ចូលបន្ថែមវប្បធម៌នេះទៅក្នុងប្រព័ន្ធអប់រំ ។

ការអប់រំអំពីសន្តិភាពបានក្លាយទៅជាការអប់រំដ៏មានឥទ្ធិពលមួយនៅក្នុងសង្គមបច្ចុប្បន្ន ។ ក្នុងការធ្វើឲ្យពិភពលោកជឿជាក់ថាការប្រើកម្លាំងយោធាមិនមែនជាដំណោះស្រាយសម្រាប់បញ្ហាជម្លោះទេ ការអប់រំអំពីសន្តិភាពសំដៅទៅរកការកាត់បន្ថយអំពើហិង្សានៅក្នុងពិភពលោក ។ ការអប់រំអំពីសន្តិភាពជួយបង្កើនសេវាសុខភាព យុត្តិធម៌សង្គម និងការផ្លាស់ប្តូរសង្គម តាមរយៈមេរៀននៃការមិនប្រើប្រាស់អំពើហិង្សារបស់ការអប់រំនេះ និងការជួយដល់អ្នកសិក្សាក្នុងការដោះស្រាយបញ្ហាផ្សេងៗ ។ ការអប់រំនេះទៀតសោតក៏ជះឥទ្ធិពលយ៉ាងខ្លាំងក្នុងការធ្វើឲ្យមនុស្សអាចបន្ថយភាពមិនអើពើការមិនចូលចិត្តចូលរួមក្នុងសង្គម អគតិ ភាពក្រអឺតក្រទម និងការធ្វើមិនដឹងព្រុជាដើម ផ្ទុយទៅវិញបែរជាលើកស្ទួយសមត្ថភាពមនុស្សឲ្យមានការយល់ដឹងនិងចូលរួមជាមួយអ្នកដទៃ ។

ដូច្នេះ តើ “ការអប់រំស្តីពីសន្តិភាព” មានលក្ខណៈបែបណា? តើវាមានតួនាទីអ្វីខ្លះនិងមានគុណសម្បត្តិអ្វីខ្លះចំពោះពិភពលោក?

## ២) និយមន័យ

បីតទី រៀដុន ដែលជានាយកនិងជាអ្នកបង្កើតមជ្ឈមណ្ឌល “ការអប់រំសន្តិភាព” នៅសាកលវិទ្យាល័យកូឡុំបៀនៃទីក្រុងញូវយ៉កបាននិយាយថា “ការអប់រំអំពីសន្តិភាព” គឺជាផ្នែកមួយនៃចំណេះដឹងដែលជួយបង្ហាញផ្លូវឆ្ពោះទៅរកសន្តិភាពនិងរក្សាសន្តិភាព ។ អ្នកចូលរួមក្នុងកម្មវិធីអប់រំនេះគឺតម្រូវឲ្យមានថ្នាក់ហ្វឹកហ្វឺនជាច្រើនដើម្បីបង្កើនជំនាញចំណេះដឹងនិងសមត្ថភាព និងដើម្បីប្រើប្រាស់ការយល់ដឹងទាំងនេះក្នុងការជម្នះលើបញ្ហាទាំងឡាយ ។

នៅក្នុងព្រឹត្តិបត្រ “ភាសានិងសង្គមស៊ីវិល និង ភាសានិងវិទ្យាសាស្ត្រជីវិត” បានផ្តល់ការយល់ឃើញអំពីការអប់រំនេះថា គោលការណ៍នៃ“ការអប់រំស្តីអំពីសន្តិភាព” ជួយអភិវឌ្ឍន៍អ្នកសិក្សាឲ្យមានការយល់ដឹងនិងជំនាញកាន់តែប្រសើរ ហើយការវិវឌ្ឍន៍ទាំងនេះមានសារសំខាន់យ៉ាងខ្លាំងក្នុងការធ្វើឲ្យអ្នកសិក្សាទាំងនេះក្លាយជាមនុស្សឆាប់យល់ពីអ្នកដទៃ មានអំណត់ និងមានឆន្ទៈល្អ ។ ការអប់រំនេះក៏ជួយបង្ហាញផ្លូវដល់មនុស្សជាច្រើនដូចជា ការគោរពចំពោះកិត្តិយសនិងវប្បធម៌ដទៃ និងការប្រើប្រាស់ភាពស្ងប់ស្ងាត់ ។ រួមជាមួយនឹងមេរៀននៅក្នុងការសិក្សាស្តីអំពីសន្តិភាព បញ្ហាជាច្រើនអាចដោះស្រាយបានដោយសន្តិវិធី តាមរយៈការសិក្សាអំពីជំនាញនៃទំនាក់ទំនងសង្គម ការស្តាប់និងគិតជិតដល់ និងបង្កើនចំណងទាក់ទងរវាងប្រជាជននិងប្រទេស និងរវាងមនុស្សនិងបរិស្ថានធម្មជាតិ ។ លើសពីនេះទៅទៀត អង្គការយូនីសេហ្វបានពោលថា ការអប់រំអំពីសន្តិភាពគឺជាដំណើរការនៃការបង្កើនចំណេះដឹង ឥរិយាបថ និងតម្លៃចាំបាច់ក្នុងការនាំមកនូវការផ្លាស់ប្តូរ ដែលជួយឲ្យកុមារ យុវជន និងមនុស្សពេញវ័យ អាចការពារមិនឲ្យមានជម្លោះនិងការប្រើអំពើហិង្សាតាមរយៈការមើលឃើញក្នុងពេលអនុវត្តន៍ និងការបង្ក្រៀនតាមក្បួនខ្នាត ។ វាក៏អាចជួយឲ្យមនុស្សមានសមត្ថភាពដោះស្រាយជម្លោះដោយសន្តិវិធី និងបង្កើតជាស្ថានការណ៍ដែលនាំមកនូវសន្តិភាព មិនថានៅកម្រិតជាបុគ្គល ជាក្រុម ជា

ប្រទេស ឬជាអន្តរជាតិឡើយ ។

ហារីស និង ម៉ារីសុន ក៏មានការយល់ឃើញប្រហាក់ប្រហែលនឹងគំនិតនេះដែរគឺថា "ការអប់រំអំពីសន្តិភាព" គឺជាទស្សនៈវិជ្ជាមួយនិងជាដំណើរការដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជំនាញនៃការស្តាប់ ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការសហការ និងដំណោះស្រាយជម្លោះផ្សេងៗ ។ បើនិយាយអំពីការបង្កើនភាពទុកចិត្តចំពោះសុវត្ថិភាពពិភពលោក និងការថែរក្សាបរិស្ថានធម្មជាតិ ដំណើរការនៃការអប់រំនេះមិនមែនត្រឹមតែទាក់ទងតែនឹងជាមួយជំនាញឥរិយាបថ និងចំណេះដឹងសម្រាប់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្រៀនមនុស្សអំពីភាពអហិង្សា សេចក្តីស្រលាញ់ សេចក្តីមេត្តា និងការគោរពចំពោះវប្បធម៌ដទៃ ។

និយាយរួម "ការអប់រំអំពីសន្តិភាព" គឺមានគោលដៅសម្រាប់បង្កើត "សន្តិភាព" ។ គោលការណ៍របស់ការអប់រំនេះទៀតសោតគឺសម្រាប់អប់រំមនុស្សអំពីចំណេះដឹង តម្លៃ និងជំនាញដែលចាំបាច់ក្នុងការរក្សាសន្តិភាពឲ្យនៅស្ថិតស្ថេរ ។ ស៊ីមិន ហ៊ីស័រ (នាយកនៃអង្គការ "ឆ្លើយតបទៅនឹងជម្លោះ») សន្មតថា "ការអប់រំអំពីសន្តិភាពបង្កើតឲ្យមានការស្តារបញ្ហាមួយចំនួនឲ្យមានតុល្យភាពឡើងវិញ ។ វាតម្រង់មនុស្សឲ្យយល់ឃើញថាមានជម្រើសនិងលទ្ធភាពច្រើនក្នុងការរស់នៅប្រកបដោយសុខដុមរម្យនារវាងមនុស្សនិងមនុស្ស និងរវាងមនុស្សនិងធម្មជាតិ" ។

មកដល់ចំណុចនេះនឹងមានការពន្យល់បង្ហាញអំពីលក្ខណៈនិងផលប្រយោជន៍នៃកម្មវិធីជាច្រើនរបស់ "ការអប់រំអំពីសន្តិភាព" ដែលរួមមានចំណេះដឹង តម្លៃ និងជំនាញ ។

## ៣) ចំណេះដឹង តម្លៃ និងជំនាញ

អ្នកជំនាញការ សាស្ត្រាចារ្យ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន កំពុងធ្វើការយ៉ាងជិតស្និទ្ធក្នុងការអភិវឌ្ឍ"ការអប់រំអំពីសន្តិភាព" ។ ជាលទ្ធផល អ្នកទាំងនេះបានបង្កើតជាកម្មវិធីសិក្សាមួយដែលចេញពីការបូកផ្សំគ្នានៃចំណេះដឹង តម្លៃ និងជំនាញជាច្រើន ។ អង្គការសហប្រជាជាតិបានពិនិត្យការអប់រំអំពីប្រធានបទនេះនៅពាសពេញពិភពលោក ហើយបានសន្និដ្ឋានថា ទំនាក់ទំនងរវាងចំណេះដឹង តម្លៃ និងជំនាញ មានលក្ខណៈឯករាជ្យពីគ្នាដូចមានបង្ហាញខាងក្រោមនេះ÷

**ជំនាញ**

- ◆ ទំនាក់ទំនងការស្តាប់ដោយយកចិត្តទុកដាក់ និងការត្រិះរិះពិចារណា
- ◆ ការសហការ
- ◆ ក្តីអាណិតនិងមេត្តា
- ◆ ការពិចារណាជិតដល់ និងការដោះស្រាយបញ្ហា
- ◆ ភាពប៉ិនប្រសប់និងប្រកបដោយសោភ័ណ
- ◆ ការផ្សះផ្សា ការចរចា និងដំណោះស្រាយជម្លោះ
- ◆ ភាពអត់ធ្មត់ និងការទប់អារម្មណ៍ខ្លួនឯង
- ◆ ទំនួលខុសត្រូវក្នុងនាមជាពលរដ្ឋ
- ◆ ការស្រមៃ
- ◆ ការដឹកនាំ និងចក្ខុវិស័យ

**ចំណេះដឹង**

ការដឹងដោយខ្លួនឯង ពោលគឺការទទួលស្គាល់ការរើសអើងបញ្ហាផ្សេងៗជាច្រើនដែលទាក់ទងទៅនឹង÷

- ◆ ជម្លោះនិងសង្គ្រាម
- ◆ សន្តិភាពនិងអហិង្សា
- ◆ បរិស្ថាននិងបរិស្ថានវិទ្យា
- ◆ អាវុធនុយក្លេអ៊ែរ និងអាវុធផ្សេងៗ
- ◆ យុត្តិធម៌និងអំណាច
- ◆ ទ្រឹស្តីនៃការវិភាគជម្លោះ ការគាំពារ និងដំណោះស្រាយ
- ◆ វប្បធម៌ ពណ៌សម្បុរ ភេទ និងសាសនា
- ◆ សិទ្ធិមនុស្សនិងការទទួលខុសត្រូវ
- ◆ សាកលភាវូបនីយកម្ម
- ◆ ពលកម្ម
- ◆ ភាពក្រីក្រ និងសេដ្ឋកិច្ចអន្តរជាតិ
- ◆ ច្បាប់អន្តរជាតិ និងតុលាការព្រហ្មទណ្ឌ
- ◆ អង្គការសហប្រជាជាតិ និងប្រព័ន្ធអន្តរជាតិ បទដ្ឋាន និងសន្ធិសញ្ញានិងច្បាប់អន្តរជាតិ
- ◆ សេវាកម្មសុខភាព ជំងឺអេដស៍
- ◆ ការជួញដូរថ្នាំញៀន

**ឥរិយាបថ**

◆ ការយល់ដឹងអំពីបរិស្ថាន
◆ ការគោរពខ្លួនឯង
◆ ការអត់ធ្មត់
◆ ការគោរពតម្លៃជាមនុស្សនិងភាពខុសប្លែកគ្នា
◆ ការយល់ដឹងអំពីវប្បធម៌ដទៃ
◆ ការយល់ដឹងអំពីភេទ
◆ ការយកចិត្តទុកដាក់ និងការយល់ចិត្ត
◆ អហិង្សានិងការផ្សះផ្សា
◆ ទំនួលខុសត្រូវសង្គម
◆ សាមគ្គីភាព ដំណោះស្រាយប្រកបដោយភាពអន់ខិន នៅក្នុងពិភពលោក

មាន «ការអប់រំអំពីសន្តិភាព» ជាច្រើនប្រភេទដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ណាមួយ នៅក្នុងករណីផ្សេងៗ នៅលើពិភពលោក ។

**៤) ការស្ទាបស្ទង់មតិលើ «ការអប់រំអំពីសន្តិភាព»**

**ក) ប្រភេទនៃ «ការអប់រំអំពីសន្តិភាព»**

មានវិធីពីរក្នុងការពន្យល់អំពីការអប់រំនេះ ។ ទីមួយការអប់រំក្នុងរយៈពេលខ្លី ជាកម្មវិធីដែលសិក្សាច្បាស់លាស់លើបញ្ហាជម្លោះ ហើយកម្មវិធីនេះក៏មានសារសំខាន់យ៉ាងខ្លាំងក្នុងការកំណត់រកបញ្ហានៃជម្លោះមួយនិងផ្តល់នូវដំណោះស្រាយជាច្រើនចំពោះបញ្ហានោះ ។ ទីពីរគឺជាកម្មវិធីមួយដែលសិក្សាអំពីមូលដ្ឋានគ្រឹះដ៏ទូលំទូលាយដែលសង្កត់ធ្ងន់លើការលើកស្ទួយសន្តិភាពយូរអង្វែងនៅក្នុងសង្គមទូទៅ ។

**◆ ការអប់រំរយៈពេលខ្លី**

ប្រធានបទផ្ទុះបញ្ឆេះអំពីជម្លោះមាននៅពាសពេញពិភពលោក ក្នុងនោះស្ថានការណ៍គ្រោះថ្នាក់ជាច្រើនអាចដោះស្រាយបានយ៉ាងឆាប់រហ័សនិងដោយសន្តិវិធីតាមរយៈការសិក្សាទៅលើមូលហេតុនិងលទ្ធផលរបស់ស្ថានការណ៍នោះ ។ នៅក្នុងទិដ្ឋភាពបែបនេះ កម្មវិធីនៃ«ការអប់រំអំពីសន្តិភាព»ជាទូទៅចាប់ផ្តើមពីការពិភាក្សានិងបង្ហាញអំពីមូលហេតុនៃជម្លោះឬសង្គ្រាមនិងវិធីដែលអាចទប់ស្កាត់ជម្លោះទាំងនោះបាន ។ នៅក្នុងប្រទេសជាច្រើន ប្រធានបទផ្សេងៗគ្នានៃការអប់រំនេះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ។ នៅក្នុងករណីនេះ ការសិក្សាដែលសង្កត់ធ្ងន់លើការសិក្សាអំពីជម្លោះ ការយល់ដឹងអំពីមូលហេតុនិងលទ្ធផលនៃជម្លោះ និងការមើលទៅលើវិធីដែលអាចប្រើប្រាស់ក្នុងការទប់ស្កាត់ជម្លោះដោយអហិង្សា បានក្លាយទៅជាវិធីសាស្ត្រមួយដ៏មានសារសំខាន់យ៉ាងខ្លាំង ។ កម្មវិធីសិក្សារយៈពេលខ្លីនេះជួនកាលត្រូវបានយកទៅអនុវត្តនៅក្នុងប្រទេសដែលបានជួបប្រទះសង្គ្រាមរួចហើយនិងសង្គមមួយចំនួនដែលប្រឈមមុខនឹងអំពើហិង្សា ។ គោលបំណងចម្បងនៃកម្មវិធីនេះគឺដើម្បីទប់ស្កាត់មិនឲ្យសង្គ្រាម និងកុំឲ្យអំពើហិង្សាកើតឡើងម្តងទៀតនៅក្នុងពេលអនាគត ។

នៅក្នុងប្រទេសជប៉ុន ការអប់រំនេះផ្តោតទៅលើការអប់រំនៃ «ការប្រឆាំងនឹងការប្រើប្រាស់អាវុធនុយក្លេអ៊ែរ» ។ ការណ៍ដែលកុមារជប៉ុនសិក្សាអំពីសង្គ្រាមលោកលើកទីពីរគឺមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ហើយអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺរឿងរ៉ាវនៅខែសីហា ឆ្នាំ១៩៤៥ នៅទីក្រុងហ៊ីរ៉ូស៊ីម៉ានិងណាហ្កាសាគីគ្រាន់តែត្រូវបានបរិយាយដោយជនជាតិជប៉ុនជំនាន់មុនប៉ុណ្ណោះ ។ ជនជាតិជប៉ុនជាច្រើនដែលរួចរស់ជីវិត ធ្លាប់មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការភ្លេចនូវព្រឹត្តិការណ៍និងមូលហេតុនៃព្រឹត្តិការណ៍នេះ ហើយជាពិសេសគឺការវិលត្រឡប់មកម្តងទៀតនៃព្រឹត្តិការណ៍នេះនៅពេលអនាគត ។ ដូច្នេះហើយបានជាការអប់រំនេះនិងសកម្មភាពមួយចំនួនទៀតត្រូវបានបង្កើតឡើងសម្រាប់កុមារជប៉ុនដើម្បីឲ្យកុមារទាំងនេះអាចស្វែងយល់ពីព្រឹត្តិការណ៍នេះដោយពេញលេញ ។

នៅប្រទេសជប៉ុន យុទ្ធសាស្ត្រនៃ«ការអប់រំអំពីសន្តិភាព» គឺផ្តល់ឲ្យសម្រាប់គ្រូបង្រៀននិងជនរងគ្រោះនៃការវាយប្រហារដោយគ្រាប់បែកនុយក្លេអ៊ែរ ប្រាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួនកាលពីព្រឹត្តិការណ៍ខែសីហាឆ្នាំ១៩៤៥ដល់សិស្សានុសិស្ស ។ នៅក្នុងការបង្រៀន កិច្ចការសាលាត្រូវបានរៀបចំឡើងដើម្បីឲ្យសិស្សស្វែងរកប្រភពព័ត៌មានដែលឆ្លើយតបទៅនឹងសំណួរជាច្រើនស្តីអំពីសង្គ្រាម សន្តិភាព និងអាវុធនុយក្លេអ៊ែរ ។ ជាលទ្ធផលចម្លើយទាំងអស់នោះត្រូវបានប្រមូលចងក្រងនិងបោះពុម្ពផ្សាយ

នៅលើក្រដាសបិទតាមជញ្ជាំង និងដាក់បង្ហាញនៅក្នុងការប្រារព្ធពិធីបុណ្យវប្បធម៌ប្រចាំឆ្នាំរបស់សាលា ។ អ្នកអប់រំជនជាតិជប៉ុនជាច្រើនរូបជឿជាក់ថា កម្មវិធីនេះអាចឆ្លុះបញ្ចាំងអំពីគំនិតរបស់សិស្សានុសិស្សជប៉ុន ដែលថាប្រជាជនជប៉ុនមិនមែនគ្រាន់តែជាជនរងគ្រោះទេ ប៉ុន្តែក៏ជាអ្នកវាយប្រហារដែរ ។ ម្យ៉ាងវិញទៀត សិស្សក៏អាចសិក្សាអំពីលទ្ធផលមិនរីកចម្រើននៃសង្គ្រាម ដូច្នេះកុមារទាំងនេះនឹងចៀសវាងមិនឲ្យព្រឹត្តិការណ៍នេះកើតឡើងម្តងទៀត ។ ប្រជាជនជប៉ុនអាចដាក់ប្រវត្តិសាស្ត្រនៃការប្រើអាវុធនុយក្លេអ៊ែរនៅទីក្រុងហ៊ីរ៉ូហ្ស៊ីម៉ាដោយឡែក ហើយបែរមករកការស្វែងរកសន្តិភាពសម្រាប់អនាគតវិញ ។

### ◆ ការអប់រំអំពីសន្តិភាពរយៈពេលវែង

គោលបំណងនៃការអប់រំក្នុងរយៈពេលវែងគឺបង្កើតឲ្យមានទម្រង់នៃសតិសម្បជញ្ញៈរបស់មនុស្សដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការថែរក្សាសន្តិភាពនិងកែប្រែឲ្យមនុស្សមានអហិង្សានៅក្នុងខ្លួន ។ គុណសម្បត្តិចម្បងរបស់ការអប់រំនេះមិនត្រឹមតែអាចជួយដោះស្រាយបញ្ហាដូចនៅក្នុងការអប់រំរយៈពេលខ្លីនោះទេ ថែមទាំងអាចបង្កើនភាពសុចរិតនៅក្នុងខ្លួន យុត្តិធម៌សង្គម ភាពស្មើភាពគ្នាចំពោះពណ៌សម្បុរ ទំនាក់ទំនង ភេទ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ ការអប់រំអំពីសន្តិភាពគឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក៏ដូចជាប្រទេសអភិវឌ្ឍន៍ ក្នុងការកសាងវប្បធម៌នៃសន្តិភាពនៅក្នុងចំណោមប្រជាពលរដ្ឋ ។

ការអប់រំស្តីអំពីសិទ្ធិមនុស្សនៅប្រទេសកាណាដាផ្តោតទៅលើការលើកតម្កើងភាពស្មើគ្នានៃជាតិពន្ធនិងជាតិសាសន៍ ដោយផ្អែកទៅលើការថែរក្សាវប្បធម៌ និរន្តរភាពនៃវប្បធម៌ និងការអភិវឌ្ឍន៍ច្បាប់នៃវប្បធម៌ចម្រុះ ។ គំនិតទាំងស្រុងនៃការអប់រំអំពីសិទ្ធិមនុស្សនេះគឺចង់តម្រង់មនុស្សឲ្យឆ្ពោះទៅរកការយល់ដឹង ការគោរពវប្បធម៌នៃក្រុមជនជាតិភាគតិច និងការចែករំលែកគុណធម៌របស់ខ្លួនជាមួយនឹងក្រុមដែលមានភាសា ពណ៌សម្បុរ និងវប្បធម៌ ដោយឡែកផ្សេងទៀត ។

សកម្មភាពនៅក្នុង "ការអប់រំអំពីសន្តិភាព" គឺមានលក្ខណៈសមស្របទាំងកុមារនិងមនុស្សពេញវ័យ ។ នៅក្នុងចំណុចនេះ វិធីសាស្ត្រពីរនឹងត្រូវបង្ហាញនៅទីនេះ ។ ទីមួយគឺការអប់រំក្នុងប្រព័ន្ធសម្រាប់កុមារ និងមួយទៀតគឺការអប់រំក្រៅប្រព័ន្ធដែលអប់រំតាមរយៈសហគមន៍ អង្គការសាសនា និងប្រព័ន្ធផ្សព្វផ្សាយ ។ ភាគច្រើននៃសកម្មភាពសម្រាប់មនុស្សពេញវ័យគឺមានទំនាក់ទំនងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលដែលដើរតួនាទីជាអ្នកថែរក្សាសន្តិភាព ។

ក្នុងន័យនេះ "ការអប់រំអំពីសន្តិភាព" ចាំបាច់ត្រូវតែជាដំណើរការមួយដ៏មានឥទ្ធិពល មិនថានៅក្នុងថ្នាក់រៀនឬនៅក្នុងសហគមន៍ទេ ។ អ្នកដែលទទូចឲ្យមានការអប់រំនេះមានទំនួលខុសត្រូវក្នុងការបង្ហាញថា ប្រជាជនសាមញ្ញដែលរួមមានកុមារនិងមនុស្សពេញវ័យអាចធ្វើអ្វីម្យ៉ាងដែលមានឥទ្ធិពលទៅលើបញ្ហាដែលបង្កឡើងដោយមនុស្សខ្លួនឯងបាន ។

### ១) ថ្នាក់រៀន

កម្មវិធីអប់រំក្នុងប្រព័ន្ធនេះត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមវិទ្យាល័យនិងសាកលវិទ្យាល័យនានា ជាពិសេសសម្រាប់ថ្នាក់សាកលវិទ្យាល័យដែលសិក្សាអំពីជម្លោះនិងសន្តិភាព ។

បើយោងតាម ដេវីដ ហក ការដាក់បញ្ចូល "ការអប់រំអំពីសន្តិភាព" ទៅក្នុងកម្មវិធីសិក្សាគឺចាំបាច់អាស្រ័យទៅលើអាយុរបស់សិស្សនិងមុខវិជ្ជាដែលមានបង្រៀននៅក្នុងកម្មវិធីសិក្សា ។ ទីមួយ ការអប់រំនេះមានសារសំខាន់ចាំបាច់សម្រាប់ជួយឲ្យសិស្សានុសិស្សអាចបង្កើនសន្តិភាពនៅក្នុងចិត្តនិងគោរពខ្លួនឯងមុននឹងក្រឡេកមើលបញ្ហារបស់អ្នកដទៃ ។ ស្នូលនៃការអប់រំនេះទៀតសោតគឺដើម្បីបញ្ជាក់ឲ្យច្បាស់ថា សិស្សយល់អំពីខ្លួនឯងនិងតម្រូវការផ្ទាល់ខ្លួន និងបង្កើនសភាពនៃការចេះយល់យោគគ្នាជាជាងភាពឆេវឆាវ ។ ការវិវឌ្ឍន៍ជំនាញនៃការគិតដិតដល់ក៏មានសារសំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យដែរដែលសិស្សានុសិស្សអាចលើកសម្តែងមតិជំទាស់និងធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ ការធ្វើដូច្នេះសិស្សានុសិស្សទាំងនេះអាចកំណត់អំពីការឃោសនាដែលលម្អៀងដូចជា ការរើសអើងជាតិសាសន៍ ការរើសអើងភេទ និងយោធានិយម តាមរយៈការផ្សព្វផ្សាយ និងតាមរយៈសៀវភៅសិក្សា ។ លើសពីនេះទៅទៀត សិស្សានុសិស្ស

ចាំបាច់បង្កើនចំណេះដឹង ជំនាញ និងសមត្ថភាព លើការសហការគ្នា ដំណោះស្រាយជម្លោះ និងការយល់ចិត្តគ្នា ។

«ការអប់រំអំពីសន្តិភាព»អាចត្រូវបានបញ្ចូលក្នុងរវាងមេរៀន ឬសកម្មភាពដែលត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីសិក្សារបស់សាលារៀន ។ ការអប់រំអំពីសន្តិភាពគឺកសាងជំនាញរបស់សិស្សឲ្យមានអត្តចរិតសន្តិភាពស្ងប់ស្ងាត់ រួមរស់ជាមួយគ្នាដោយសន្តិភាព និងអភិវឌ្ឍសមត្ថភាពរបស់សិស្សទាំងនេះដើម្បីកសាងសន្តិភាពនៅក្នុងពិភពលោក ។ គោលបំណងជាមូលដ្ឋានក្នុងការផ្តល់ការអប់រំអំពីសន្តិភាពនៅក្នុងសាលារៀនគឺដើម្បីទប់ស្កាត់សិស្សឬនិស្សិតទាំងអស់កុំឲ្យក្លាយទៅជាអ្នកប្រព្រឹត្តអំពើហិង្សា និងដើម្បីលើកទឹកចិត្តឲ្យអ្នកទាំងនេះប្រកាន់ខ្ជាប់នូវតម្លៃនៃសីលធម៌សង្គមនៅក្នុងគំនិតរបស់ខ្លួន ។ មានអង្គការក្រៅរដ្ឋាភិបាលនិងប្រទេសខ្លះដែលបានពង្រីកមុខវិជ្ជាសិក្សា កម្មវិធីសិក្សា និងសកម្មភាពផ្សេងៗទៀតនៅសាលារៀនដូចជា «ការអប់រំអំពីតម្លៃ»នៅប្រទេសម៉ាឡេស៊ីនិងហ្វីលីពីន «ការអប់រំអំពីភាពជាពលរដ្ឋ»នៅសហរដ្ឋអាមេរិក «ការអប់រំដើម្បីការយោគយល់គ្នាទៅវិញទៅមក»នៅអៀរឡង់និង «ការអប់រំអំពីការអភិវឌ្ឍ»ដោយអង្គការយូនីសេហ្វ ។

ជាក់ស្តែង «សាលាម៉ុងតេហ្សូរី» ដែលមានមូលដ្ឋាននៅក្នុងទីក្រុងឡាក់កាណូវនៃប្រទេសឥណ្ឌា ជាសាលារៀនដ៏ល្បីមួយដែលបានបញ្ចូលមុខវិជ្ជា «ការអប់រំអំពីសន្តិភាព»ទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន ។ ចំណាត់ការរបស់សាលាម៉ុងតេហ្សូរីបានលើកកម្ពស់ដល់សន្តិភាពនិងភាពសុខដុមរមនានៅក្នុងចំណោមនិស្សិតទាំងឡាយតាមរយៈកម្មវិធីសិក្សានិងសកម្មភាពសន្តិភាពផ្សេងៗទៀតដែលផ្តោតលើបញ្ហាផ្សេងៗដូចជាការសិក្សាអំពីជីវិត ច្បាប់ និងរចនាសម្ព័ន្ធរបស់សកលលោក ។ គោលបំណងគឺថាចំណេះដឹងអំពីសន្តិភាពនឹងសាយភាយទៅជាសកម្មភាពផ្សេងៗទៀតនៅក្នុងសាលារៀន ។ ឧទាហរណ៍ៈ នៅពេលសិស្សទាំងនោះចាប់ផ្តើមសរសេរបទអត្ថាធិប្បាយណាមួយ ឬក៏ចូលរួមនៅក្នុងពិធីផ្សេងៗដូចជាសិល្បៈ តន្ត្រី ឬល្ខោនរូបភាព អ្នកទាំងនោះគិតអំពីសាមគ្គីភាព សន្តិភាព និងការគោរពជាជំហានទីមួយ ។

### ក) សហគមន៍

ការអប់រំអំពីសន្តិភាពនៅក្នុងសហគមន៍គឺបង្រៀនអំពីបុព្វហេតុនិងឥទ្ធិពលនៃសង្គ្រាម សន្តិភាព និងជម្លោះផ្សេងៗ ។ តាមរយៈការអប់រំអំពីសន្តិភាព សហគមន៍អាចចាប់ផ្តើមដោយការប្រមូលមនុស្សឲ្យជួបជុំគ្នានិងណែនាំឲ្យស្គាល់គ្នាទៅវិញទៅមកក្នុងគោលបំណងសំខាន់ដើម្បីបង្កើនការទុកចិត្ត និងបង្កើតទំនាក់ទំនងនឹងគ្នាទៅវិញទៅមក ។ កម្មវិធីអប់រំស្តីអំពីសន្តិភាពឆ្លើយតបទៅនឹងផលប្រយោជន៍របស់ប្រជាជនតាមមធ្យោបាយខុសៗគ្នាអាស្រ័យទៅលើប្រភេទផ្សេងៗនៃប្រពៃណីវប្បធម៌ និងបញ្ហារបស់សហគមន៍ផ្ទាល់ ។ ផលប្រយោជន៍សំខាន់បំផុតរបស់កម្មវិធីអប់រំអំពីសន្តិភាពគឺដើម្បីពង្រីកទំនាក់ទំនងរវាងមនុស្ស និងដើម្បីពង្រីកការយោគយល់និងក្តីមេត្តាចំពោះគ្នាទៅវិញទៅមក ។

ជាក់ស្តែង លីបង់ជាប្រទេសមួយដែលត្រូវបែកបាក់ដោយជម្លោះរវាងអ្នកកាន់សាសនាគ្រិស្តនិងអ្នកកាន់សាសនាអ៊ីស្លាម ។ ការពង្រីកការអប់រំអំពីសន្តិភាពមានតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសបែកបាក់មួយនេះ ។ «ជំរំអភិវឌ្ឍន៍យុវជនស្ម័គ្រចិត្ត» នៅក្នុងប្រទេសលីបង់ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៩ ដែលបានប្រមូលយុវជនលីបង់ប្រមាណជា១ពាន់នាក់ពីទូទាំងប្រទេស ។ យុវជនទាំងនេះត្រូវបានហ្វឹកហ្វឺនអំពីទស្សនៈសន្តិភាព និងអំពីរបៀបដែលត្រូវថែរក្សាកុមារលីបង់ពីអាយុ៦ឆ្នាំដល់១៣ឆ្នាំ ។ បន្ទាប់ពីការហ្វឹកហ្វឺន យុវជនទាំងនេះនឹងបន្តធ្វើការនៅក្នុងជំរំជាងមួយពាន់ទៀតដោយមានការចូលរួមពីសំណាក់កុមារជនជាតិលីបង់ដែលមានសាសនាខុសៗគ្នានិងមកពីកន្លែងផ្សេងៗគ្នានៃប្រទេស ។ កម្មវិធីនេះបានអភិវឌ្ឍទស្សនៈវិជ្ជមានចំពោះខ្លួនឯង សមត្ថភាពនៃការសហប្រតិបត្តិការ សាមគ្គីភាព ការចូលរួមនិងការសម្តែងមតិ គំនិតយុត្តិធម៌ និងសមភាពនៅក្នុងចំណោមយុវជនលីបង់ ។

### ឃ) អង្គការសាសនា

ក្រុមអប់រំអំពីសន្តិភាពនិងមន្ត្រីតំបន់បានផ្តល់ការគាំទ្រទៅដល់ព្រះវិហារគ្រិស្តសាសនានិងអង្គការសាសនាផ្សេងៗទៀត ។ នៅពេលដែលអ្នកទាំងនេះបានផ្តល់សិក្ខាសាលាទៅឲ្យគ្រូបង្រៀននៅតាមព្រះវិហារ ចំណេះដឹងស្តីពីការអប់រំអំពីសន្តិភាពអាចត្រូវបានផ្ទេរបន្តទៅឲ្យមនុស្សផ្សេងទៀតតាមរយៈការបង្រៀន

នៅថ្ងៃអាទិត្យនៅតាមសហគមន៍របស់អ្នកទាំងនោះ ។

ទីក្រុងខូវិនទ្រីរបស់ប្រទេសអង់គ្លេសជាតំបន់មួយដែលមានប្រជាជនចម្រុះជាតិសាសន៍មកពីតំបន់ផ្សេងៗនៃពិភពលោក ។ «ធម្មយាត្រាដើម្បីសន្តិភាពនៅខូវិនទ្រី» ដែលជាសកម្មភាពមួយក្នុងចំណោមសកម្មភាពល្អៗមួយចំនួនក្នុងការផ្តល់ការអប់រំអំពីសន្តិភាពតាមរយៈស្ថាប័នសាសនាផ្សេងៗ ត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំដើម្បីប្រមូលក្រុមដែលធ្វើការងារដើម្បីសន្តិភាពនិងភាពសុខដុមរមនាឲ្យបានជួបជុំគ្នានៅក្នុងទីក្រុងនេះ ។ កាលពីឆ្នាំមុនៗ ធម្មយាត្រានេះត្រូវបានចូលរួមដោយចៅហ្វាយក្រុងខូវិនទ្រី តំណាងស្ត្រីហ្គូតឌីវ៉ា មេដឹកនាំសាសនា និងមនុស្សជាច្រើននាក់ទៀតមកពីក្រុមសាសនាផ្សេងៗនៅក្នុងទីក្រុងខូវិនទ្រី ។ ធម្មយាត្រាដើម្បីសន្តិភាពនេះចេញដំណើរពី «ព្រះវិហារនៃសាមគ្គីភាព» ហើយបន្តដើរជុំវិញទីក្រុងទៅទស្សនាព្រះវិហារគ្រិស្តសាសនាព្រះវិហារសាសនាឥស្លាម ព្រះវិហារសាសនាហិណ្ឌូ និងព្រះវិហារសាសនាផ្សេងៗទៀត ។ មានការណែនាំអំពីសាសនារបស់ខ្លួននៅគ្រប់ព្រះវិហារសាសនាទាំងអស់ ។ ព្រឹត្តិការណ៍នេះបានបង្កលក្ខខណ្ឌឲ្យមានទំនាក់ទំនងជិតស្និទ្ធ និងបានជួយកែលម្អអត្តចរិតនៃការប្រព្រឹត្តរបស់មនុស្សចំពោះអ្នកដទៃតាមរយៈការបង្កើនសេចក្តីទុកចិត្ត និងការមិនរើសអើង ។

### ង) ប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយធំៗបំផុតក្នុងការផ្សព្វផ្សាយមនោគមវិជ្ជាពិសេសណាមួយទៅក្នុងសង្គម និងជាប្រភពធនធាននៃព័ត៌មានសំខាន់បំផុតនៅក្នុងពិភពលោកបច្ចុប្បន្ននេះ ។ តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយអាចមានន័យវិជ្ជមាននិងអវិជ្ជមាន ។ នៅក្នុងសង្គមប្រជាធិបតេយ្យ ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីជាធនធាននៃការផ្សព្វផ្សាយដើម្បីលើកទឹកចិត្តមនុស្សឲ្យចូលរួមក្នុងបរិបទនៃលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការផ្លាស់ប្តូរសង្គម ។

ការអប់រំអំពីសន្តិភាពត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។ ជាក់ស្តែង យើងឃើញមានកម្មវិធីបង្រៀនតាមវិទ្យុនិងទូរទស្សន៍អំពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស សន្តិភាព និងការដោះស្រាយជម្លោះ ។ ទាំងការស្រាវជ្រាវរបស់អង្គការក្រៅរដ្ឋាភិបាលនិងបុគ្គលស្តីពីការអប់រំអំពីសន្តិភាពត្រូវបានចុះផ្សាយនៅក្នុងកាសែត ទស្សនាវដ្តី គេហទំព័រ និងសៀវភៅដែលអាចត្រូវបានផ្សព្វផ្សាយនៅទូទាំងពិភពលោក ។

ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកបានបង្កើតកម្មវិធីមួយដែលមានឈ្មោះថា «វេទិកាបង្រៀនភាសាអង់គ្លេសតាមប្រព័ន្ធអ៊ីនធឺណែត» ដើម្បីបង្រៀនរបៀបប្រើប្រាស់ភាសាអង់គ្លេសតាមប្រព័ន្ធអ៊ីនធឺណែត ។ កម្មវិធីនេះមិនត្រឹមតែដើម្បីបង្រៀនភាសាអង់គ្លេសនោះទេ ថែមទាំងផ្តល់ការអប់រំអំពីសន្តិភាពនិងដើម្បីអភិវឌ្ឍអត្តចរិតវិជ្ជមានដែរ ។ តាមរយៈការផ្តល់ដល់សិស្សានុសិស្សនិងនិស្សិតនូវប្រធានបទទាក់ទងទៅនឹងការយល់ដឹងអំពីវប្បធម៌និងសន្តិភាព ជីវភាពរស់នៅប្រកបដោយសន្តិភាពត្រូវបានបង្កើតនិងលើកកម្ពស់នៅក្នុងទម្រង់ចម្រុះវប្បធម៌ ។ ជាគោលការណ៍ ការផ្តល់សម្ភារសិក្សាដល់សិស្សបានផ្តល់ឱកាសដល់អ្នកទាំងនោះក្នុងការពង្រឹងជំនាញក្នុងការគិតគូរឲ្យបានហ្មត់ចត់ និងក្នុងការដោះស្រាយបញ្ហា ហើយជំនាញនេះបានធ្វើឲ្យសិស្សានុសិស្សទាំងនោះមានភាពទន់ភ្លន់និងមានវិជ្ជាជីវៈច្រើនជាងមុន ។ **(នៅមានត)**

**គីម កែវកន្និដ្ឋា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជានិងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

**៤) ហាងកាហ្វេ** ៖ មជ្ឈមណ្ឌលយើងខ្ញុំមានហាងកាហ្វេសម្រាប់បម្រើសេវាភេសជ្ជៈនិងចំណីអាហារជូនលោកអ្នក ។

ភាពយន្តឯកសារអំពីខ្មែរក្រហម មានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។


វគ្គបណ្តុះបណ្តាលច្បាប់អន្តរជាតិនៅការិយាល័យពត៌មានសាធារណៈ

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# យុត្តិធម៌សម្រាប់ជនរងគ្រោះ

ចាប់ផ្តើមដោយការបណ្តេញប្រជាជនទាំងអស់ចេញពីទីក្រុងនានា ហើយបំពេញមកវិញនូវរណ្តៅកប់សាកសពយ៉ាងច្រើននៅរាយប៉ាយពាសពេញផ្ទៃប្រទេស ទីបំផុតរបបវាលពិឃាដមួយបានសម្លាប់ប្រជាជនខ្លួនឯងអស់មួយលានប្រាំពីរសែននាក់តែក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃប៉ុណ្ណោះ ។

ប្រជាជនកម្ពុជាគ្រប់ៗរូបដែលរួចផុតពីការស្លាប់ ហើយដែលបច្ចុប្បន្នមានអាយុចាប់ពីសែសិបឆ្នាំឡើងទៅ សុទ្ធតែមានរឿងនិទានដ៏សែនរំជួលចិត្តផ្ទាល់ខ្លួនម្នាក់ៗ ។ គឺជារឿងនិទានដែលរំពុកឡើងវិញអំពីរឿងរ៉ាវពិតក្នុងឆាកជីវិតរបស់ខ្លួនដែលបានជួបប្រទះនូវទុក្ខវេទនា ការនិរាសព្រាត់ប្រាស់ ការបែកបាក់គ្រួសារ ។ រឿងនិទានដែលរៀបរាប់អំពីការបង្ខំឲ្យធ្វើពលកម្មដ៏សែនធ្ងន់ធ្ងរ រឿងនិទានដែលរៀបរាប់អំពីការអត់ឃ្លានហួសនិស្ស័យ រឿងនិទានដែលរៀបរាប់អំពីទារុណកម្មលើរូបរាងកាយនិងផ្លូវចិត្តដែលកម្មាភិបាលខ្មែរក្រហមនៅតាមមូលដ្ឋានបានប្រព្រឹត្តិមកលើខ្លួនផ្ទាល់និងចំពោះសាច់ញាតិបងប្អូនឪពុកម្តាយ ។

រឿងរ៉ាវពិតដែលពោរពេញដោយការរំជួលចិត្តមិនអាចទប់ទឹកភ្នែកបានទាំងអស់នោះបានចាប់ផ្តើមឡើងកាលពីសាមសិបឆ្នាំមុន ហើយបានបន្តឲ្យមានរបួសស្នាមដល់អារម្មណ៍និងផ្លូវចិត្តជនរងគ្រោះទាំងអស់ក្នុងរបបខ្មែរក្រហមរហូតមកដល់សព្វថ្ងៃនេះ ។ វិធីតែមួយគត់ក្នុងការព្យាបាលស្នាមរបួសផ្លូវចិត្តទាំងអស់នោះ គឺគ្មានអ្វីក្រៅពីការផ្តល់ឲ្យជនរងគ្រោះគ្រប់ៗរូបនូវយុត្តិធម៌ដ៏ថ្លៃថ្នូរមួយ ។ គឺជាយុត្តិធម៌ដែលមិនមែនជាការសងសឹក ។

ពេលវេលាបីទសវត្សរ៍ដែលបានកន្លងផុតទៅបានធ្វើឲ្យវ័យអ្នកដែលសល់ពីស្លាប់និងអ្នកទទួលខុសត្រូវក្នុងការស្លាប់កាន់តែចាស់ជរាទៅៗ ។ អ្នកទទួលខុសត្រូវខ្លះដូចជា ប៉ុល ពត, សុន សេន និង កែ ពក ជាដើម បានស្លាប់ទៅបាត់ទទេដោយគ្មានបានពន្យល់បំភ្លឺដល់ជនរងគ្រោះបានស្តាប់ឮដោយផ្ទាល់ពីមូលហេតុដែលនាំឲ្យក្រុមខ្លួនបង្កើតឲ្យមានរបបវាលពិឃាដ ។ ទាំង ប៉ុល ពត, សុន សេន និង កែ ពក សុទ្ធតែមិនបានដឹងថា អតីតសមមិត្តដ៏ជិតស្និទ្ធរបស់ខ្លួនដែលមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃនេះកំពុងតែមិនហ៊ានប្រឈមមុខនឹងការពិតនូវទង្វើរបស់ខ្លួនពីអតីតកាលទេ ហើយពេញចិត្តនឹងភាពកំសាកមិនទទួលខុសត្រូវអ្វីទាំងអស់ ។ ចំណែកឯជនរងគ្រោះទាំងអស់ (ទាំងអ្នកស្លាប់និងអ្នកនៅរស់) ក៏មិនទាន់ទទួលបាននូវយុត្តិធម៌ដែលបានមកពីការកាត់ទោសដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែរ ។

តើដល់ពេលណាទៅទើបយុត្តិធម៌ត្រូវបានផ្តល់ឲ្យជនរងគ្រោះគ្រប់ៗរូបក្នុងរបបវាលពិឃាដ?

សូមឲ្យតុលាការកាត់ក្តីខ្មែរក្រហមកើតមានឡើងឲ្យបានឆាប់ ដើម្បីបិទទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់ខ្មៅងងឹតនេះសំដៅព្យាបាលស្នាមរបួសផ្លូវចិត្តដល់ជនរងគ្រោះទាំងអស់និងក្នុងន័យផ្សះផ្សាជាតិពិតប្រាកដ ។ នេះគឺជាការអំពាវនាវដ៏ទទូចក្នុងនាមជាជនរងគ្រោះម្នាក់ក្នុងរបបខ្មែរក្រហម ។ **ម៉េង រស្មី**

## សេចក្តីប្រកាសរកប្អូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ អាន គៅ ភេទស្រី អាយុ៥៨ឆ្នាំ រស់នៅភូមិព្រៃម៉ីយ៍ ឃុំផាន់ញីម (អតីតភូមិដើម ឃុំនីរពេជ្រ) ស្រុកប្រាសាទបាល័ង្គ (កំពង់ស្វាយ) ខេត្តកំពង់ធំ ។

សូមសួររកប្អូនប្រុសឈ្មោះ អាន កួយ និង អាន គុយ ដែលបានចេញពីផ្ទះទៅធ្វើកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ កួយ បានមកលេងផ្ទះម្តងរយៈពេល៤-៥ថ្ងៃ រួចក្រោយមកក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។

បើសាមីខ្លួនបានឮឬបងប្អូនបានស្គាល់ឈ្មោះខាងលើ សូមផ្តល់ពត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើតាមប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# ចងចាំការជម្លៀសរំលំទីក្រុងភ្នំពេញនៅក្នុងរបបខ្មែរក្រហម

*(សេចក្តីថ្លែងការណ៍នេះចេញផ្សាយនៅទីក្រុងវ៉ាស៊ីងតោនឌីស៊ី សហរដ្ឋអាមេរិក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ ដោយលោក Adam Ereli អ្នកនាំពាក្យរដ្ឋក្រសួងការបរទេសសហរដ្ឋអាមេរិក)*

សប្តាហ៍នេះគឺជាខួបទី៣០ នៃការកាន់កាប់អំណាចរបស់ពួកខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។ គេបានប៉ាន់ប្រមាណថាមានប្រជាជនកម្ពុជាប្រមាណដល់៣លាននាក់បានស្លាប់នៅក្នុងរបបវាលពិឃាដនេះ ។ សហរដ្ឋអាមេរិកចូលរួមជាមួយប្រជាជនកម្ពុជារាប់លាននាក់ ជនជាតិអាមេរិកដើមកំណើតខ្មែរ និងអ្នកដទៃផ្សេងទៀត ដើម្បីរំឭកនិងចងចាំដល់ជនរងគ្រោះនៅក្នុងរបបដ៏ឃោរឃៅនិងសោកសៅនេះ ។

សហរដ្ឋអាមេរិកជឿជាក់ថាត្រូវតែមានការទទួលខុសត្រូវចំពោះអំពើដ៏សាហាវយង់ឃ្នងទាំងនេះ ហើយសហរដ្ឋអាមេរិកស្វាគមន៍កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សម្រាប់សហរដ្ឋអាមេរិកក្នុងការចូលរួមចំណែកនៅក្នុងដំណើរការនេះដូចដែលច្បាប់សហរដ្ឋអាមេរិកបានចែង យើងជឿជាក់ថាតុលាការសម្រាប់កាត់ទោសខ្មែរក្រហមឆ្លើយតបតាមស្តង់ដាយុត្តិធម៌ដែលទទួលស្គាល់ដោយអន្តរជាតិ ។ នៅពេលដែលការបង្កើតតុលាការនេះកំពុងដំណើរការទៅមុខ យើងនឹងចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិនិងប្រទេសផ្សេងៗទៀតដែលមានការចាប់អារម្មណ៍ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ ។

យើងនឹងបន្តផ្តោតការយកចិត្តទុកដាក់ទៅលើសារសំខាន់និងភាពចាំបាច់ចំពោះប្រព័ន្ធតុលាការឯករាជ្យនៅក្នុងប្រទេសកម្ពុជា ។ មានតែការទទួលយកការគោរពច្បាប់និងការកើតមានឡើងនូវស្ថាប័នផ្សេងៗប្រកបដោយប្រសិទ្ធភាពដើម្បីរាំងខ្ទប់ និរទណ្ឌភាព (ភាពគ្មានទោស) ទើបរបបគ្រប់គ្រងអំណាចនានាដូចជារបបខ្មែរក្រហមដែលត្រូវបានកត់ត្រានៅក្នុងប្រវត្តិសាស្ត្រដ៏សោកសៅនឹងមិនអាចកើតមានជាថ្មីម្តងទៀត ។


អ្នកទោសនៅមន្ទីរស-២១


អ្នកទោសនៅមន្ទីរស-២១


អ្នកទោសនៅមន្ទីរស-២១

# ជីវិតក្នុងភាពនឹងថ្កល់

## ណោត ប៊ុនធី
## ប្រធានក្រុមកងពល១៧០

*(បទសម្ភាសន៍ជាមួយ ណោត ផល្លី អាយុ៤៦ឆ្នាំ ត្រូវជាប្អូនប្រុស នៅស្រុកអូររាំងឪ ខេត្តកំពង់ចាម)*


ណោត ប៊ុនធី និង ណោត ផល្លី ថតក្នុងឆ្នាំ១៩៧២

បងប៊ុនធី មានរូបរាងស្អាតគួរស្រលាញ់ណាស់ ។ ពេលគាត់នៅភូមិ អ្នកភូមិគោរពរាប់អានគាត់ណាស់ តែខ្ញុំយល់ថាមួយជីវិតរបស់គាត់ គាត់មិនដែលសប្បាយចិត្តម្តងណាទេ ។

បងប៊ុនធី ចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧០ បើគិតទៅប្រហែលជាគាត់អាយុ១៩ឆ្នាំ ។ គាត់បានឮសម្តេចឪប្រកាសតាមវិទ្យុឲ្យប្រជាជនចូលព្រៃតស៊ូ ដូច្នេះទើបបងប្រុសខ្ញុំនិងប្រជាជន៧០នាក់ទៀតចាកចេញពីភូមិ ។ កាលណោះខ្ញុំនៅក្មេងទើបមិនបានចូលរួមនឹងគេ ។ ដល់ឆ្នាំ១៩៧៤ទើបខ្ញុំបានទៅ ។

បងប៊ុនធី ត្រូវបញ្ជូនទៅសមរភូមិច្រើនណាស់ ដូចជានៅព្រៃវែង ស្វាយរៀង និងកំពង់ឆ្នាំង ។ ក្រោយមកគាត់នៅក្នុងកងពល១០៧នៃភូមិភាគបូព៌ា ។ រវាងឆ្នាំ១៩៧២-៧៥ គាត់បានផ្ញើសំបុត្រមកផ្ទះរាល់ៗឆ្នាំហើយគាត់មកលេងផ្ទះរៀងរាល់ពីរបីខែម្តង ។ ពេលគាត់មកលេងផ្ទះ គាត់ស្លៀកតែឯកសណ្ឋានកងទ័ពប៉ុណ្ណោះ ។

បងប៊ុនធី ត្រូវរបួសលើកដំបូងនៅពេលគាត់ប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅខេត្តព្រៃវែង ។ កាលណោះប្រហែលមួយខែក្រោយរបបលន់ណុលដួលរលំ ។ គាត់របួសជើង ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យ ៣-២ ។

ពេលគាត់សម្រាកនៅមន្ទីរពេទ្យ គាត់សរសេរប្រវត្តិរូបទុកឲ្យ បងសៀង ជានារីដែលគាត់ចង់រៀបការជាមួយ ។ កាលណោះទាំងស្រីទាំងប្រុសត្រូវតែសរសេរប្រវត្តិរូបរបស់ខ្លួន ។ ប្រុសៗធ្វើកងទ័ព ប៉ុន្តែនារីមិនដឹងថាខាងប្រុសធ្វើអ្វីទេ ដូច្នេះទើបខាងប្រុសផ្ញើប្រវត្តិរូបឲ្យខាងស្រី ។ ធ្វើដូច្នេះដើម្បីឲ្យខាងស្រីដឹងអំពីតួនាទីរបស់ខាងប្រុស ។

នៅឆ្នាំ១៩៧៨ បងប៊ុនធី បានផ្ញើសំបុត្រមួយឲ្យខ្ញុំតាមរយៈមិត្តកក្តិម្នាក់នៅក្នុងកងជាមួយខ្ញុំ ។ ក្នុងសំបុត្រនោះសរសេរថាគាត់ត្រូវរបួសស្នាក់នៅពេទ្យ១៧មេសាទីក្រុងភ្នំពេញ ។ កន្លែងនោះនៅក្បែរកងដឹកជញ្ជូនរបស់ខ្ញុំ ។ ខ្ញុំបានសុំការអនុញ្ញាតពីប្រធានកងវរសេនាធំទៅជួប បងប៊ុនធី តែដល់ពេលចូលដល់បន្ទប់របស់គាត់ ខ្ញុំបែរជាចំណាំគាត់មិនបាន ។ ខ្ញុំមិនដែលឃើញគាត់ទុកសក់វែងដូចពេលនោះទេ ។ ថ្ពាល់គាត់ត្រូវរបួសយ៉ាងដំណំ ។ ចូលដល់ក្នុងបន្ទប់ភ្លាម ខ្ញុំហៅគាត់ "បង! បង!" គាត់ខំប្រឹងក្រោកឈរ ។ មុខគាត់ហើមធំ ខ្ញុំអាណិតគាត់ណាស់ ។ ខ្ញុំយំអស់មួយសន្ទុះទើបយើងបានជជែកគ្នាប្រហែលមួយឬពីរម៉ោងដែរ ។

បងប៊ុនធី ប្រាប់ខ្ញុំថាគាត់ចង់ឈប់ធ្វើកងទ័ពរួចត្រឡប់

មកផ្ទះរៀបការ ។ គាត់ថាគាត់នឹក បងសៀង ។ ឪពុកម្តាយបងសៀង ក៏បានយល់ព្រមពីរឿងរៀបការរបស់គាត់ទាំងពីរនាក់ដែរ ។ ខ្ញុំថា «បងត្រូវរបួសអីចឹងបងអាចសុំអង្គការឲ្យដាក់បងនៅកងពិការដើម្បីគេចពីការច្បាំងគ្នាក្នុងសមរភូមិ ។ បើបងតស៊ូប្រយុទ្ធនៅសមរភូមិមុខ ខ្ញុំខ្លាចតែបងស្លាប់ទេ» ។ បងប៊ុនធី និយាយថា គាត់នឹងឈប់ពីជួរកងទ័ព ។

ពេទ្យដាក់សេរ៉ូមឲ្យគាត់ ដូច្នេះខ្ញុំជួយកាន់ថ្នោកសេរ៉ូមឲ្យគាត់ពេលគាត់ទៅបត់ជើង ។ មកដល់បន្ទប់សឹងតែមិនទាន់គាត់ដួលក្រឹប ដោយសារគាត់ខ្សោយពេក ។ ខ្ញុំលើកគាត់ឡើងទ្រគាត់ពីក្រោយ រួចស្រែកហៅពេទ្យ ។ ពេទ្យមកដល់ចាក់ថ្នាំឲ្យគាត់លុះគាត់ដឹងខ្លួនគាត់ប្រាប់ថា គាត់ចង់ទៅដេកវិញប៉ុន្តែខ្ញុំចេះតែរំខានគាត់ ។ ខ្ញុំឆ្លើយថា បើខ្ញុំមិនជួយបងប្រហែលជាបងទង្គិចក្បាលពេលដួលនោះហើយ ។

ពេលអង្គការយកគាត់ចេញពីពេទ្យ គាត់សុំចូលកងពិការ ។ គាត់និយាយលែងកើត ទើបខ្ញុំប្រាប់គាត់ឲ្យធ្វើពុតជាមនុស្សថ្លង់ ។ ប៉ុន្តែ បងប៊ុនធី ប្រាប់ខ្ញុំថាគាត់ត្រូវអង្គការបញ្ជូនទៅខេត្តកំពង់ឆ្នាំង ហើយប្រធានកងពលឈ្មោះ ឈូក សៅ ក៏ត្រូវចាប់ខ្លួនបញ្ជូនទៅទីនោះដែរ ។ ខ្មែរក្រហមប្រាប់គាត់ថា ម្តងនេះអង្គការមិនមែនបញ្ជូនឲ្យទៅច្បាំងទេ គឺទៅធ្វើព្រលានយន្តហោះ ។ ខ្មែរក្រហមមិនទុកចិត្តអ្នកដែលធ្លាប់ធ្វើការជាមួយ ឈូក សៅ ។ ឃើញគាត់តែម្តងហ្នឹង ខ្ញុំបាត់គាត់រហូត ។

ពេលវៀតណាមកាន់កាប់ភ្នំពេញនៅឆ្នាំ១៩៧៩ ខ្ញុំរត់ទៅជំរំតាមព្រំដែនថៃ ។ ទៅដល់សំឡូត ខ្ញុំខំដើររកគាត់ដែរ ព្រោះកម្មាភិបាលខ្មែរក្រហមនៅភ្នំពេញបានរត់ភៀសខ្លួនទៅទីនោះច្រើនណាស់ ។ ខ្ញុំរកគាត់មិនឃើញទើបគិតថាគាត់ស្លាប់ហើយ ។ ដំបូងខ្ញុំគិតថា ប្រហែលជាគាត់ស្លាប់ពេលដែលរត់ចេញពីភ្នំពេញ ។ ពេលលោកស្រី (អ្នកស្រាវជ្រាវរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា) មកដល់ទើបខ្ញុំដឹងថា បងប៊ុនធី ស្លាប់នៅគុកទួលស្លែង ។

គ្រាន់តែឃើញខ្ញុំត្រឡប់មកផ្ទះវិញ ម្តាយខ្ញុំយំពេលឃើញខ្ញុំស្គមខ្វាំងពេកខ្យល់បក់រលំ ។ អ្នកភូមិជាច្រើននាក់នាំគ្នាមកមើលខ្ញុំ ទើបគ្រែខ្ញុំបាក់អស់ ។

សៀង ដែលបងប្រុសខ្ញុំចង់រៀបការជាមួយឥឡូវនេះគឺជាប្រពន្ធរបស់ខ្ញុំ ។ បងប្រុសខ្ញុំបាត់ខ្លួនយូរណាស់ ហើយនាងរង់ចាំបងខ្ញុំរហូតតាំងពីឆ្នាំ១៩៧៨ដល់១៩៨០ ។ ក្រោយមកឪពុកម្តាយខ្ញុំសម្រេចឲ្យខ្ញុំរៀបការជាមួយនាង ។

បងប៊ុនធី ធ្លាប់បានផ្ញើសំបុត្រមកផ្ទះនៅខែមីនា ឆ្នាំ១៩៧៨ម្តងដែរ គឺមុនពេលខ្ញុំទៅមើលគាត់នៅពេទ្យបន្តិច ។ គាត់ថាគាត់ត្រូវរបួសកំពុងត្រឡប់មកផ្ទះ ។ យូរហើយខ្ញុំដែលមិនបានយកសំបុត្រនោះមកមើល ម្តងនេះខ្ញុំឃើញមានកណ្តៀរកាត់ នេះមានន័យថារឿងរបស់គាត់បានចប់ហើយ ។◆◆◆

# យ៉ាន់ យឿន ហៅ យន
# យុទ្ធជនកងពល៣១០

*(បទសម្ភាសន៍ជាមួយ យ៉ាន់ វុត្ថា អាយុ៤៤ឆ្នាំ ត្រូវជាប្អូនប្រុស នៅស្រុកចម្ការលើ ខេត្តកំពង់ចាម)*

បងយ៉ាន ត្រូវគេកេណ្ឌធ្វើទាហានពេលគាត់រៀននៅវត្តអំឡុងឆ្នាំ១៩៧២ ។ កាលណោះ មានសុទ្ធតែទាហានខ្មែរក្រហមជាច្រើននាក់នៅទីនោះ ហើយគាត់ក៏បានស្ម័គ្រចិត្តដែរ ។ ពុកម៉ែព្រមឲ្យ បងយ៉ាន ទៅព្រោះគាត់គ្រាំទ្រខាងសម្តេចនិងចង់ជួយស្រោចស្រង់ប្រទេសជាតិ ។

បងយ៉ាន បានមកលេងយើងពីរបីថ្ងៃដែរនៅឆ្នាំ១៩៧២ គឺមុនពេល បងយឹម ត្រឡប់មកផ្ទះវិញ ។ បងយឹម ជាខ្មែរក្រហមម្នាក់ដែរ គាត់ពិការដោយសារច្បាំងគ្នានៅកំពង់ចាម ។ ខ្ញុំមិនបានដឹងអ្វីច្រើនអំពីដំណើរមកលេងរបស់គាត់ទេ ព្រោះកាលណោះខ្ញុំនៅតូចមិនចាប់អារម្មណ៍ដឹងពីរឿងមនុស្សចាស់ ។

ប្រហែលឆ្នាំ៧៦-៧៧ ឪពុកខ្ញុំបានជួប បងយ៉ាន ។ ឪពុកខ្ញុំនៅក្រសួងឃោសនាការ ។ គាត់បានចុះទៅមើលកម្មករនៅកំពង់សោម ។ បងយ៉ាន និងពុក ជជែកគ្នាបានសន្ទុះតូចដែរ ។ ក្រោយពេលឪពុកខ្ញុំវិលមកផ្ទះ ខ្មែរក្រហមបានចោទគាត់ថាជាជនក្បត់ ។ ខ្ញុំព្យាយាមទៅមើលពុកដែរតែមានមនុស្សប្រាប់ខ្ញុំថាគាត់ត្រូវបណ្តេញចេញពីការងារហើយ ។ ខ្មែរក្រហមបានសម្លាប់គាត់នៅពាក់កណ្តាលឆ្នាំ១៩៧៧ តែខ្ញុំមិនដឹងថានៅកន្លែងណាទេ ។

ក្រោយនេះបន្តិចអង្គការបញ្ជូនម្តាយខ្ញុំទៅសហករណ៍មួយ



យន ថតប្រហែលក្នុងឆ្នាំ១៩៧២

ហើយសម្លាប់គាត់ចោលនៅទីនោះតែម្តង ។ មានមនុស្សប្រាប់ខ្ញុំថា ម្តាយខ្ញុំត្រូវអង្គការសម្លាប់នៅចម្ការអណ្តូង ខេត្តកំពង់ចាម ។ ខ្មែរក្រហមចោទថាគាត់ជាអាមេរិកកាំងនិងយួន ។ អង្គការថែមទាំងបានសម្លាប់ប្អូនប្រុសខ្ញុំពីរនាក់និងប្អូនស្រីអាយុ៧ឆ្នាំម្នាក់ទៀតក្នុងពេលតែមួយជាមួយម្តាយខ្ញុំ ។ ក្រៅពីនោះ បងប្រុសខ្ញុំបីនាក់ទៀតត្រូវអង្គការយកទៅសម្លាប់ចោលពេលដោយឡែកៗពីគ្នា ។

ខ្មែរក្រហមមានពាក្យមួយឃ្លាថា "ជីកស្មៅត្រូវជីកទាំងឫស" មានន័យថាចាំបាច់ត្រូវតែសម្លាប់គ្រួសារទាំងមូល ។ យើងអាចនៅរស់រានបានប្រសិនបើខ្មែរក្រហមមិនតាមដានប្រវត្តិរូបរបស់យើង ។ បើអង្គការសើរើឃើញថាបានសម្លាប់ឪពុកម្តាយយើងហើយ យើងជាកូនមុខជាត្រូវគេយកទៅសម្លាប់ចោលដែរជាមិនខាន ។ ខ្ញុំគិតថាខ្មែរក្រហមខ្លាចយើងសងសឹកឲ្យឪពុកម្តាយយើងវិញ ទើបចាប់ទាំងសាច់ញាតិបងប្អូនសូម្បីតែអ្នករួមការងារជាមួយគ្នាក៏ដោយ ។

ខ្ញុំចូលធ្វើបដិវត្តន៍ពេលអាយុបាន១៨ឆ្នាំ ។ ដំបូងខ្ញុំនៅកងកុមារ និងក្រោយមកនៅមន្ទីរជួសជុលអាវុធ ។ ឆ្នាំ១៩៧៧ ខ្មែរក្រហមឲ្យខ្ញុំកាន់កាំភ្លើងមួយដើម ហើយបញ្ជូនខ្ញុំទៅច្បាំងជាមួយវៀតណាមតាមព្រំដែន ។ ខ្ញុំធ្លាប់តែស្គាល់យួនលក់ត្រីនៅផ្សារ តែខ្ញុំមិនច្បាស់ថាវៀតណាមមានរូបរាងយ៉ាងម៉េចទេ ។ យ៉ាងណាក៏ដោយ ខ្ញុំត្រូវតែប្រយុទ្ធព្រោះខ្ញុំគ្មានកន្លែងណាគួរទៅទៀតទេ ។

ខ្ញុំមានប្រវត្តិរូបមិនល្អ ។ ក្រោយពេលឪពុកម្តាយខ្ញុំត្រូវជម្លៀសចេញ ខ្ញុំភ័យញ័រខ្លួនអស់ហើយ ព្រោះខ្មែរក្រហមតាមកត់ប្រវត្តិរូបនិងសកម្មភាពរបស់ខ្ញុំយ៉ាងលម្អិតរាល់អាទិត្យ ។ ខ្មែរក្រហមឃ្លាំមើលខ្ញុំជាប់ ហើយផ្លាស់ខ្ញុំទៅកន្លែងនេះកន្លែងនោះជាច្រើនដង ។ លើសពីនេះទៅទៀត ខ្មែរក្រហមបានចុះទៅភូមិខ្ញុំតាមដានគោលជំហរថែមទាំងសាកសួរមេក្រុមខ្ញុំអំពីរឿងរ៉ាវរបស់ខ្ញុំទៀតផង ។ សំណាងល្អដែលមេក្រុមរបស់ខ្ញុំស្រលាញ់រាប់អានខ្ញុំទើបគាត់រាយការណ៍ប្រវត្តិរូបខ្ញុំដោយឥតលាក់លៀម ។

ចាប់ពីឆ្នាំ១៩៧២មក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីបងយ៉ន ទេ ។ អ្នកខ្លះនិយាយថា គាត់ស្លាប់ ហើយខ្លះទៀតថាគាត់រស់នៅប៉ៃលិន ។ ខ្ញុំចង់ទៅលេងគាត់ដែរតែលុយកាក់សោហ៊ុយមិនគ្រប់ ម្យ៉ាងប៉ៃលិនជាតំបន់ក្តៅគគុកក្រោយឆ្នាំ៧៩ ហើយវាស្ថិតនៅក្រោមការកាន់កាប់របស់ទាហានខ្មែរក្រហមនៅឡើយ ។ អ្នកនៅក្បែរផ្ទះរបស់គាត់និយាយថា គាត់ទើបនឹងស្លាប់ថ្មីៗនេះដោយសារកើតអេដស៍ ។

តើខ្ញុំធ្វើម៉េចសងសឹកឲ្យក្រុមគ្រួសារខ្ញុំបានទៅ បើខ្ញុំមិនទាំងដឹងថាអ្នកណាជាជនដៃដល់ផង? សព្វថ្ងៃនេះប្រជាជនខ្លះថាតាម៉ុក ជាមេនាំគំនិត ប៉ុន្តែបើទោះជាយើងកាត់សាច់គាត់ជាចម្រៀកៗយកមកហូបក៏មិនគ្រប់សម្រាប់ជីវិតជនរងគ្រោះជាងមួយលាននាក់ដែរ ។ គ្មានអីដែលអាចទូទាត់សងនូវការឈឺចាប់របស់យើងបានឡើយ ។

ខ្ញុំមានអារម្មណ៍ថាឯកោព្រោះគ្មានគ្រួសារនៅទំនុកបម្រុងនឹងគេ ។ គ្រួសារដទៃទៀតនៅមានសាច់ញាតិបងប្អូន ឯខ្ញុំវិញគ្មាន វាហាក់បីដូចជាខុសគ្នាឆ្ងាយណាស់ ។ រាល់ថ្ងៃ ខ្ញុំព្យាយាមលួងលោមខ្លួនឯងកុំឲ្យគិតដល់រឿងទាំងនេះ ព្រោះខ្ញុំម្នាក់ឯងមិនអាចយកវត្ថុដែលបាត់បង់ទៅត្រឡប់មកវិញបានទេ ។ ◆◆◆

# ត្រូវតែកាត់ទោសដើម្បីទុកជាមេរៀន

ក្នុងអារម្មណ៍ខ្ញុំអស់រយៈកាល៣០ឆ្នាំកន្លងទៅ ដែលនៅតែមានការងឿងឆ្ងល់ចំពោះទង្វើរបស់ខ្មែរក្រហម "កម្ពុជាប្រជាធិបតេយ្យ" ដឹកនាំដោយ ប៉ុល ពត និងបក្ខពួក ជាពិសេសការបណ្តេញអ្នកទីក្រុងភ្នំពេញឲ្យចេញពីទីក្រុងទាំងតក់ក្រហល់ក្នុងអំឡុងពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ និងការសម្លាប់រង្គាលដោយគ្មានអាណិតអាសូរទៅលើទាហានលន់ណុល សិស្ស និស្សិត បញ្ញវន្ត ព្រះសង្ឃ សាស្ត្រាចារ្យ សិល្បករ ។ល។ ជាពិសេសឆ្លើយសឹកសង្គ្រាមនៃទាហានលោកលន់ណុល ដែលភាគច្រើនចូលធ្វើទាហានក៏ដើម្បីការពារទឹកដីនិងមាតុភូមិពីសំណាក់សត្រូវឈ្លានពានដែលទីបំផុតមេដឹកនាំខ្មែរក្រហមទាំងនោះក៏ធ្វើសង្គ្រាមតទល់នឹង"ពួកវៀតកុង" ។

តើនរណាជាអ្នកបញ្ជាឲ្យដេញបងប្អូនអ្នកទីក្រុងទាំងអស់ "ជាពិសេសអ្នកទីក្រុងភ្នំពេញ"? ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា, សុន សេន, តាម៉ុក, នាយឌុច? ឬជាផែនការនយោបាយដ៏ខ្មៅកខ្វក់របស់បរទេសណាមួយ?

បើបំណាច់នឹងធ្វើសង្គ្រាមមកតទល់ជាមួយកងទ័ពវៀតណាមខាងដើមដដែលជាដដែល តើចាំបាច់សម្លាប់ទាហានលន់ណុលធ្វើអ្វី? តើការរៀបចំប្រទេសជាតិដែលគ្មានសាលារៀន គ្មានប្រាក់ចាយវាយ គ្មានអ្វីៗទាំងអស់ ជាពិសេសការរំលាយព្រលឹងជាតិខ្មែរ "ការបំបាត់ស្ថាប័នមន្ត្រីអគ្រានុកូលដ្ឋាន" នោះជាគំនិតរបស់អ្នកណា?

នេះជាចម្ងល់ពីរ-បីចំណុចក្នុងចំណោមចម្ងល់ជាច្រើនដែលដក់ក្នុងអារម្មណ៍របស់ខ្ញុំឥតស្រាកស្រាន្ត ហើយអំពើពិឃាដដែល ប៉ុល ពត និងបក្ខពួកបានប្រព្រឹត្ត លទ្ធផលគឺវាលពិឃាដឬទីលានមរណៈដ៏ធំមួយដែលប្រជាជាតិខ្មែរបានទទួល គឺសេចក្តីស្លាប់ដ៏សែនវេទនា ចុកចាប់ និងអយុត្តិធម៌ជាទីបំផុត ដែលគួរណាបានទទួលនូវការកាត់ក្តីមួយប្រកបដោយយុត្តិធម៌ជាយូរណាស់មកហើយ មិនចាំបាច់ពន្យាររហូតដល់៣០ឆ្នាំដូច្នេះឡើយ ។

ការកាត់ក្តីបណ្តាមេខ្មែរក្រហមដែលត្រូវប្រព្រឹត្តឡើងដោយមានចៅក្រមអន្តរជាតិចូលរួមផងនៅពេលខាងមុខនេះគឺជាលើកទីមួយសម្រាប់ថ្នាក់អន្តរជាតិនិងជាលើកទីពីរសម្រាប់រកយុត្តិធម៌ជូនបងប្អូនខ្មែរទាំងអស់ដែលស្លាប់ទៅយ៉ាងខ្លោចផ្សាជាងពីរលាននាក់ ជាពិសេសចំពោះអ្នកទីក្រុងភ្នំពេញដែលកាលអំឡុងឆ្នាំនោះ "១៩៧០-១៩៧៥" មានចំនួនជាងមួយលាននាក់ ពេលត្រឡប់មកវិញក្នុងឆ្នាំ១៩៧៩ មានមិនដល់៥ពាន់គ្រួសារផង ។

ការកាត់ក្តីមេដឹកនាំខ្មែរក្រហមដែលនឹងប្រព្រឹត្តទៅនាថ្ងៃខាងមុខអាចផ្តល់យុត្តិធម៌ជូនជនរងគ្រោះដែរឬទេ? តើបងប្អូនខ្មែរដែលនៅសល់ពីស្លាប់ក្នុងរបបដ៏ឃោរឃៅនោះបានទទួលរង្វាន់ឬលទ្ធផលយ៉ាងណា?

ក្នុងអារម្មណ៍របស់ខ្ញុំ ខ្ញុំយល់ឃើញថា ទោះបីការកាត់ក្តីនោះពុំបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះ១០០ភាគរយឬការកាត់ក្តីនោះចំណេញដល់ប្រទេសឬមហាអំណាចណាមួយក៏ដោយក៏ត្រូវតែប្រព្រឹត្តទៅជាដាច់ខាតដើម្បីជាមេរៀនមួយសម្រាប់ដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលដឹកនាំប្រទេសចូលទៅកាន់មហាវិនាសកម្មមួយ ជាពិសេសពូជសាសន៍របស់ខ្លួនដែលត្រូវសម្លាប់យ៉ាងរង្គាលនិងអយុត្តិធម៌បំផុតពីរបបអ្នកដឹកនាំទាំងនោះ ហើយដែលរាស្ត្រខ្មែររងគ្រោះត្រូវទទួលបាននូវការកាត់ក្តីមួយប្រកបដោយយុត្តិធម៌ដែលប្រជាជនកម្ពុជានិងអន្តរជាតិចង់បានជាទីបំផុត ។

**ហេង ថាល់សាឧុធ**

## ពាក្យស្លោកខ្មែរក្រហម

◆ **កម្ចាត់ជាដាច់ខាតយួនឈ្លានពានខាតធី លេបទឹកដី ឱ្យវិនាសអន្តរធានពីទឹកដីកម្ពុជា។**

*(ដកស្រង់ពីសៀវភៅ០៧៦កណហ)*

# សូមពិចារណាឡើងវិញអំពីជើងឯក

*ខ្ញុំជាជនកម្ពុជាមួយរូបដែលបានឆ្លងកាត់សង្គមមួយដែលអ្នកផងទាំងពួងបានដាក់ឈ្មោះថា «គុកឥតជញ្ជាំង» ឬសង្គមវាលពិឃាដ ។ ថ្វីត្បិតតែរហូតដល់ដល់សព្វថ្ងៃមានរយៈពេលជាង២៥ឆ្នាំទៅហើយក្តី នៅក្នុងខួរក្បាលរបស់ខ្ញុំនៅតែឃើញអ្វីៗដែលយើងបានទទួលនូវអ្វីៗទាំងពួងដែលសង្គមនោះសាបព្រោះមកលើយើងយ៉ាងប្រត្យក្ស ។*

*លោកនាយកមជ្ឈមណ្ឌលឯកសារជាទីរាប់អាន!*

*ខ្ញុំគិតថា សង្គ្រាមនៅក្នុងប្រទេសដ៏កម្សត់របស់យើងកកើតឡើងមិនមែនជារឿងចៃដន្យនោះទេ តាមពិតទៅគឺជាការសម្រេចចិត្តខុសខាងនយោបាយមួយយ៉ាងធ្ងន់ធ្ងរបំផុត អ្វីៗត្រូវបានបំផ្លិចបំផ្លាញ ហើយមានមនុស្ស៣លាននាក់ស្លាប់ដោយសារការសម្លាប់ អត់អាហារ គ្មានថ្នាំព្យាបាល ក្នុងចំណោមមនុស្ស៧លាននាក់ ។*

*ទាក់ទិននឹងរឿងរ៉ាវខាងលើ នាពេលថ្មីៗកន្លងមកនេះខ្ញុំបានដឹងតាមរយៈសារពត៌មានថា មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកត្រូវបានរាជរដ្ឋាភិបាលវិនិយោគឲ្យក្រុមហ៊ុនមួយរបស់ជប៉ុនដើម្បីអភិវឌ្ឍតំបន់ទេសចរណ៍ ។ ក្រោយពីបានដឹងនូវដំណឹងនេះខ្ញុំចេះតែមានអារម្មណ៍ថា តំបន់ជើងឯកគឺជាមណ្ឌលសម្លាប់មនុស្សរាប់ម៉ឺននាក់ក្រោមស្នាដៃរបស់ ឌុច ដែលយកពីគុកទួលស្លែងឬមន្ទីរឃុំឃាំង ស-២១នោះ ហើយជាកន្លែងដែលប្រជាជនគ្រប់វណ្ណៈនៅទីក្រុងភ្នំពេញ បានទៅខ្ទិសដល់វិញ្ញាក្ខន្ធអ្នកដែលបានស្លាប់ទៅដោយពុំមានកំហុសជារឿងរាល់រដូវ ម្យ៉ាងវិញទៀត ចំពោះក្រុមហ៊ុនឯកជនហើយជាជនបរទេសផងនោះ ខ្ញុំបាទគិតថាគេនឹងមិនធ្វើអ្វីៗដូចដែលរដ្ឋាភិបាលបានគិតនោះទេ ហេតុនេះខ្ញុំសូមចូលរួមគាំទ្រទាំងស្រុងចំពោះគំនិតរបស់លោក ឆាំង យុ ដែលសុំឲ្យរដ្ឋាភិបាលគិតម្តងទៀតចំពោះការជួលនេះ ។*

**ហ៊ិន សារុន**

## សេចក្តីប្រកាសរកបងប្រុសនិងបងស្រី

*នាងខ្ញុំឈ្មោះ ខែក អ៊ិន អាយុ៤៨ឆ្នាំ រស់នៅភូមិបល្ល័ង្ក ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានបងប្អូនស្រី៣នាក់ ប្រុស៣នាក់ ។ សូមសួររក ១)បងប្រុសឈ្មោះ ច្រឹង សឿ ២)បងស្រីឈ្មោះ ច្រឹង សួរ ដែលទាំងពីរនាក់នេះបានបាត់ខ្លួនកាលពីឆ្នាំ១៩៧៩ ។ នៅចុងឆ្នាំ១៩៧៨ បងប្រុស សឿ បានផ្ញើសំបុត្រមកសួរសុខទុក្ខក្រុមគ្រួសារដោយប្រាប់ថា គាត់ធ្វើជាទ័ពនៅកងពលមេមត់ ចំណែកបងស្រី សួរ បែកគ្នានៅឆ្នាំ១៩៧៩ ដោយមានអ្នកជួបគាត់ពេលរត់ឡើងភ្នំនៅមណ្ឌលគិរី ។*

*បើសាមីខ្លួនទាំងពីរបានឮ ឬបងប្អូនបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមផ្តល់ពត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើតាមប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។ សូមអរគុណ ។*

## សេចក្តីប្រកាសរកបងប្រុស

*ខ្ញុំបាទឈ្មោះ ហ៊ុន រីម និង ហ៊ុន រុន ភេទប្រុស រស់នៅភូមិត្រពាំងក្រោល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។ សូមសួររកបងប្រុសឈ្មោះ ហ៊ុន ធៀង មានឈ្មោះបដិវត្តន៍ រ៉េត ដែលបានបាត់ខ្លួនតាំងពីពេលដែលចេញពីផ្ទះទៅបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៤ ជាមួយអ្នកជិតខាងឈ្មោះ ចិន មិ និង មឿន តាមរយៈប្រធានឃុំឈ្មោះ ប៊ុញ ។*

*បើសាមីខ្លួនបានឮ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើ សូមផ្តល់ពត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើតាមប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។ សូមអរគុណ ។*

# ថ្ងៃ១៧មេសា

១ - ១៧ មេសា ចង្រៃឫស្សា ខ្មែរក្រុងមិនភ្លេច ក្រុមព្រាយបិសាច
គ្រងខ្មៅគគ្រិច ចូលមកពន្លិច បណ្តេញយើងទៅ ។
២ - ១៧ មេសា ចង្រៃឫស្សា ឈាមក្រហមឆ្អៅ រាស្ត្រខ្មែរវឹកវរ
ព្រាត់ប្រាសកូនចៅ វាដេញយើងទៅ ដាមដោយទឹកភ្នែក ។
៣ - ១៧ មេសា ចង្រៃឫស្សា ស្រុកប្រួលប្រែប្លែក ឫស្សីចេញផ្លែ
ដើមពោធិ៍បាក់មែក អំបែងកំបែក អណ្តែតព្រោងព្រាត ។
៤ - ១៧ មេសា ចង្រៃឫស្សា ប៉ុលពតពេជ្ឈឃាត ខ្លួនកើតជាខ្មែរ
តែចិត្តចង្អៀត ប្រើល្បិចគ្រប់ស្មៀត សងសឹកឈ្នានីស ។
៥ - ១៧ មេសា ចង្រៃឫស្សា លើលោកយើងនេះ មិនដែលមានទេ
ពួកខ្មែរកុម្មុយនិស្ត ចិត្តខ្មៅសំគិះ ដូចសត្វតិរច្ឆាន ។
៦ - ១៧ មេសា ចង្រៃឫស្សា រកភ្លេចមិនបាន សម្លាប់ជិះជាន់
ជាតិខ្មែរគ្រប់ប្រាណ អស់ជិតបីលាន ព្រោះតែគំនុំ ។
៧ - ១៧ មេសា ចង្រៃឫស្សា ថ្ងៃដែលយើងយំ ទឹកភ្នែកយើងហូរ
ឆ្អឹងគរដូចភ្នំ បើវាស់ទំហំ ធំជាងសមុទ្រ ។
៨ - ១៧ មេសា ចង្រៃឫស្សា ក្តៅដូចទឹកក្រុត ទឹមមនុស្សដូចគោ
បាញ់ចាក់សម្លុត រាស្ត្រខ្មែរភ័យស្លុត ទុរភិក្សវឹកវរ ។
៩ - ១៧ មេសា ចង្រៃឫស្សា ខ្មែរផ្អើលឈូឆរ ខ្វះរត់ចោលស្រុក
ធ្វើខ្វាក់ថ្លង់គរ បើកទ្វារចំហ ទមិឡចូលព្រោងព្រាត ។
១០ - ១៧ មេសា ចង្រៃឫស្សា ខ្មែរត្រូវប្រុងស្មៀត ចិត្តត្រូវចងចាំ
ពួកប្រេតចោលម្សៀត សូមកុំភ្លាត់ទៀត កុម្មុយនិស្តឈ្លានពាន ។
១១ - ១៧ មេសា ចង្រៃឫស្សា សូមខ្មែរគ្រប់ប្រាណ ចាត់ទុកជាថ្ងៃ
ចង្រៃសាមាន្យ បានដល់វិមាន កុំភ្លេចខ្មុមចាស់ ។
១២ - ១៧ មេសា ចង្រៃឫស្សា ថ្ងៃប្រវត្តិសាស្ត្រ ឈាមខ្មែរហូរស្រោច
ខ្មែរស្លាប់ច្រើនណាស់ សូមចាំឲ្យច្បាស់ ខ្មែរអើយកុំភ្លេច ។

**ហេង ថាល់សាទុធ**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

DC-Cam Main Office: #66, Preah Sihanouk Blvd, Tonle Basac, Chamkar Morn, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email:dccam@online.com.kh, Homepage: www.dccam.org.